# គ្រាប់ពូជសត្វពស់

ព្រះជាម្ចាស់ជាទីស្រឡាញ់ជាព្រះមាន ឫទ្ធិចេស្តាដែលបង្កើត សព្វអ្វីៗដោយ អំណាច ចេស្តានៃព្រះវិញ្ញាណទ្រង់ ហើយ ទ្រង់នាំព្រះយេស៊ូវគ្រីស្ទ ជាបុត្រាតែមួយរបស់ទ្រង់ ជាអ្នកដែលសុគត សម្រាប់យើងជាមនុស្សបាប ជាអ្នកសុចរិតជំនួសអ្នកទុចរិត ដើម្បីផ្សះផ្សាយើងជាមួយការប្រកបគ្នាដ៏អស្ចារ្យម្តងទៀតជាមួយព្រះ។ ដូចដែលយើងត្រូវបានបង្រៀនក្នុងព្រះបន្ទូលដ៏មានពរ ដែលយើង បាន ទៅរកការ ប្រកបគ្នាមុនពេលដាក់គ្រឹះនៅផែនដី "ពេលដែលតារាពេលព្រឹកច្រៀងឡើងទាំងអស់គ្នា ហើយព្រះបុត្រារបស់ ព្រះស្រែកដោយអំណរ ត្រលប់ទៅមុនពេលមានគ្រឹះនៅផែនដី។" តើយើងដឹងបានយ៉ាងណាថានោះ មិនមែនជាពេលដូចគ្នា ទៅនឹងពេល ដែលកូនចៀមត្រូវបានគេសម្លាប់ពេល ដែលព្រះជាម្ចាស់នៅក្នុង ព្រះទ័យដ៏អស្ចារ្យឃើញយើងស្រែក និង អបអរក្នុងសេចក្តីសង្គ្រោះតាមរយៈព្រះយេស៊ូវ?

2 ហើយយប់នេះយើងទទួលបានអាទិភាពពី ភាពជាព្រះដ៏មានសិរីរុងរឿងដែលនឹងបង្ហាញក្នុងការយាងមកជាលើកទីពីរ។ រាល់ជម្ងឺនិង ទុក្ខព្រួយនឹងត្រូវបាត់ទៅ។ ហើយយើងនឹងមានរាងកាយ ដូចជារាងកាយដ៏រុងរឿងរបស់ទ្រង់ផ្ទាល់ យើងនឹងឃើញទ្រង់ជាយ៉ាងនោះ។ នៅទីនេះយើង ឃើញដៃរបស់យើង ដែលរួញទៅសក់របស់យើងប្រែជាប្រផេះ ស្មាក៏កោង យើងដឹងថា យើងនឹងអាចស្លាប់ហើយ តម្រង់ទៅរកធូលីដីដែលក្បាលយើងកំពុងឱនដាក់និង កន្លែងណាដែលយើង ចេញមក។ ប៉ុន្តែព្រះអម្ចាស់ជាព្រះ ដូចអ្វីដែលជាក់ច្បាស់ទ្រង់ជាព្រះ ទ្រង់បាន សន្យាថាយើងនឹងត្រូវបានលើកឲ្យរស់វិញនៅថ្ងៃចុងក្រោយ ហើយ យើងពិតជាជឿ។

3 ទូលបង្គំ ឈរយ៉ាងមុតមាំដោយជំនឿ របស់ទូលបង្គំនៅយប់នេះក្នុងព្រះវត្តមានរបស់ទ្រង់ ចូលមកដោយមានភាពជឿជាក់ព្រោះព្រះយេស៊ូវបានចងយើងក្នុងការធ្វើរឿងនេះ។ មិនមែនអាស្រ័យលើការល្អដែលទូលបង្គំធ្វើ ទូលបង្គំមិនបានធ្វើអ្វីដែលល្អឡើយ ប៉ុន្តែទូលបង្គំមកដោយបន្ទាបខ្លួន ប្រកាសថាទូលបង្គំមានវត្ត មានតម្លៃនេះ ព្រោះដោយសារតែព្រះគុណដែលទ្រង់ប្រទានដល់ទូលបង្គំ។ ដូច្នេះទូលបង្គំចូលមកទូលសូម ដែលទ្រង់នឹងប្រទានពរដល់ទូលបង្គំនៅយប់នេះ ក្នុងការនាំព្រះបន្ទូលមក។ ព្រោះមានការសរសេរទុកមកថា "មនុស្សមិនមែន

រស់ដោយសារតែនំប៉័ងឡើយ ប៉ុន្តែគ្រប់ពីព្រះបន្ទូល ចេញពីព្រះឱសរបស់ព្រះផងដែរ។″ ហើយ សូមឲ្យព្រះឱស្ឋរបស់ព្រះ មានបន្ទូលនៅយប់នេះ។ សូមឲ្យព្រះបន្ទូលចេញមកហើយ បានចូលទៅក្នុងជម្រៅចិត្តរបស់យើង ជាអ្នកស្តាប់ និង បំពេញដោយព្រះវិញ្ញាណ និង វត្តមានរបស់ទ្រង់។ ទូលបង្គំទូលសូមដោយព្រះនាម ព្រះយេស៊ូវគ្រីស្ទ។ អាម៉ែន។

4 ថ្ងៃ—នេះ និង ម្សិលមិញ យប់មិញ ហើយនឹង ថ្ងៃនេះ យើងបាននិយាយពីប្រធានបទ ទីមួយ ចាប់ផ្តើមដំបូង *ហេតុអ្វីបានជាយើងមិនមែនជានិកាយ*។ ហើយយើងនឹងធ្វើឲ្យវាកាន់តែមុតមាំ ហេតុអ្វីបានជាយើងមិនមែនជានិកាយ ហើយហេតុអ្វីបានជាយើងមិនជឿលើនិកាយ។ ព្រោះយើងបានរកឃើញ ក្នុងព្រះគម្ពីរនិកាយមិន ដែលចេញមកពីការតាំងរបស់ព្រះជាម្ចាស់ឡើយ វាជាការតាំងពីអារក្ស និង បានបង្ហាញមកដោយព្រះគម្ពីរ។ ហើយយ៉ាងណាក៏ដោយ តាមរយៈនិកាយនាំឲ្យមានកំហុសឆ្គង។ ឥឡូវយើងនិយាយពីរឿងនេះដើម្បីកែតម្រង់ និង នាំយកពាងឧបោសថមកកាន់ការប្រកបគ្នាពីព្រះបន្ទូលព្រះដែលមានព្រះពរ។នោះសេចក្តីសង្ឃឹមរបស់យើងមិនសង់ លើការនិយាយរបស់និកាយឡើយ ឬមនុស្សណាម្នាក់និយាយដែរវាសង់នៅលើអ្វី ដែលព្រះអម្ចាស់ជាព្រះមានបន្ទូល។ ហើយនោះជារបៀបតែមួយដែលជាសេចក្តីត្រឹមត្រូវជានិច្ច។

5 ហើយនៅព្រឹកនេះ ខ្ញុំមានប្រាំចំនុច ខ្ញុំជឿ អត្ថបទផ្សេងៗដែលចេញមកពីនិកាយ មិនបាននិយាយនៅក្នុងព្រះគម្ពីរឡើយ នោះជាអ្វីដែលក្រុមជំនុំប្រូតេស្តង់ខំធ្វើបែបនោះ ហើយ បង្រៀនគោលលទ្ធិ ដូចគ្នានូវអ្វីដែលម្តាយជាពេស្យាដែរកាតូលិកជាអ្នកអធិប្បាយ ហើយចេញមកជាក្រុមជំនុំប្រូតេស្តង់។ ហើយយើង ទៅរកអ្វីដូចគ្នា ដែលទាស់នឹងគ្រប់ផ្នែកក្នុងព្រះបន្ទូលរបស់ព្រះ។

6 ក្រុមជំនុំនិកាយទីមួយ យើងបានសម្លឹងមើលនៅសៀលនេះក្នុងប្រវត្តិសាស្ត្រឪពុកនីសិននៃក្រុមជំនុំនីសិន។ នៅក្នុងមរណៈភាពរបស់សាវក មានឪពុកចេញមកជា នីសិន ពួកគេបន្តពីរបីឆ្នាំ។ បីរយម្ភៃប្រាំឆ្នាំ ទីបំផុតក៏ក្លាយជា—ជា នីសៀប្រទេសបារាំងជាកន្លែងដែល—ដែលគេចាប់ផ្តើមក្រុមប្រឹក្សា នីសៀ ដ៏ធំ។ ហើយគេក៏បង្កើតសាសនា ដែលជាក្រុមជំនុំកាតូលិកដែលមានសព្វ ថ្ងៃ ហើយក៏ហុចបន្តទៅជាប្រូតេស្តង់។

7 ហើយ ដូចដែលខ្ញុំបាននិយាយ—កាលពីការបង្រៀនព្រឹកមិញ "សម័យកាលក្រុមជំនុំនីមួយៗនេះ ពីរឿងនោះ—សម័យក្រុមជំនុំថៃស្សាទីរ្សនិក ១៥០០ឆ្នាំនៃសម័យកាលងងឹត មិនមែនតែម្តងទេប៉ុន្តែអ្វីដែលទ្រង់មានបន្ទូល 'អ្នកនៅតែមានព្រះនាមយើង។'"

8 ហើយ នៅផ្នែកមួយទៀត ពួកគេមិននៅក្នុងព្រះគ្រីស្ទតទៅទៀតឡើយ។ ពួកគេបានបង្កើតចេញឈ្មោះនិកាយ "កាតូលិក លូធឺ វេស្លេ បាបទីស្ត ព្រីសប៊ីធីរៀន ពេនទីកុស្ត" បន្តចុះមក។

9 ប៉ុន្តែមុនបញ្ចប់សម័យកាលក្រុមជំនុំ ទ្រង់មានបន្ទូល "យើងដាក់ទ្វាចំហរ នៅពីមុខអ្នកៗ" ឃើញទេ? ហើយនោះជាសម័យកាលដែលយើងជឿថាយើងកំពុង តែនៅសព្វថ្ងៃ សម័យកាលទ្វាចំហរ រវាងកាបន្តនៃក្រុមជំនុំឡៅឌីសេ។

10 ហើយ វាមានរយៈពេលបីរយម្ភៃឆ្នាំជាក្រុមប្រឹក្សាឡៅឌីសេ។ ហើយនៅក្នុងនោះ ពួកគេទទួលទម្រង់ទាំងនេះ។ ហើយពួកគេទទួលទម្រង់នេះដូចជា ការប្រស់ទឹក ចាក់ទឹក ការជ្រមុជទឹកខុស ព្រះវិញ្ញាណបរិសុទ្ធខុស និងអ្វីផ្សេងទៀតទាំងអស់នេះ។ ពួកគេទទួល។

11 ហើយបន្ទាប់ពេលដែល លូធឺ ជាសង្ឃ និង ចេញពីក្រុមជំនុំកាតូលិក បាននាំទាំងអស់នេះចេញមក។ ហើយចេញមកពីនោះទៀតមានស្វីងលី(Zwingli)ចេញពី Zwingli មានកាល់វីន( Calvin)ចញេពី Calvin មានវេស្លេ អូ បន្តចុះ។ ហើយពួកគេបន្តនាំមកសាសនាទាំងនោះចុះមក។ ហើយតើព្រះជាម្ចាស់ដឹកនាំក្រុមជំនុំទ្រង់ម្តេចបាន ពេលពួកគេកំពុងដើរតាមផ្លូវ ដែលទ្រង់មិនបាននាំគេចេញមកសម្រាប់ទទួលការដឹកនាំ?

12 ហើយចងចាំ ក្នុងវិវរណៈ១៧ យើងឃើញមាន "ស្ត្រីម្នាក់។" ឥឡូវពាក្យទាំងនេះបានចេញមកច្បាស់។ ពួកគេសរសេរក្នុងព្រះគម្ពីរ ដូច្នេះខ្ញុំអាចនិយាយពីពួកគេបាន។ វាបាននិយាយថាស្ត្រីម្នាក់នេះជា "ស្រីសំផឹង" ដែលមានន័យថាជាស្ត្រីមានកិត្តិយស ខូចខាតដែលនាង តម្រូវឲ្យរៀបការជាមួយប្តីម្នាក់ ប៉ុន្តែបែរជារួមភេទជាមួយ លោកិយវិញ។ ហើយ នាងមាន...នាងជា "**ម្តាយនៃស្រីសំផឹង**" ដូច្នេះនាងក៏ មានកូនស្រីជាច្រើន។ ហើយ យើងអាចទាញយកបានផ្នែកភូមិសាស្ត្រពីទីនោះ ចាប់ផ្តើម...និងមានខ្ញុំផ្ទាល់ មើលឃើញក្នុងខគម្ពីរឃើញពីគោលលទ្ធិរបស់នាង ហើយអ្វីគ្រប់យ៉ាង ខ្ញុំជឿថាព្រះអម្ចាស់បានដាក់វាជាខ្សែរបន្ទាត់

យ៉ាងល្អឥតខ្ចោះ ដែលមិនមែនជាអ្វីផ្សេងទៀត ឡើយក្រៅពីក្រុមជំនុំកាតូលិក។ វាជាផ្លូវតែមួយអាចធ្វើទៅបាន។ ហើយនាងបង្កកំណើតឲ្យអ្វី? ក្រុមជំនុំប្រូតេស្តង់។ ជាការ ពិត នាងបានធ្វើ។

13 ហើយនាងមានពែងស្រានៃ ការកំផិតនៅក្នុងដៃរបស់នាង ហើយនាងបានហុច វាទៅឲ្យស្ដេចលើផែនដី។ ហើយនាងជាអ្នកគ្រប់គ្រងនៅលើផែនដី និយាយពីព្រលឹងវិញ្ញាណ។ ហើយនោះគឺបែបហ្នឹង។ មិនមែនជាអ្វីផ្សេងទៀតឡើយ...

14 មើល ចូរ យើងត្រឡប់ទៅដានីញ៉ែល និង យករូបភាពនោះ។ មើលរូបភាព នេះ: ក្បាលពីមាស អាណាចក្របាប៊ីឡូន ប្រាក់...ឬប្រាក់ Medes-o-Persia លង្ហិន អេឡិចសាន់ដឺ ដឺ ហ្គ្រេត និង បន្តទៀត អាណាចក្រក្រិក(Grecian) និង ចក្រភពរ៉ូម រ៉ូមខាងកើត និង ខាងលិច ជាជើងទាំងពីរ។

15 ហើយចូរកត់ចំណាំ ក្នុងនគរទាំងដប់នេះ ដែលស្ដែងបានមកស្មែងទាំងដប់ដែលយើងនិយាយនៅព្រឹកនេះ ក្នុងនគរនីមួយនៃនគរទាំងដប់ ដែលកើតឡើងមានដែក និង ដីឥដ្ឋលាយជាមួយគ្នា។ ហើយដែកជាជើង ដែលជារ៉ូម។ ហើយមានស្នាមឆ្កូតនៃលទ្ធិរ៉ូម៉ាំង ដែលលាយគ្នាក្នុងរាល់ជាតិសាសន៍ ដែលនៅក្រោមមេឃ តាមរយៈក្រុមជំនុំកាតូលិក។ នោះជាការត្រឹមត្រូវ។ ហើយពួកគេមិនលាយគ្នាទេ នៅកន្លែងណាក៏ដោយ។

16 ហើយពួកគេរៀបការជាអន្តរអាពាហ៍ពិពាហ៍ ក្នុងចំណោមគ្នាទៅវិញទៅមក។ ព្រះគម្ពីរនិយាយថាគេនឹងធ្វើ។ ហើយសូមមើលសព្វថ្ងៃនេះ។ កូនប្រុសរបស់អ្នកទៅតាមក្មេងស្រីកាតូលិក ពេលពួកគេចេញទៅក្រៅហើយរៀបការ ពួកគេត្រូវសន្យាថានឹងចិញ្ចឹមកូនឲ្យក្លាយជាកាតូលិក ឃើញទេ ទៅវិញទៅមក។ មើលវាពិត ជាបំបែកអំណាចអ្នកផ្សេង។

17 ប៉ុន្ដែនោះជាអ្វី? ព្រះគម្ពីរនិយាយថាជាពេស្យាចារលក្ខណៈទាំងមូល។ ឥឡូវតើអ្នកនឹងធ្វើអ្វី? នោះជាការត្រឹមត្រូវណាស់។ ហើយតើបាបរបស់មនុស្សនឹងត្រូវបានចូលមក...យើងត្រលប់ទៅចោទិយកថា និង បង្ហាញពីក្មេងដែលត្រូវបានចុះតាមច្បាប់ ក្មេងឥតខាន់ស្លា មិនអាចចូលក្នុងជំនុំរបស់ព្រះអម្ចាស់១៤ជំនាន់។ នោះគឺនៅក្រោមច្បាប់។ ហើយ ព្រះគ្រីស្ទយាងមកដើម្បី ពង្រីកច្បាប់វិន័យ។ តើជាជាងប៉ុណ្ណាទៅទៀត នាបច្ចុប្បន្ន?

18 ហើយតើមានអ្វីកើតឡើងចំពោះរឿងនេះ មានបញ្ហាអ្វីចំពោះក្មេងស្រីនៅតាមផ្លូវទាំងនេះនាសព្វថ្ងៃ ស្ត្រីដក់បារីក្មេងៗ ស្លៀកខ្លី ស្រីកាត់សក់ខ្លីៗនិងផ្សេងទៀត? តើមានបញ្ហាអ្វីកើតឡើងចំពោះវា? វាព្រោះតែម្តាយរបស់ពួកគេធ្វើបែបនោះ។ វាត្រូវបានចូលមក ការទុចរិត ពីជំនាន់មួយទៅជំនាន់មួយ។ នោះជាអ្វីបែបនោះហើយ។ ហើយតើយើងទទួលបានអ្វី? យើងមកដល់កន្លែងមួយដែលប្រមូលផ្តុំដោយបាប ស្មោគគ្រោក។

19 នោះជាហេតុផលដែលព្រះបានលើករុស្ស៊ីឡើង នៅខាងនាយ ជាមួយគ្រាប់បែកអាតូមិក ដើម្បីលុបបំបាត់នាងចោល ដូចជាទឹកជំនន់កាលពីបុរាណពេលដែលទ្រង់លើកពពក។ ប្រាកដណាស់ទ្រង់ធ្វើ។ ហើយព្រះគម្ពីរនិយាយដូច្នោះ។ រុស្ស៊ីជាប្រទេសមិនជឿថាមានព្រះ មិនជឿថាមានព្រះ បានសម្តែង ឡើងដូចអ្វីដែលនៅក្នុងព្រះហស្ត ព្រះជាម្ចាស់ដ៏មានចេស្តា។ ដូចជាស្តេចនេប៊ូក្នេសាត្រូវ បំផ្លាញ អ៊ីស្រាអែលដែរ ព្រោះពួកគេមិនបានដើរជាមួយព្រះជាម្ចាស់ រុស្ស៊ីត្រូវងើបឡើងដើម្បី "សងសឹកពួកបរិសុទ្ធ" នៃក្រុមជំនុំកាតូលិក ពីរឿងឈាមដែលនាងបានបង្ហូរឈាមរបស់ពួកអ្នកបរិសុទ្ធ។ ព្រះគម្ពីរនិយាយបែបនោះ។ វាត្រូវយករឿងទាំងមូល។

20 ដូច្នេះ មើលនៅទីនេះ បើម្តាយរបស់ពួកគេជាស្រីរាំរ៉ែក ហើយ យាយរបស់គេក៏ដូច្នេះដែរ ហើយម្តាយរបស់នាងជាស្រីតាមផ្លូវ តើបច្ចុប្បន្ននាងជាអ្វី? ជាស្រីរាំស្រាត់រ៉ក–ខេន–រ៉ូលដែលធ្វើឲ្យប្រុសៗស្រើបស្រាល។ តើកូនរបស់នាងនឹងក្លាយជាអ្វី?

ហើយអ្នកនិយាយ "តើព្រះជាម្ចាស់ធ្វើបែបនោះទេ?" ហ្នឹងហើយ។

21 ព្រះជាម្ចាស់យាងមកជួបក្មេង ដែលគ្មានវិសមភាព ជាជំនាន់ ទោះបីជាដប់បួនជំនាន់។ ហើយបើព្រះគ្រីស្ទយាងមកដើម្បីពង្រីកវា យើងនឹងនិយាយ "មួយរយជំនាន់ឬប្រាំរយជំនាន់" ហេតុអ្វីទ្រង់មានបន្ទូល"អ្នកនៅពីមុនអ្នកបានឮគេនិយាយអ្នកជំនាន់មុន 'អ្នកមិនត្រូវសម្លាប់គេ។' ខ្ញុំនិយាយ 'អ្នកណាដែលខឹងនឹង បងប្អូនដោយឥតហេតុនោះបានន័យថាសម្លាប់រួចហើយ។' អ្នកធ្លាប់ឮគេនិយាយ ពីមុនមកថា 'អ្នកមិនត្រូវធ្វើការកំផិតឡើយ' ប៉ុន្តែខ្ញុំនិយាយវិញថា អ្នកដែលសម្លឹង មើលស្ត្រីដោយមានចិត្ត សម្រើបជាមួយនាងនោះបានធ្វើការកំផិតហើយ។" ទ្រង់បានធ្វើ

វា...អ្វីជា*ការពង្រីក*? "មានន័យថាធ្វើឲ្យវាបានធំជាងមុនច្រើនដង។" បើនៅក្រោមក្រិតវិន័យមានដប់បួនដំណាតើយូប៉ុណ្ណាដែលត្រូវមានដូចគ្នានៅថ្ងៃ នេះ?

22 បុរសក្មេង និងបុរសវ័យ–កណ្តាល និង បុរសរៀបការហើយមិនមានការគោរពដល់ការស្បថក្នុងអាពាហ៍ពិពាហ៍ទៀតឡើយ។ ហេតុអ្វី ពួកគេយកស្ត្រីមក និង រស់នៅជាមួយពួកគេកន្លែងណាក៏បាន និង ដូចជាឆ្កែធម្មតាដែរ។ ឆ្កែមានការគោរពជាង និង មានសីលធម៌ជាងមនុស្សខ្លះទៀតផង។ ហើយ ខ្ញុំដឹងថានោះជារឿងធំណាស់ ប៉ុន្តែវាត្រូវ។

23 ហេតុអ្វី? ហើយក្រុមជំនុំ បានស្របតាមនឹង មិននិយាយអ្វីពីវាឡើយ។ ហេតុអ្វី? ពួកគេធ្វើតាមតែអ្វីដែលម្តាយគេធ្វើ។ ក្រុមជំនុំទទួលវាជាមរតក។ ព្រោះក្រុមជំនុំ និងព្រះវិហារកាតូលិកដែលចេញពីក្រុមជំនុំកាតូលិក បាបរបស់ព្រះវិហារកាតូលិកនឹងចូលទៅក្នុងប្រូតេស្តង់។ ជាការពិត វាដូច្នេះ យ៉ាងនេះឆ្នាំងមិនអាចហៅ កំសៀវថា "ស្មោកគ្រោក" ទេ។ វាជាការពិត។

24 ឥឡូវ យើងឃើញ និង នៅក្នុងខគម្ពីរ យើងរកឃើញ...ហើយខ្ញុំមិនដែលឃើញការកត់ចំណាំលើតុទីនេះនៅយប់នេះទេ។ ខ្ញុំនិយាយ "បង្ហាញខ្ញុំកន្លែងណាមួយដែលព្រះតាំងក្រុមនិកាយ។ បង្ហាញខ្ញុំកន្លែងណាមួយ ដែលព្រះតាំងស្ត្រីឲ្យអធិប្បាយ។ បង្ហាញខ្ញុំកន្លែងណាមួយដែលព្រះទាំងការប្រស់ទឹក។ បង្ហាញខ្ញុំកន្លែងណាមួយព្រះតាំងការប្រោះទឹក។ បង្ហាញខ្ញុំកន្លែងណាមួយដែលព្រះបានឲ្យនរណាម្នាក់ជ្រមុជទឹកក្នុងព្រះនាម 'ព្រះបិតា ព្រះបុត្រា និង ព្រះវិញ្ញាណបរិសុទ្ធ។' រកទាំងអស់នោះមក។" ហើយយើងនៅតែធ្វើវាជានិច្ច។ វាត្រូវបានកត់ត្រាទុកក្នុងក្រុមជំនុំ។

25 ឥឡូវ ខ្ញុំនិយាយ "ចំពោះហេតុផលរបស់អ្នក យើងមិនអាចជ្រមុជទឹកបានឡើយ ព្រោះយើងជឿក្នុងការជ្រមុជដោយព្រះនាមព្រះអម្ចាស់យេស៊ូវគ្រីស្ទ។ គ្មាននរណាម្នាក់នៅក្នុងព្រះគម្ពីរធ្លាប់ ជ្រមុជទឹកដោយរបៀបណាផ្សេងទៀតឡើយ។ អ្នកបង្ហាញខ្ញុំកន្លែងមួយដែលនរណាម្នាក់បានជ្រមុជទឹកដោយព្រះនាម 'ព្រះបិតា ព្រះរាជបុត្រា ព្រះវិញ្ញាណបរិសុទ្ធ' ខ្ញុំនឹងលើកដៃហើយនិយាយថាខ្ញុំជាព្យាការីក្លែងក្លាយ។"

26 "ហើយប្រសិនបើព្រះគម្ពីរចែងថាអ្នកត្រូវតែ 'ទទួលពិធីជ្រមុជទឹកក្នុងព្រះនាមព្រះយេស៊ូវគ្រីស្ទ' មានន័យថាអ្នកត្រូវតែ ធ្វើតាមរបៀបនោះ។ លោកប៉ុល បាន

បង្គាប់ឱ្យគេធ្វើពិធីជ្រមុជទឹក។ ទោះបីជាគេបានជ្រមុជយ៉ាងណាក៏ដោយ គឺគេត្រូវទទួលពិធីជ្រមុជម្តងទៀត។ ពួកគេត្រូវជ្រមុជដូចគ្នាទៅ នឹងម្នាក់ដែលបានជ្រមុជឱ្យព្រះយេស៊ូវគ្រីស្ទ គឺលោកយ៉ូហានបាទីស្ត។ គាត់មានប្រសាសន៍ថា 'ការនេះមិនមានទៀតឡើយ អ្នកត្រូវតែមក ធ្វើពិធីជ្រមុជម្តងទៀត។' ហើយគឺគេត្រូវធ្វើវាមុននឹងគេទទួលព្រះវិញ្ញាណដ៏វិសុទ្ធ។ វាគឺជាកម្មវិធីរបស់ព្រះជាម្ចាស់។"

27 ខ្ញុំប្រហែល ជានិយាយជ្រៅជាងនេះ យប់នេះ។ ហេតុអ្វី? ព្រះយេស៊ូវ រក្សាពាក្យរបស់ព្រះអង្គ។ តើអ្នកជឿទេថាដូច្នេះ? ឥឡូវនេះជាពេលល្អណាស់ដែលអ្នកនៅទីនេះ នៅវេលាព្រឹកនេះ ប៉ុន្តែខ្ញុំចង់បញ្ជាក់បន្ថែមបន្តិចទៀត។

28 ហេតុអ្វីបានជាលោកប៉ុល...លើកឡើងពីការនេះ បន្ទាប់ពីការនេះបានបញ្ចប់រួចហើយ? "ទោះបីជាទេវតាមកពីស្ថានសួគ៌បានមក និង អធិប្បាយពីអ្វីផ្សេងៗទៀត ចូរឱ្យពួកគេ វិនាសចុះ។"

29 ឥឡូវនេះអ្នកបាននិយាយថា "យើងមានពន្លឺថ្មីហើយ។" ទេអ្នកមិនមែនទេ។ នេះជាអ្វីដែលវិញ្ញាណអាក្រក់មកនិយាយជាមួយ អេវ៉ា ជាមួយនឹងពន្លឺថ្មី។ អ្នកមិនត្រូវការពន្លឺថ្មីទេ។ គឺអ្នកត្រូវដើរក្នុងពន្លឺដែលព្រះជាម្ចាស់បានរៀបចំរួចហើយគឺ ទាំងអស់នេះហើយ។

30 ឥឡូវនេះសូមមើលការនេះ គឺសាមញ្ញទេ។ នៅពេលដែលចុះពីលើភ្នំនៃ ការផ្លាស់ប្រែរិញនោះ ព្រះយេស៊ូវមានព្រះបន្ទូលទៅកាន់សិស្សព្រះអង្គថា "តើមនុស្សនិយាយថាបុត្រមនុស្សជានរណា?"

"ម្នាក់និយាយថា លោកជា 'ម៉ូសេ ឬ អេលីសេ ម្នាក់ទៀតនិយាយថា ជាម្នាក់ក្នុងចំណោមព្យាការី។'"

ទ្រង់សួរថា "តើអ្នកគិតថាខ្ញុំជានរណា?"

31 គាត់និយាយ លោកពេត្រុសបាននិយាយថា "ទ្រង់ជាព្រះគ្រីស្ទជាព្រះបុត្រារបស់ព្រះដ៏រស់។"

32 ព្រះអង្គមានព្រះបន្ទូលថា "មានពរហើយស៊ីម៉ូនជាកូនរបស់យ៉ូណាស សាច់ និង ឈាមមិនបានបើកសម្តែងការនេះដល់អ្នកឡើយ។" ឃើញទេ វាមិនមែនមកតាម សិក្ខាសាលាទេ។ វាក៏មិនមែនមកតាមនិកាយដែរ។ "សាច់ និង ឈាមមិនបានបើកសម្តែងការនេះដល់អ្នកឡើយ។ អ្នកក៏មិនអាច រៀនវាតាមរយៈសាលា

នៃទេវវិទ្យាណាឡើយ។ ប៉ុន្តែព្រះបិតារបស់ខ្ញុំដែលគង់នៅស្ថានសួគ៌ បាន បើក សម្តែងឲ្យអ្នកឃើញ។ ហើយនៅលើថ្មដានេះខ្ញុំនឹងសង់ក្រុមជំនុំរបស់ខ្ញុំ ទ្វានៃស្ថាននរកមិនអាច ប្រឆាំងទាស់នឹងវាឡើយ″ វិញ្ញាណបានបើកសម្តែងពីទ្រង់ជាអ្នកណា។

33 កត់សម្គាល់ "ហើយខ្ញុំនិយាយជាមួយអ្នកពេត្រុស។ ហើយខ្ញុំនឹងឲ្យកូនសោនគរដល់អ្នក។ ហើយអ្វីដែលអ្នកចងលើផែនដី ខ្ញុំនឹងចងនៅស្ថានសួគ៌ដែរ អ្វីដែកអ្នកស្រាយនៅលើផែនដី ខ្ញុំនឹងស្រាយនៅស្ថានសួគ៌ដែរ។″ ឥឡូវទ្រង់ត្រូវតែរក្សាព្រះបន្ទូលរបស់ទ្រង់ បើមិនដូច្នោះទ្រង់មិនមែនជាព្រះឡើយ។ ឥឡូវពេលទ្រង់ធ្វើដូច្នោះ ពីរបីថ្ងៃក្រោយមក ទ្រង់ត្រូវបានគេឆ្កាង រស់ឡើងវិញ និង ត្រូវលើកទៅស្ថានសួគ៌ ហើយ ពេត្រុសបើកការផ្សាយដំណឹងល្អនៅថ្ងៃពេនទីកុស្ត។ តើគាត់បានធ្វើទេ? គាត់ ពិតណាស់ គាត់បានធ្វើ។ ឥឡូវ សង្កេត ពេលគាត់...

34 ពួកគេទាំងអស់គ្នាចំអកពួកគេ ព្រោះពួកគេពេញដោយព្រះវិញ្ញាណ។ ពួកគេត្រូវបានគេហៅថា "អ្នកជឿស័ប់ ហូលីរ៉ុលឡឺ″ ឬជាឈ្មោះអ្វីមួយប្រភេទ បែបនោះ។ ហើយពួកគេទាំងសើច និង និយាយ "អ្នកទាំងនេះពេញដោយស្រាថ្មី។″

35 ហើយពេត្រុសឈរឡើងក្នុងចំណោមពួកគេ លើកសម្លេងឡើង ហើយគាត់និយាយថា "អ្នកទាំងអស់គ្នាជាបងប្អូនអើយ សូមស្តាប់ខ្ញុំ។ ស្តាប់ពាក្យខ្ញុំ និង ស្តាប់ខ្ញុំ។ អ្នកទាំងនេះមិនមែនស្រវឹងដូចអ្នកគិតនោះឡើយ នេះទើបតែម៉ោងទីបីនៃថ្ងៃប៉ុណ្ណោះ។ ប៉ុន្តែនេះជាអ្វីដែលត្រូវបាននិយាយដោយហោរ៉ាយ៉ូអែល 'ហើយ វានឹងមកដល់នូវថ្ងៃចុងក្រោយ យើងនឹងចាក់វិញ្ញាណយើង′ ហើយអ្វីដែលទ្រង់នឹងធ្វើលើបុត្រានិងបុត្រីរបស់ទ្រង់ និង អ្នកបម្រើស្រី និង អ្នកផ្សេងទៀត នៅថ្ងៃនោះ។″

36 ហើយ ពេលពួកគេចាប់ផ្តើមឮរឿងនេះ ពួកគេត្រូវបានចាក់ចូលក្នុងចិត្ត។ ព្រោះ ពួកគេបានស្តាប់ឮមនុស្សម្នាក់ដែល មិនដឹង អេប៊ីស៊ី ប៉ុន្តែពួកគេត្រូវតែចាំសម្គាល់គាត់ ដឹងថាគាត់មានអ្វីនៅ ខាងក្នុងកំពុងបញ្ចេះគាត់ជាព្រះវិញ្ញាណបរិសុទ្ធ។ បញ្ឈប់គាត់? ហេតុអ្វី វាហាក់ដូចជាការព្យាយាមដាក់ភ្លើង លើអាគារស្ងួត នៅពេលមានខ្យល់។ អ្នកមិនអាចធ្វើបានឡើយ។ គាត់ត្រូវបានបំពេញដោយព្រះវិញ្ញាណបរិសុទ្ធ។ ហើយតើគាត់ធ្វើអ្វី ឥឡូវ?

37 ពួកគេនិយាយ "ល្អមនុស្សទាំងឡាយ និងបងប្អូន តើយើងអាចធ្វើអ្វីដើម្បីបានសង្គ្រោះ?″

38 ឥឡូវ សូមសង្កេតមើល ពេត្រុសអ្នកមានកូនសោនៃនគរស្ថានសួគ៌។ ឃើញ?

39 ឥឡូវ ពេលព្រះយេស៊ូវរស់ឡើងវិញនៅថ្ងៃទីបី ទ្រង់មិនទាន់មានកូនសោរនៃនគរស្ថានសួគ៌ឡើយ។ តើអ្នកដឹងទេ? ទ្រង់មានបន្ទូល "ខ្ញុំមានកូនសោនៃសេចក្តីស្លាប់ និង ស្ថាននរក" ប៉ុន្តែមិនមែនទៅនគរស្ថានសួគ៌ទេ ព្រោះពួកគេបានប្រគល់ឲ្យពេត្រុសហើយ។

40 ឥឡូវ ទ្រង់មានបន្ទូល "អ្វីដែលអ្នកស្រាយនៅផែនដី ខ្ញុំនឹងស្រាយនៅស្ថានសួគ៌។ អ្វីអ្នកចងនៅផែនដី ខ្ញុំនឹងចងនៅស្ថានសួគ៌ដែរ។"

41 ឥឡូវ គាត់ឈរនៅទីនេះជាមួយកូនសោ ដើម្បីបើកអ្វីដែលជាព្រះពរដល់ផែនដី។ ហើយនៅទីនេះគាត់មានកូនសោក្នុងដៃ។ ហើយពួកគេសួ "តើយើងអាចធ្វើអ្វីដើម្បីបានការសង្គ្រោះ?" ឥឡូវមិនថាពួកសាវកនិយាយឲ្យធ្វើអ្វីនោះទេ ព្រះជាម្ចាស់ត្រូវរៀបចំការនោះនៅស្ថានសួគ៌ ព្រោះទ្រង់ប្រទានអំណាចឲ្យគាត់។

42 ឥឡូវ ពេត្រុសនិយាយ "ចូរឲ្យ អ្នករាល់គ្នាម្នាក់ៗ ប្រែចិត្ត និងទទួលការជ្រមុជទឹកដោយព្រះនាមព្រះយេស៊ូវគ្រីស្ទ សម្រាប់ការលាង បាបរបស់អ្នកហើយអ្នកនឹងទទួលបានអំណោយទាននៃព្រះវិញ្ញាណបរិសុទ្ធ។" តើនោះត្រូវទេ? ហើយនោះជាហេតុផល កូនសោត្រលប់ទៅស្ថានសួគ៌ ដោយឈ្មោះណាមួយ ផ្លូវណាផ្សេងទៀត មានទម្រង់—ទម្រង់ផ្សេង។ បើវាត្រលប់ មកផែនដី និង ត្រលប់ទៅស្ថានសួគ៌ បើមិនដូច្នោះព្រះយេស៊ូវមិនបានរក្សាព្រះបន្ទូលជាមួយពេត្រុសឡើយ។ ហើយគ្រប់ កន្លែងនៅក្នុងព្រះគម្ពីរដែលពួកគេជ្រមុជទឹក បន្ទាប់ពីនោះ ពួកគេជ្រមុជទឹកក្នុង ព្រះនាមព្រះយេស៊ូវគ្រីស្ទ។ ហើយបើអ្នកណាជ្រមុជទឹកពីមុននោះត្រូវមកជ្រមុជ ម្តងទៀត ក្នុងព្រះនាមព្រះយេស៊ូវគ្រីស្ទ ដើម្បីទទួលព្រះវិញ្ញាណបរិសុទ្ធ។ នោះជាការត្រឹមត្រូវ។ វានៅតែដំណើរការដដែល។

43 ដូច្នេះ បើយើងបង្រៀនការជ្រមុជទឹកក្នុងព្រះនាម "ព្រះវរបិតា ព្រះបុត្រា និង ព្រះវិញ្ញាណបរិសុទ្ធ" ថាវាជាការថ្លែងទំនាយខុស។ ឥឡូវ ខ្ញុំមិនចង់ធ្វើឲ្យអ្នកឈឺចាប់ទេ ប៉ុន្តែខ្ញុំត្រូវតែសន្ទតពីរឿងនេះ ដើម្បីឲ្យក្រុមជំនុំនឹងឃើញថាជាអ្វី។ យើងមិនមែននៅទីនេះ ជាក្រុមល្ងង់ខ្លៅអវិជ្ជានោះទេ យើងដឹងថាយើងឈរលើព្រះបន្ទូលរបស់ព្រះ។ ឃើញយើងដឹង។ ខ្ញុំជម្រុញឲ្យនរណាម្នាក់បង្ហាញខ្ញុំកន្លែងណាមួយដែលមានអ្នកជ្រមុជទឹកដោយដោយព្រះនាម "ព្រះវរបិតា

ព្រះរាជបុត្រា និង ព្រះវិញ្ញាណបរិសុទ្ធ" ឥឡូវអ្នកកំពុងតែស្ដាប់ការថ្លែងទំនាយខុស ឬ ការពិត? ស្វែងរកក្នុងខគម្ពីរវាស្រេចតែអ្នក។

44 បង្ហាញខ្ញុំកន្លែងណាមួយដែលនរណាម្នាក់នៅក្នុងព្រះគម្ពីរ ដែលក្រុមជំនុំធ្លាប់តាំងជានិកាយ ក្នុង—ក្នុងព្រះគម្ពីរ។ បង្ហាញខ្ញុំនៅក្នុងព្រះគម្ពីរកន្លែងណាដែលតាំងអ្នកអធិសប្បាយស្ត្រីភេទ។ បង្ហាញខ្ញុំមកថាក្នុងព្រះគម្ពីរកន្លែងណាដែលមានរឿងទាំងនេះ ដែលកំពុងតែនិយាយនេះ ធ្លាប់បានត្រូវគេតាំងឡើងក្នុងព្រះគម្ពីរ។ ពួកវាមិនអញ្ចឹងទេ។ ប្រាប់ខ្ញុំកន្លែងណាមួយ។ អ្នកក្លាយជានិកាយ...

45 ល្អ ពេលដែលមេតូឌីស្ត ងើបឡើង ពួកគេអធិប្បាយ ការប្រោសឲ្យបានវិសុទ្ធ។ នោះជាការល្អ។ ប៉ុន្តែពេលពួកគេធ្វើដូច្នោះ ពួកគេបានដាក់ឈ្មោះនិកាយ និងតាំងវាឡើង។ ហើយជាហេតុផលដែលព្រះគម្ពីរនិយាយថា"អ្នកមានឈ្មោះ។"

អ្នកនិយាយថា "ខ្ញុំជាគ្រីស្ទាន។"

"ល្អ និកាយមួយណាដែលអ្នកធ្វើជាសមាជិក?"

46 អ្នក និយាយ "មេតូឌីស្ត" ហេតុអ្វី អ្នកធ្វើពេស្យាចារដូច្នេះ។ "ខ្ញុំជាបាបទីស្ត" ធ្វើពេស្យាចារ។ "ពេនទីកុស្ត" អ្នកធ្វើពេស្យាចា។ អ្នកជាកម្មសិទ្ធក្រុមជំនុំនោះ។

47 អ្នកត្រូវតែជាកម្មសិទ្ធរបស់ព្រះគ្រីស្ទ។ មិនមានកិច្ចការអ្វីត្រូវនិយាយ "មេតូឌីស្ត" "បាបទីស្ត។" បើអ្នកជាគ្រីស្ទបរិស័ទ អ្នកជាគ្រីស្ទបរិស័ទក្នុងចិត្ត។

48 គ្រប់ទាំងនិកាយទាំងនោះអាចបង្កើតកូនបាន ជាកូនរបស់ព្រះជាម្ចាស់ នោះត្រឹមត្រូវ។ ប៉ុន្តែបើអ្នកគិតថាអ្នកអាចទៅស្ថានសួគ៌ដោយព្រោះអ្នកជាមេតូឌីស្ត ឬ បាបទីស្ត អ្នកខុសហើយ។ ហើយ នោះជាហេតុផលដែលយើងនៅក្រៅចំនុចនោះ។

ហេតុអ្វីបានជាអ្នកបាបទីស្តមិនអាចមើលឃើញ?

49 ខ្ញុំសួរអ្នកមេតូឌីស្តនៅទីនេះ សរសេរសារណាមួយ បានសរសេជាយូមកហើយ។ គាត់និយាយថា "រឿងមួយដែលយើងប្រឆាំងនឹងអ្នក គឺអ្នកដើរតាមរបៀបពេនទីកុស្ត។"

ខ្ញុំនិយាយ "នរណាជា 'យើង'?"

"យើង ជាមេតូឌីស្ត។"

50 ខ្ញុំនិយាយ "ល្អ ខ្ញុំនឹងប្រាប់អ្នកអ្វីដែលខ្ញុំនឹងធ្វើ។ ខ្ញុំមកក្រុងរបស់អ្នកហើយ ឲ្យមេតូឌីស្តជួយគាំទ្រវា។"

"អូ" និយាយ "ពិតណាស់ យើងមិនធ្វើបែបនោះទ្បើយ។"

51 ខ្ញុំនិយាយ "នោះគ្រាន់តែជាអ្វីខ្ញុំគិត។ ខ្ញុំនៅជាមួយពេនតីកុស្ត ព្រោះអ្នកពេនទីកុស្តជឿវា។ នោះគឺត្រឹមត្រូវ។ ពួកគេប្រមូលគ្នាជុំវិញរឿងនោះ។ ពួកគេជាអ្នកដែលចូលទៅជិតអត្ថប្រយោជន៍នៃរឿងនោះ។"

52 តើមានប៉ុន្មាននាក់ដែលអានអត្ថបទក្នុងទស្សនាវដ្តី *ជីវិត* នាពេលថ្មីៗនេះអំពីក្រុមជំនុំពេនទីកុស្ត? វាជាអព្ភូតហេតុដ៏ធំនៅសម័យកាលនេះ។ ពួកគេមានអ្នកជឿថ្មីក្នុងឆ្នាំនេះ ច្រើនជាងក្រុមជំនុំផ្សេងទៀតដែលដាក់ជាមួយគ្នា។ ហេតុអ្វី? ទោះបីនៅមានកំហុសរបស់ពួកគេក៏ដោយ ព្រះជាម្ចាស់កំពុងធ្វើ សកម្មភាពដល់គេ ព្រោះគេជឿលើសេចក្តីពិតហើយធ្វើដំណើរតាមនោះ។ វាជាសេចក្តីពិត។

53 ប៉ុន្តែយើងកំពុងធ្វើអ្វីឥឡូវនេះ? ឃើញ? នោះជាហេតុផលដែលយើងមិនធ្វើជានិកាយ។ ហើយជាក់ច្បាស់ដូចជាពេនទីកុស្តដែលគេកំណត់ឈ្មោះ...

54 ហើយពេលត្រលប់ទៅត្រើយនាយ ពេលដែលព្រះវិញ្ញាណបរិសុទ្ធបានចាក់លើក្រុមជំនុំពេនទីកុស្ត កាលពីសែសិបឆ្នាំមុន ហើយពួកគេចាប់ផ្តើមនិយាយជាភាសាដទៃ ជាអំណោយទានមួយបែប។ ជាអំណោយទានតូចបំផុត។ ជាអំណោយទានតូចជាងគេបំផុត តាមរយៈប៉ុលប្រាប់ គឺការនិយាយភាសាដទៃ។ ហើយ ពេលវាចាក់ចុះមក "អូ" ពួកគេនិយាយ "យើងទទួលបានហើយ" និង ពួកគេក៏បង្កើតនិកាយ ក្រុមប្រឹក្សាផ្លូវការ ដែលឥឡូវត្រូវជា Assemblies of God។ "អូ គ្មាននរណាម្នាក់ទទួលបានទេ ទាល់តែអ្នកនិយាយភាសាដទៃ" ហើយព្រះជាម្ចាស់ក៏ធ្វើសកម្មភាពចាកចេញពីគេ និង ទុកចោលនៅទីនោះ។ ពិតណាស់។ បាទ លោក។

55 ក្រោយមកមានភាពតែមួយ(Oneness) ក៏ឃើញមានការជ្រមុជទឹកក្នុងព្រះនាមព្រះយេស៊ូវ។ ពួកគេនិយាយៗ "អូ យើងទទួលបាន" ពួកគេរៀបចំ។ តើពួកគេធ្វើអ្វី? ព្រះជាម្ចាស់បានយាងចេញ ហើយទុកឲ្យគេនៅទីនោះ។

វាសម្រាប់ "អ្នកណា នឹងចង់បាន ចូរឲ្យគាត់មក។"

56 ឃើញទេ ភាពតែមួយ(Oneness) មិនអាចចូលក្នុងសន្និបាទ(Assemblies) ឡើយ។ សន្និបាត(Assemblies)ក៏មិនអាចចូលទៅកាន់ភាពតែមួយ(Oneness) ដែរ។ ខ្ញុំនឹងនិយាយពីមនុស្សល្អៗរបស់ពួកគេ លោក ហ្គូស និង ដុកទ័រ ប៉ូប និង អ្នកជាច្រើនទៀត។ មនុស្សជាអ្នកអស្ចារ្យក្នុង...ខ្ញុំអង្គុយជាមួយគេ។ ខ្ញុំនិយាយ"តើអ្នកបង្រៀនភស្តុតាងដើម ដូចជាអ្នកប្រាជ្ញដោយរបៀបណា?"

57 "ល្អ" និយាយ "បងប្អូនប្រុសប្រាណហាំ" មួយ ពីរ ឬ បី នៃចំណោមគេ ពិតជាស្មោះត្រង់ណាស់ និយាយ "យើងដឹងថាវាខុស ប៉ុន្តែយើងអាចធ្វើអ្វីបាន? បើយើងនិយាយអ្វីពីវាឥឡូវ ហេតុអ្វី វានឹងចូលកាត់កម្មវិធីទាំងមូល" ពិតណាស់ និង អ្នកនឹងមិនធ្វើជាចាស់ទុំទៀតឡើយ ឬអ្នកមើលការទូទៅ។ នោះជាគំនិត។

58 បងប្អូនប្រុស ខ្ញុំចង់ធ្វើកិច្ចការតូចមួយនៅចន្លោះពេលបន្តិច ឬ អធិប្បាយក្រោមដើមស្រល់ ហើយមានសេចក្តីពិត ពិតណាស់ និង ដឹងថាអ្នកកំពុងប្រាប់ពីសេចក្តីពិត។ មនុស្សត្រូវការសេចក្តីពិត។ ហើយ អ្នកក៏ត្រូវធ្វើតាមភារកិច្ចនោះដែរ ភាពជាគ្រីស្ទបរិស័ទ ដើម្បីស្ពាយចេញទៅនូវការកត់ត្រាពីសេចក្តីពិត។ ព្រះជាម្ចាស់នឹងប្រកាន់យកចំពោះទំនួលខុសត្រូវរបស់អ្នក។

59 បន្ទាប់មកលើការទាំងអស់នេះ បើអ្នកមិនបានជ្រមុជទឹក ក្នុងព្រះនាមព្រះ យេស៊ូវគ្រីស្ទ ហើយអ្នកមិនបានធ្វើការទាំងនេះ ហើយអ្នកមិនបានទទួលព្រះវិញ្ញាណបរិសុទ្ធ...

60 អ្នកនិយាយ "អូ ខ្ញុំនិយាយជាភាសាដទៃ" មិនមែនមានន័យថាអ្នកមានព្រះវិញ្ញាណបរិសុទ្ធឡើយ។

61 ខ្ញុំបានឃើញមេធ្មប់ អ្នកមន្តអាគម អារក្ខ និង អ្វីផ្សេងៗទៀត និយាយភាសាដទៃ និយាយភាសាដទៃ។ ជាការពិតណាស់។ ពួកគេមិនមានព្រះវិញ្ញាណបរិសុទ្ធឡើយ ហើយអ្នកដឹងពីការនោះ។ ផឹកឈាមពីឆ្អឹងលលាដ៍មនុស្ស និងហៅអារក្ខ ហើយនិយាយជាភាសារដទៃ។ ពួកគេមិនមានព្រះវិញ្ញាណបរិសុទ្ធឡើយ។

62 ដូច្នេះ ព្រោះអ្នកនិយាយភាសា នោះមិនមានន័យថាអ្នកមានវាទេ។ មានវិធីតែមួយដែលអ្នកអាចដឹងបានថាអ្នកមាន ពេលដែលវិញ្ញាណរបស់អ្នកថតយកមកនូវវិញ្ញាណរបស់ទ្រង់ និង ផលផ្លែនៃព្រះវិញ្ញាណដែលតាមអ្នក: សេចក្តីស្រឡាញ់ ជំនឿ អំណរ សេចក្តីសុខសាន្ត អត់ធ្មត់ សេចក្តីល្អ សុភាព សំឡូត។ នោះជាអ្វីពេលអ្នកមានព្រះវិញ្ញាណបរិសុទ្ធ។ វានឹងកត់ត្រាពីរឿងនោះផ្ទាល់។

63 ឥឡូវ ពេលអ្នកព្យាយាមផ្អែកលើ ព្រោះអ្នកជាសមាជិកក្រុមជំនុំព្រះជាម្ចាស់ ឬបាបទីស្ត ឬព្រីសប៊ីធីរៀន អ្នកនឹងឃើញថាអ្នកកំពុងធ្វើអ្វី? អ្នកកំពុងយកឈ្មោះជាពេស្យាចារ។ នោះជាការពិត។ ចូរចេញពីរឿងនោះ។ នៅឲ្យឆ្ងាយពីវា ខ្ញុំមិនមានន័យថាឲ្យអ្នកចេញពីក្រុមជំនុំ ឬ អ្វីទៀតឡើយ អ្នកធ្វើអ្វីដែលអ្នកចង់។ ប៉ុន្តែកុំឲ្យដេកដួលនៅឡើយ "អូ ខ្ញុំជាព្រីសប៊ីធីរៀនយើងមិនជឿសម័យកាលការអស្ចារ្យ" ហេតុអ្វីអ្នកមិនជឿ? ព្រះគម្ពីរបានបង្រៀន។ "អូ ខ្ញុំជាសមាជិកព្រះវិហារព្រះគ្រីស្ទ។ គេនិយាយថាសម័យការអស្ចារ្យវាផុតបាត់ទៅហើយ" ពួកគេជាព្យាការីក្លែងក្លាយ។

64 ខ្ញុំអាចបង្ហាញអ្នកកន្លែងដែលព្រះគ្រីស្ទប្រទានចេស្ដាដល់ក្រុមជំនុំ ដើម្បីព្យាបាលជម្ងឺ ប្រោសអ្នកស្លាប់ឲ្យរស់វិញ និង ដេញអារក្ស។ ខ្ញុំចង់ដេញដោលអ្នកដែលបង្ហាញខ្ញុំពីខគម្ពីរកន្លែង ដែលទ្រង់ដកវាចេញពីក្រុមជំនុំ។ អ្វីដែលយកវាចេញ? សាសនារបស់អ្នក ត្រូវទេ មិនមែនជាព្រះបន្ទូលព្រះឡើយ។ ព្រះវិញ្ញាណបរិសុទ្ធនៅតែធ្វើឲ្យការងារបានសម្រេច បន្តដូចគ្នា និង ទ្រង់នៅតជារៀងរហូត។

65 នោះជាហេតុផល យើងមិនមែនជា និកាយ "មានទម្រង់ជាសេចក្ដីល្អ តែបដិសេធអំណាចព្រះជាម្ចាស់ ចូរចេញពីរបៀបនោះ" យើងមិនជឿរបៀបនោះទេ។

66 ឥឡូវ តើវាចាប់ផ្ដើមរបៀបណា? យើងត្រូវតែប្រញាប់ និង ធ្វើវាឲ្យរហ័សតាមតែអាចធ្វើទៅបាន របៀបវាចាប់ផ្ដើមដំបូង។ តើយើងមានខគម្ពីរគ្រប់គ្រាន់សរសេរពីព្រះវិញ្ញាណបរិសុទ្ធទេ។

67 ហើយអ្វីមួយផ្សេងទៀត យើងមានការជម្រុញកាលពីយប់មិញ ពី "ការស៊ូទ្រាំរបស់ពួកបរិសុទ្ធ" មិនមែនតាមរបៀបអ្នកបាបទីស្ដជឿឡើយ។ ទេ លោក។ ខ្ញុំជឿជាក់ថាមានភាពខុសគ្នារវាងបាបទីស្ដ និង គំនិតរបស់ពួកគេ ទ្រឹស្ដីនៃកាលវិននីស្តរបស់ពួកគេ។ ខ្ញុំពិតជាមិនយល់ស្របតាមអ្នកព្រីសប៊ីធីរៀនឡើយ។ ខ្ញុំក៏មិនយល់ស្របតាមមេតូឌីស្ដលើរបៀបរបស់គេនៃលទ្ធិអាមីនៀន។ បាទ លោក។ ប៉ុន្តែពួកគេមានទាំងសេចក្ដីពិត ប៉ុន្តែអ្នកត្រូវតែនាំមក*ទីនេះ*ដែលជាទីតាំងនៃសេចក្ដីពិត។ ពេលអ្នកធ្វើដំណើរជាមួយនោះ អ្នកនឹងធ្វើដំណើរការដោយកម្រោលជាមួយវា។ ជាការពិតណាស់។

68 បាបទីស្ដចូលមក ជ្រមុជទឹកបានពីរនាក់នៅទីនោះ ក្នុងការជ្រមុជ និង គ្រូអធិប្បាយជ្រមុជទឹកឲ្យគេ ប្រាំបួនក្នុងចំណោមដប់នាក់ជាអ្នកជក់បារី ត្រលប់

ទៅវិញ ហើយ ឈរនៅខាងក្រៅ លេងបៀ បោកប្រាស់គេពេលយប់ រត់ទៅមក និង មានមុខរបររៀចរេរ ហើយ ស្ត្រីទាំងនោះស្លៀកខ្លី ដើរនៅតាមផ្លូវកាត់សក់ខ្លី និង—និងជក់បារីនិយាយគ្នា ជប់លៀង និង និយាយរឿងកំប្លែងស្មោគគ្រោក។ ហើយអ្នកហៅថាជាគ្រីស្ទបរិស័ទ? ហើយ អ្នកគិតថាអ្នកមានសុវត្ថិភាពអស់កល្ប? អ្នកចុះនរកទាំងបែបដូច្នេះ។ អ្នកមិនបានរីករាយខ្លួននៅស្ថានសួគ៌តាម លក្ខណៈណាមួយ។ ពិតជាមិន។ នោះគឺមិនមែនជាសុវត្ថិភាពអស់កល្ប ឡើយ។

ប៉ុន្តែមានពេលដែលមនុស្សកើតជាថ្មីចេញពីព្រះវិញ្ញាណបរិសុទ្ធ...

69 ហើយអ្នកជាពេនទីកុស្ត ព្រោះអ្នកលោតចុះលោតឡើង និយាយភាសាដទៃ រត់ចុះឡើងតាមចន្លោះផ្លូវជួរកៅអី នោះមិនមានន័យថាអ្នកទទួលជីវិតអស់កល្បឡើយ។ តើអ្នកមិនដែលគិតដូច្នេះក្នុងខួក្បាលរបស់អ្នកទេ? ទេ លោក។ វាពិតជាមិនដូច្នោះ។ ព្រោះអ្នកដឹងពី—ដឹងពីជីវិតផ្ទាល់របស់អ្នកដែលអ្នកមាន កត់ទុក អ្នកមិនបានត្រឹមត្រូវជាមួយព្រះជាម្ចាស់។ នោះជាការត្រឹមត្រូវ។ អ្នកមិនបានត្រឹមត្រូវឡើយ។ នោះគឺមិនមានសុវត្ថិភាពអស់កល្បជានិច្ចឡើយ។

70 ប៉ុន្តែ ខ្ញុំចង់សួរអ្នកពីរឿងខ្លះ។ តើមានសុវត្ថិភាពអស់កល្ប? ព្រះគម្ពីរនិយាយរឿងនោះ។ ព្រះគម្ពីរនិយាយថាឈ្មោះរបស់យើងត្រូវបានកត់ត្រាក្នុងសៀវភៅជីវិតរបស់កូនចៀមមុនផែនដីនេះចាប់ផ្តើម។

71 ដូចខ្ញុំបាននិយាយកាលពីព្រឹកមិញ ខ្ញុំនិយាយវាម្តងទៀត។ មនុស្សដែលសរសេរចម្រៀង "មានឈ្មោះថ្មីដែលបានសរសេរ ដោយសិរីរុងរឿងនៅយប់នេះ វាជាឈ្មោះរបស់ខ្ញុំ" គំនិតរបស់គាត់ត្រឹមត្រូវ ប៉ុន្តែគាត់ខុសហើយ បើគិតតាមខគម្ពីរ។ ឈ្មោះរបស់អ្នកមិនត្រូវបានកត់ទុកក្នុងយប់ដែលអ្នកទទួលបានសេចក្តីសង្គ្រោះនោះឡើយ។

72 ឈ្មោះរបស់អ្នក តាមរយៈព្រះគម្ពីរ តាមរយៈគម្ពីរវិវរណៈ១៣:១៧ និងតទៀត "ត្រូវបានកត់ទុកនៅទីនោះមុនផែនដីចាប់ផ្តើមផង ហើយព្រះយេស៊ូវគ្រីស្ទត្រូវបានធ្វើគត់មុនគ្រឹះនៃផែនដីផង។"

73 តើព្រះជាម្ចាស់ដែល ជាអង្គអស់កល្ប ព្រះដ៏អស់កល្ប អាចជ្រាបពីការបញ្ចប់របស់ការចាប់ផ្តើមដំបូង តើទ្រង់អាចអនុញ្ញាតឲ្យបាបចូលក្នុងលោកកិយបាន បើវាមិនមានហេតុផល?

74 ត្រលប់ទៅពីអ្វីដែលយើងបាននិយាយ។ អ្វីជាដំបូង ព្រះសង្គ្រោះ ឬ មនុស្សបាប? [មនុស្សម្នាក់ក្នុងក្រុមជំនុំនិយាយ "ព្រះសង្គ្រោះ"–Ed] ព្រះសង្គ្រោះ ប្រាកដណាស់។ មួយណាដែលមានអំណាចជាង ព្រះសង្គ្រោះឬមនុស្សបាប? បើព្រះសង្គ្រោះអាចដោះបាបចេញ ទ្រង់មានអំណាចជាងហើយ។ ល្អ ហេតុអ្វីទ្រង់អនុញ្ញាតឲ្យបាបចូលពីដំបូង? គឺដើម្បីបង្ហាញថាទ្រង់ជាអង្គសង្គ្រោះ។ តើមួយណាមានអំនាចបំផុត អ្នកព្យាបាល ឬ ជម្ងឺ? ["អ្នកព្យាបាល"] អ្នកព្យាបាល។ ចុះហេតុអ្វីបានជាទ្រង់អនុញ្ញាតឲ្យជម្ងឺចូលមក។ ដើម្បីបង្ហាញថាទ្រង់ជាអង្គប្រោសឲ្យជា។ ខ្ញុំមានអារម្មណ៍ពីភាពជាសាសនា។ ហ្នឹងហើយ។ អូ ខ្ញុំអើយ? នោះជាលក្ខណៈរបស់ទ្រង់។

75 នោះជាហេតុផលដែលទ្រង់អនុញ្ញាតឲ្យបញ្ហាចូលមក។ នេះជាហេតុដែលទ្រង់អនុញ្ញាតឲ្យទុក្ខលំបាកចូលមក ដើម្បីបង្ហាញថាទ្រង់ជាអំណរ។ ពិតណាស់ វាដូច្នោះ។ នោះជាហេតុដែលយើងត្រូវមានយប់ ដើម្បីបង្ហាញថានេះគឺជាពេលថ្ងៃ។ ហេតុនេះ បានជាយើងមានកំហឹង ដើម្បីបង្ហាញថា មានសេចក្ដីសុខសាន្ត។ ប្រាកដណាស់ វាមានគុណសម្បត្តិ និង គុណវិបត្តិ។ អូ ទ្រង់អស្ចារ្យ។

76 ឥឡូវ តើវាចាប់ផ្ដើមដូចម្ដេច? យើងនឹងបន្តទៅវា លឿនតាមតែយើងអាចធ្វើ បាន ដូច្នេះខ្ញុំមិនទុកអ្នកឲ្យនៅពេញមួយយប់ឡើយ។ ឥឡូវ វាត្រូវតែមានការចាប់ផ្ដើមនៃគ្រប់អ្វីទាំងអស់។

77 ហើយ ខ្ញុំចង់សួរអ្នកមួយ។ ឥឡូវអ្នកប្រហែល...ញាត់របស់នេះចូលហោប៉ៅរបស់អ្នក។ អ្នកមិនចាំបាច់ដាក់វានៅក្នុងចានរហូតទេ។ ប៉ុន្តែសូមស្ដាប់រឿងនេះ។

78 បើសិនជាអ្នកជាស្នាដៃបង្កើតដ៏អស់កល្ប ដូច្នេះអ្នកមិនមាន ចំណាប់ផ្ដើមឡើយ ហើយក៏ មិនអាច មានទីបញ្ចប់ដែរ។ ព្រោះ *អស់កល្ប* មកពីពាក្យ "គ្មានដើម គ្មានបញ្ចប់។"

79 តើអ្នកមិនចាំទេឬ? ខ្ញុំនិយាយ នៅព្រឹកនេះ ពីរបៀបដែលសង្ឃមិលគីស្សាដែក ពេលគាត់ជួបអាប្រាហាំដែលត្រលប់មកពីសម្លាប់ស្ដេច។ ហើយព្រះគម្ពីរបាននិយាយហេព្រើ៧ថា—ថា"លេវីបានថ្វាយដង្វាយដប់ភាគរយដល់ មិលគីស្សា ដែក ពេលគាត់នៅក្នុងពូជពង្សរបស់ឪពុកគាត់ អ័ប្រាហាំ។" អ័ប្រាហាំ បង្កើតអ៊ីសាក អ៊ីសាកបង្កើតយ៉ាកុប យ៉ាកុបបង្កើតលេវី។ ដែលនោះជាឪពុក ជាជីតា ជាជីតាទួត។ ហើយពេលលេវីនៅក្នុងពូជរបស់ជីតាទួតរបស់គាត់ ព្រះគម្ពីរបានផ្ដល់

តម្លៃដល់គាត់ក្នុងការដាក់តង្វាយមួយភាគដល់ម៉ិលគីស្សាដែកដែរ។ និយាយពីភាពអស់កល្ប! ខ្ញុំ ខ្ញុំ! គាត់មិនដែលនិយាយថា "គាត់ធ្វើវាជាស្រមោលគាត់ធ្វើវា។ ដោយពេញសក្តានុពល" ព្រះគម្ពីរនិយាយ "គាត់ដាក់ដង្វាយមួយភាគដប់។" អាម៉ែន។

80 បន្ទាប់មក បើយើងចេញមកពីគ្រាប់ពូជត្រឹមត្រូវ ពេលប៉ុលអធិប្បាយដំណឹងល្អ ខ្ញុំនៅទីនោះ ហើយ អ្នកនៅទីនោះ។ យើងត្រូវតែចូលចំណុចនោះ មួយភ្លែតបួមឡើងដាក់ត្រចៀក។ កត់សម្គាល់ នោះជាអ្វីដែលខគម្ពីរបានប្រកាស ដល់យើងទោះជាត្រលប់ទៅវិញក៏ដោយ។

81 សូមគិត! លេវី យ៉ាកុប ឳពុករបស់គាត់ និង អ៊ីសាក ឳពុករបស់គាត់ អាប្រាហាំ ឳពុករបស់គាត់ជីតាទួតរបស់គាត់។ ពេលលេវីនៅក្នុងពូជជីតា–ទួតរបស់គាត់ គាត់ថ្វាយតង្វាយមួយភាគដប់ដល់ស្តេចមិលគីស្សាដែក។

82 ខ្ញុំចង់សួរអ្នក។ នេះជានរណា យ៉ូប27...38 ពេលលោកនិយាយ "តើអ្នកនៅឯណាពេលយើងដាក់គ្រឹះផែនដី? ពេលតារាពេលព្រឹកច្រៀងជាមួយគ្នា ហើយបុត្រារបស់ព្រះជាម្ចាស់ ស្រែកដោយអំណរ?" តើអ្នកណាជាបុត្រារបស់ព្រះដែលស្រែកច្រៀងដោយអំណរ? ព្រះយេស៊ូវមានបន្ទូលពីរឿងនោះ ថា "ខ្ញុំមានអំណរជា មួយអ្នកតាំងពីមុនគ្រឹះផែនដីមានផង។" យើងមិនមែនជារបស់អ្វីដែលបង្កើតពេលវេលាឡើយ។ យើងជារបស់បង្កើត ភាពអស់កល្ប។

83 "គ្មាននរណាអាចមកឯខ្ញុំ លើកតែព្រះវរបិតាជាអ្នកនាំមក។ ហើយ អស់អ្នកដែលមកឯខ្ញុំ ខ្ញុំនឹងប្រទានជីវិតអស់កល្បនិងលើកគេឲ្យរស់វិញនៅថ្ងៃចុងក្រោយ។ គ្មាននរណាអាចទាញចេញពីព្រះហស្តរបស់ព្រះបិតាបានឡើយ ដែលទ្រង់បានប្រទាន គេមកដល់ខ្ញុំ។" តើអ្នកបាត់បង់បែបណា?

84 មើល អ្នកភ័យខ្លាច។ អ្នកខ្លាច។ អ្នកត្រលប់ទៅមកត្រង់នេះ។ ហើយនោះជាភស្តុតាងដ៏ល្អបំផុតមួយ ក្នុងពិភពលោក អ្នកមិនទាន់ទៅកន្លែងណានៅឡើយ។ នោះជាការពិត។ តើព្រះអាចសង្គ្រោះអ្នកយ៉ាងណា បើទ្រង់...

85 តើមនុស្សប៉ុន្មាននាក់នៅក្នុងក្រុមជំនុំនេះនឹងលើកដៃរបស់អ្នក និង ជឿថាព្រះជាម្ចាស់ជា គ្មានដែនកំណត់។? អ្នកដឹងថាពាក្យថា *គ្មានដែនកំណត់* មានន័យយ៉ាងណា? នោះគឺល្អឥតខ្ចោះ។ អស់កល្បអ្នកមិនអាច—មិនអាច ពន្យល់ ពាក្យ *គ្មានដែនកំណត់ បានទេ។*

86 តើអ្នកធ្លាប់យកកាមេរ៉ាមកកំណត់ថាគ្មានដែនកំណត់ទេ? ហេតុអ្វី វាគ្រាន់តែមានន័យបែបនោះ។ ត្រូវណាស់។ គ្មានវិធីណាផ្តោតលើវាបន្តទៀតឡើយ។

87 ល្អ នោះគឺជាព្រះ យ៉ាងនោះហើយ។ ទ្រង់គ្មានដែនកំណត់។ ហើយ បើទ្រង់គ្មានដែនកំណត់នោះមិនអាចមានសត្វស្លាបល្អិត មិនមានរុយ មិនមានចៃឆ្កែ មិនមានចៃមនុស្ស មិនមានសត្វល្អិត ឬមិនមានអ្វីទៀតធ្លាប់មានលើផែនដី ឬនឹងមានទៅថ្ងៃមុខ ប៉ុន្តែពេលព្រះជ្រាបវាមុនផែនដីកកើតរូបរាង។ មានគំនិតទស្សនៈខ្លះពីភាពគ្មានដែនកំណត់។

88 ល្អ ដូច្នេះ ព្រះជាម្ចាស់ដែលគ្មានដែនកំណត់ទ្រង់សង្គ្រោះអ្នកនៅទីនេះ ដឹងថាទ្រង់នឹងចោលអ្នកនៅសប្តាហ៍ក្រោយ ខែក្រោយ ឆ្នាំក្រោយ ហេតុអ្វី ទ្រង់យកឈ្នះគ្រប់ទាំងគោលបំណង។ ទ្រង់មិនអាចចោលអ្នកឡើយ។ "អ្នកដែលឮពាក្យខ្ញុំ និងជឿទ្រង់ដែលបញ្ជូនខ្ញុំមក នោះមានជីវិតអស់កល្ប និង មិនចូលមកក្នុងការជំនុំជម្រះឡើយប៉ុន្តែបានឆ្លងពីអស់ទាំងសេចក្តីស្លាប់មកឯជីវិតវិញ។" មិនអាចធ្វើវា។ អ្នកនឹងមិន...

89 "អ្នកណាដែលមកពីព្រះនោះ មិនធ្វើបាបឡើយព្រោះពូជរបស់ទ្រង់នៅក្នុងអ្នកនោះ ហើយ គាត់មិនអាចធ្វើបាបឡើយ។" តើគាត់អាចធ្វើបាបយ៉ាង ណា កាលបើមានតង្វាយលោះបាបសម្រាប់គាត់ហើយ?

90 តើខ្ញុំអាចឈឺយ៉ាងមិច បើខ្ញុំមានសុខភាពល្អហើយ? តើខ្ញុំអាចខ្វាក់យ៉ាងមិច បើខ្ញុំអាចមើលឃើញ? អូ ខ្ញុំ! តើខ្ញុំអាចនៅក្នុងអាគារ និង នៅក្រៅអាគារនៅពេលតែមួយម្តេចកើត? តើខ្ញុំអាចស្រវឹង និង ស្វាងពេលតែមួយម្តេចបាន? អ្នកមិនអាចធ្វើបានទេ។

91 ហើយ ពេលអ្នកត្រូវបានសង្គ្រោះ អ្នកស្ថិតនៅក្រោមការលាងកំហុស ហើយបាបអ្នកមិនត្រូវបានរាប់ថាជារបស់អ្នកឡើយ។ តើដាវីឌមិនបាននិយាយថា "មានពរហើយអស់អ្នកដែលព្រះមិនប្រកាន់បាបគេ ក៏មិនចោទប្រកាន់ទោសផង"? ព្រះជាម្ចាស់មិនបានប្រកាន់ទោសទាស់នឹងស្នាព្រះហស្តទ្រង់បង្កើតឡើយ។ នោះជាភាពមុតមាំ។ នោះមិនមានជាទឹកដោះគោដែលគេយកក្រែមចេញនោះទេ។ ប៉ុន្តែនោះជាព្រះគម្ពីរ។ ព្រះជាម្ចាស់មិនប្រកាន់ទោសដល់អ្នកសុចរិតឡើយ។

92 "ព្រះជាម្ចាស់" ដោយព្រះគុណទ្រង់ ដោយការកំណត់ទុកជាមុន "មិនសព្វព្រះទ័យឲ្យនរណាវិនាសឡើយ ប៉ុន្តែមានព្រះទ័យ ឲ្យទាំងអស់គ្នាប្រែចិត្ត

វិញ។" ប៉ុន្តែភាពគ្មានដែនកំណត់ ហើយដឹងថានរណានឹងមក និង នរណាមិនមក ទ្រង់អាចកំណត់ទុកមុននូវគ្រប់យ៉ាងដើម្បីធ្វើការតាមបំណងព្រះទ័យទ្រង់។ បើ ទ្រង់មិនបានធ្វើ ហេតុអ្វីបានជាទ្រង់អនុញ្ញាតឲ្យបាបចូលមកតាំងពីដំបូង? ពេល ទ្រង់ជាព្រះសង្គ្រោះ...បើមិនមានមនុស្សបាប ទ្រង់ក៏មិនមែនជាព្រះសង្គ្រោះដែរ ការកំណត់ ទ្រង់មុនជាអ្វី មិនអាចចេញមកបានឡើយ។

93 តើទ្រង់អាចក្លាយជា អ្នកប្រោសឲ្យជាយ៉ាងដូចម្ដេច? តើទ្រង់អាចក្លាយជា អ្នកប្រោសឲ្យជាយ៉ាងដូចម្ដេច? ព្រោះទ្រង់អនុញ្ញាតឲ្យជម្ងឺចូលមក ដែលទ្រង់អាច បង្ហាញអង្គទ្រង់ជាអ្នកប្រោសឲ្យជា។ ទ្រង់ជាអ្នកប្រោសឲ្យជា។ តើអ្នកជា...តើទ្រង់ ត្រូវបានគេស្គាល់ដូចម្ដេច? តើការកំណត់របស់ទ្រង់បានដំណើរការយ៉ាងណា? តើ ទ្រង់អាចជាអ្នកប្រោស ឲ្យជាយ៉ាងណា បើគ្មានជម្ងឺ?ទ្រង់ត្រូវតែអនុញ្ញាតឲ្យ មានជម្ងឺ។

94 គ្មានអ្វីឲ្យឆ្ងល់ឡើយ ប៉ុលនិយាយ ក្នុងរ៉ូម៨ "មនុស្សល្ងង់ នរណាអាចប្រាប់ —ជាងស្មូនពីអ្វីត្រូវធ្វើ នរណា ពេលដែលដីឥដ្ឋងើបឡើងនិយាយ 'ហេតុអ្វីអ្នកធ្វើ ខ្ញុំជាយ៉ាងនេះ?' តើទ្រង់មិនបានលើកផារ៉ោនឡើងដើម្បីគោលបំណងដូចគ្នាទេឬ ដើម្បីទ្រង់អាចនឹងបង្ហាញសិរីរុងរឿងនៅក្នុងអេស៊ីព្ទ? ទ្រង់នឹងធ្វើឲ្យរឹងទទឹងដល់ អ្នកណាដែលទ្រង់ធ្វើ និង ប្រោសជាសុចរិតអ្នកណាដែលទ្រង់នឹងធ្វើ។ មិនមែន អ្នកនោះទេដែលនឹងធ្វើ ឬ ដែលនឹងដំណើរការ ប៉ុន្តែជាព្រះដែលបង្ហាញក្ដីសប្រណី សណ្ដោសវិញ។"

95 ដូច្នេះ អ្នកគ្មានអ្វីធ្វើជាមួយវាឡើយ អ្នកគ្មានអ្វីត្រូវធ្វើជាមួយវាឡើយ។ អ្នក គ្មានអ្វីមួយត្រូវធ្វើឡើយ។ បើវាជាព្រះគុណ វាជាអំណោយទទេ នោះជាអ្វីដែល អ្នកមិនអាចធ្វើបានឡើយ។ ព្រះជាម្ចាស់ប្រទានវាដល់អ្នក ហើយ នោះជាព្រះទ័យ ព្រះជាម្ចាស់។ នោះជាអ្វីដែលព្រះជាម្ចាស់បានកំណត់ទុកជាមុនសម្រាប់អ្នក។

96 ព្រះគម្ពីរនិយាយថា យើងត្រូវបាន "កំណត់ទុកជាមុន ធ្វើជាកូនចិញ្ចឹមជា បុត្រ របស់ព្រះ មុនគ្រឹះផែនដីផង។" បន្ទាប់ ពេលព្រះជាម្ចាស់សម្លាប់ចៀម នៅក្នុង ព្រះតម្រិះទ្រង់ផ្ទាល់ មុនគ្រឹះផែនដី ដើម្បីបង្ហាញពីការសន្ទត់របស់ទ្រង់ ទ្រង់ពីមុន ជាអ្វី ពេលដែលកូនចៀមត្រូវបានសម្លាប់ យើងក៏ត្រូវបានសម្លាប់ជាមួយវាដែរ។ ពេលឈាមកូនចៀមបានចូលក្នុងព្រះទ័យទ្រង់ ត្រលប់ទៅមុនគ្រឹះផែនដី ឈ្មោះ

របស់អ្នកនិង ខ្ញុំ ត្រូវបានកត់ទុកលើសៀវភៅហើយ ទាំងអស់ស្ថិតនៅក្នុងព្រះតម្រិះទ្រង់។

97 ទ្រង់គ្មានដែនកំណត់។ បើទ្រង់មិនបានធ្វើ ហេតុអ្វីទ្រង់អនុញ្ញាតវាកើតឡើង? មួយណាដែលខ្លាំងជាង (ខ្ញុំបាននិយាយ) ជាព្រះសង្គ្រោះ ឬ អ្នកមានបាប? មួយណាមានកម្លាំងជាង? ដូច្នេះ អ្នកខ្លាំងជាងត្រូវតែអនុញ្ញាតដល់អ្នកខ្សោយជាង ហើយទ្រង់ធ្វើវាសម្រាប់សិរីរុងរឿងរបស់ទ្រង់ប៉ុណ្ណោះ។ ពេលទ្រង់បង្កើត លូស៊ីហ្វើ ទ្រង់ជ្រាបថា វានឹងក្លាយជាអារក្ខ។ ទ្រង់ត្រូវអនុញ្ញាតឲ្យមានដើម្បីបង្ហាញថាទ្រង់ជាអង្គសង្គ្រោះ ជាព្រះគ្រីស្ទ។ ទ្រង់ត្រូវអនុញ្ញាតឲ្យកើតឡើងបែបនោះ។

98 ឥឡូវ ព្រះគម្ពីរមិនបាននិយាយទេឬ ថា "គ្រប់ទាំងអស់ធ្វើការរួមគ្នាសម្រាប់អ្នកដែលស្រឡាញ់ព្រះជាម្ចាស់"? [ក្រុមជំនុំនិយាយ "អាម៉ែន"—Ed.] ដូច្នេះតើអ្នកខ្លាចអ្វី?

ចូរយើងក្រោកឡើងហើយធ្វើ<br>
ដោយចិត្ត តស៊ូ<br>
កុំឲ្យរឹងរូសដូចគោដែលគេដេញ ត្រូវតែសុំ និងអង្វរ!<br>
ហើយធ្វើជាវីរៈបុរស!

99 ខ្ញុំចូលចិត្តបែបនោះ ។ សូមក្រោកឈរ! កំណាព្យមួយដែលតែងជួយខ្ញុំពេលខ្ញុំនៅក្មេង មានបទដូចនេះ។

មានជនជាតិរ៉ូមដែលថ្លៃថ្នូរ<br>
ក្នុងសម័យចៅអធិរាជរ៉ូម<br>
ទ្រង់បានឮសម្លេងកង្កែបឃំ<br>
នៅពីមុខប្រាសាទ និយាយថា:<br>
"អូ មានសេចក្តីសុខណាស់នៅលើដើមស្រល់នោះ<br>
គ្មាននរណាអាចអង្រួនបានឡើយ។"<br>
"អូ ទេ" វីរៈបុរសនិយាយ<br>
"ខ្ញុំនឹងរកវិធី ឬ ធ្វើវាឲ្យបាន។"

100 អ្នកគឺនៅទីនោះ។ ត្រូវទេ។ បើព្រះគម្ពីរបង្រៀនថាព្រះយេស៊ូវគ្រីស្ទនៅដូចថ្ងៃម្សិលមិញ ថ្ងៃនេះ និង រៀងរហូតទៅ...វាមិនមែនជារឿងងាយស្រួលទេ

ពេលដែលខ្ញុំឈានជំហានចេញពីរោងឧបោសថថ្ងៃនេះ ហើយគ្រប់គ្នាប្រាប់ខ្ញុំថា រឿង*បែបនេះ* កើតឡើង និង រឿង*បែបនោះ* កើតឡើង។ "អ្នកអាចត្រូវបានចាត់ទុកថាជាអ្នកជឿជ្រុល ត្រូវបានគេបោះចូលទៅក្នុងគុក ហើយសមាគមន៍វិជ្ជសាស្រ្តនឹងប្រឆាំងនឹងអ្នក។" ប៉ុន្តែព្រះជាម្ចាស់មានបន្ទូលឲ្យធ្វើវា។ ព្រះគម្ពីរនិយាយថាទ្រង់គឺបែបនោះ។ ហើយឥឡូវភ្លើងនៃការបំពេញព្រះចេស្តាឆេះនៅក្នុងប្រជាជាតិក្រោមស្ថានសួគ៌។ ហេតុអ្វី? ប្រឈមនឹងវា!

តើអ្នកតស៊ូជាមួយការងារថ្ងៃនីមួយៗរបៀបណា?
តើអ្នកភ័យខ្លាចតួនាទីដែលអ្នកស្វែងរក?
តើអ្នកអាចឈរជំហរធ្វើការទៅមុខទេ?
តើអ្នកមានគំនិតនឿយហត់ និង ទទេស្អាតឬទេ? (ខ្ញុំស្អប់រឿងនោះ)
ឬអ្នកប្រឈមនឹងការងាថ្ងៃមុខ
ឬការភ័យខ្លាចកំពុងតែរត់តាមរយៈវានោះ?
បើដូច្នេះ តស៊ូនឹងអ្វីបន្ទាប់ដែលអ្នករកបាន
តាមរយៈការគិតអ្នកនឹងធ្វើវា។

101 នៅជាមួយវា។ ជាការពិត។ គោលបំណងក្នុងចិត្តអ្នក ដូចជាដានីញ៉េល។ នៅជាមួយព្រះជាម្ចាស់។

102 "តើរឿងនេះកើតឡើងនៅឯណា? តើវាកើតឡើងយ៉ាងដូចម្តេច? អ្វីដែលធ្វើឲ្យមនុស្សបង្កើតការនោះ? តើហេតុអ្វីយើងចេះតែប្រុងតែបំផ្លាញវា? បងប្អូនប្រុសប្រាណហាំ សូមពន្យល់ខ្ញុំ។ អ្វីដែលធ្វើឲ្យអ្នកគិតថារឿងទាំងមូលនេះត្រូវលុបចេញ?" វាធ្លាប់ត្រូវបានលុបចេញពីមុន(ត្រូវទេ?) នៅក្នុងការបំផ្លាញពីសម័យមុន។ ឥឡូវមានអ្វីដែលជ្រៅ។ ហើយយើងត្រៀមរួចរាល់ថានឹងអាន។

103 ឥឡូវខ្ញុំចង់ឲ្យអ្នកបើកជាមួយខ្ញុំ ទៅគម្ពីរលោកុប្បត្តិ នៅជំពូក៣។ បើអ្នកចង់ដឹងអ្វី ខ្ញុំអាចបង្ហាញអ្នកក្នុងគម្ពីរលោកុប្បត្តិដែលជាកន្លែងនៃជំនឿសាសន៍ដទៃ និង លទ្ធិផ្សេងៗ និងអ្វីផ្សេងទៀតដែលយើងមានសព្វថ្ងៃ ចាប់ផ្តើមពីលោកុប្បត្តិ។ មានមនុស្សប៉ុន្មានអ្នកដែលដឹងថា *លោកុប្បត្តិ* មានន័យថា "ការចាប់ផ្តើម"? ជាកាពិត។

104 យើងឃើញថាមានក្រុមជំនុំ កាតូលិកពីដំបូង បាប៊ីឡូន នីមរ៉ុត ជាអ្នកបង្កើត យើងឃើញវាមាននៅកណ្ដាលគម្ពីរ យើងឃើញវានៅចុងក្រោយនៃព្រះគម្ពីរ យើងឃើញ ការព្យាយាមនាំអ្នកអធិប្បាយជាស្ត្រី នៅក្នុងការចាប់ផ្ដើមនៃព្រះគម្ពីរ ដោយការថ្វាយបង្គំរូបសំណាកតូចមួយដែលចេញពីឬសគល់។ តើមានប៉ុន្មាននាក់ដែលអាន ហ៊ីសស្លប *បាប៊ីឡូន២* ដែលជាប្រវត្តិសាស្ត្រ? ត្រឹមត្រូវ។ រកឃើញនៅក្នុងប្រវត្តិសាស្ត្រនេះ។ ពួកគេមានស្ត្រី...និងបន្ទាប់មកអ្នកចងចាំទេ ទោះបីយ៉ាកុបក៏លួចព្រះរបស់ឪពុកខ្លួនដែរ ហើយ កូនស្រីរបស់គាត់បានលាក់នៅពីក្រោមនាង និង យកវាចេញនៅវាលរហោស្ថាន ដែលធ្វើឲ្យជំរុំស្មោគគ្រោក នាពេលក្រោយ។ ត្រូវហើយ។

105 ចូរអាននៅទីនេះឥឡូវក្នុងលោកុប្បត្ត

*ឯពស់ជាសត្វចេះឧបាយកលលើសជាងអស់ទាំងសត្វព្រៃ ដែលព្រះយេហូវ៉ាដ៏ជាព្រះទ្រង់បានបង្កើត វានិយាយទៅកាន់ស្ត្រីថា តើព្រះមានព្រះបន្ទូលហាមមិនឲ្យអ្នកបរិភោគផ្លែឈើណានៅក្នុងសួនច្បារមែនឬ?*

*...ស្ត្រីឆ្លើយតបថា យើងបរិភោគអស់ទាំងផ្លែឈើនៅក្នុងសួនច្បារបាន:*

*តែត្រង់ដើមឈើ១...ដែលនៅកណ្ដាលសួនច្បារនោះ ព្រះទ្រង់មានព្រះបន្ទូលថា កុំឲ្យបរិភោគផ្លែនោះឡើយ ថែមទាំងកុំឲ្យប៉ះពាល់ ផង*

*ក្រែងលោស្លាប់*

*រួចពស់ក៏និយាយ ទៅស្ត្រីថា អ្នកមិនស្លាប់ជាពិតមែនទេ ដ្បិតព្រះទ្រង់ជ្រាបថា នៅថ្ងៃណាដែលអ្នកបរិភោគ នោះភ្នែកអ្នកនឹងបានភ្លឺឡើង(ឃើញទេប្រមាញ់រកពន្លឺថ្មី) ហើយអ្នកនឹងបានដូចជាព្រះដែរ ព្រមទាំងដឹងការខុសត្រូវផង*

106 ឃើញពួកមិត្តភក្រ័សម័យនេះទេ ព្យាយាមយកអ្វីចេញពីព្រះគម្ពីរ? "ហេតុអ្វីមិនគ្រាន់តែចាក់ ឬ ប្រោះៗ ឬ *របៀបនេះ* ឬ *របៀបនោះ?"* អត់ទេ។ ព្រះជាម្ចាស់ដាក់កម្មវិធី ហើយនោះជាអ្វីដែលយើងត្រូវតែធ្វើតាម *បែបនេះ*។

*កាលស្ត្រីបានឃើញថា ផ្លែឈើនោះបរិភោគបាន ក៏ជាទីគាប់ដល់ភ្នែក ហើយជាដើមដែលល្មមគួរនឹង...ចង់បាន ដើម្បីឲ្យបានប្រាជ្ញា នោះនាងក៏យកផ្លែមកបរិភោគព្រមទាំងចែកឲ្យដល់ប្ដីដែរគាត់ក៏បរិភោគតាម*

*នោះស្រាប់តែភ្នែករបស់អ្នកទាំង២បានភ្លឺឡើង ហើយគេដឹងថាខ្លួននៅជាអាក្រាត ក៏យកស្លឹកល្វាមកក្លាស់ធ្វើជាប្រដាប់បាំង*

107 ខ្ញុំចង់ឈប់ត្រង់នេះមួយភ្លែត។ ឥឡូវ វាត្រូវតែមានការចាប់ផ្ដើមពីរាល់អ្វីៗទាំងអស់។ អ្នកមានការចាប់ផ្ដើម។ ឥឡូវយើង...ត្រង់នេះខ្ញុំចង់ឲ្យមានការយកជាគោលការទាំងមូល ឥឡូវ យើងនិយាយនៅក្នុងការប្រជុំពីរលើកចុងក្រោយ និងមកដល់ទីនេះ។

108 ឥឡូវ កាលពីព្រឹកមិញ យើងត្រលប់ទៅវិញ និង ពង្រីកសាច់រឿង ក្នុងព្រះគម្ពីរពេលដែល ព្រះជាម្ចាស់កំពុងបង្កើតពិភពលោក នោះជាពេលដែលទ្រង់កំពុងបង្កើតហ្គាស ហើយហ្គាសបានក្លាយជាកាល់ស្យូម និងជាក្បុង និង—និងអ្វីផ្សេងៗទៀត។ ទ្រង់កំពុងបង្កើតរាងកាយរបស់យើង។ ទ្រង់កំពុងដាក់អាគារឡើងដូចជាចៅហ្វាយសាងសង់ដ៏អស្ចារ្យម្នាក់ ដូចជាអ្នកសាងសង់កំពុងដាក់ឧបករណ៍របស់គាត់ដើម្បីសង់គម្រោងផ្ទះមួយ។ ទ្រង់កំពុងបង្កើតរាងកាយរបស់អ្នក។ ទ្រង់ស្គាល់ច្បាស់ ក្នុងព្រះទ័យទ្រង់ អ្វីនឹងត្រូវសម្រេច។

109 ដៃ*នេះ* ព្រះជាម្ចាស់បង្កើតដៃនោះមុនទ្រង់...ពេលទ្រង់កំពុងបង្កើតពិភពលោក ប៉ុន្តែ វិញ្ញាណរបស់ខ្ញុំទ្រង់បង្កើតមុនពិភពលោក។ ឥឡូវ ប៉ុន្តែដៃនេះ និង រាងកាយនេះ ទ្រង់បង្កើត ពេលទ្រង់បង្កើតពិភពលោក ព្រោះរាងកាយនេះកើតចេញពីផែនដី និង ត្រលប់ទៅជាដីវិញ។ ព្រះជាម្ចាស់បង្កើតការនោះ។ ទ្រង់បានដាក់ទាំងអស់ចេញក្នុងគម្រោងរបស់ទ្រង់ និង កម្មវិធីរបស់ទ្រង់។

110 ឥឡូវ ពេលទ្រង់បង្កើតផែនដី ទ្រង់បង្កើតមនុស្ស ហើយ មនុស្សមិនទាន់មើលបានពេញលក្ខណៈនៅឡើយ។ ឥឡូវយើងមាន កាលព្រឹកមិញ បន្តដោយការសម្ដែងរបៀបដែល—ព្រះបិតាយាងចុះមកដើម្បីស្វែងរកបុត្រារបស់ទ្រង់ បង្កើតទ្រង់តាមរូបអង្គទ្រង់ និង អ្វីផ្សេងទៀត។ ហើយទ្រង់បង្កើតប្រពន្ធមួយឲ្យលោក និងជាអ្នកជំនួយ។

111 ឥឡូវ ចងចាំថា អស់ទាំងស្នាព្រះហស្តដែលបង្កើតមកលើផែនដី អ័ដាំបាន ដាក់ឈ្មោះឲ្យ។

112 ទ្រង់បានបង្កើត—ចតុបាត និង សត្វពាហនៈធំ និង អ្វីគ្រប់យ៉ាង។ ហើយ សព្វថ្ងៃ យើង...អ្នកប្រវត្តិសាស្ត្រនិង—និងមានគំនិតនៃវិទ្យាសាស្ត្រដែលខុសគ្នា ខ្លាំង បានព្យាយាមសាកល្បង ៦ពាន់ឆ្នាំ ដើម្បីស្វែងរកការតភ្ជាប់ដែលបាន បាត់បង់ ហេតុអ្វីបានជាសត្វទាំងនោះ...មនុស្សជាជីវិតសត្វ។ យើងដឹងថា យើង ត្រូវបានបង្កើតមក...

113 ហើយស្ត្រីជាផ្នែកមួយនៃបុរស ជាអនុផល។ ស្ត្រីមិនមែនជាស្នាព្រះហស្ត បង្កើតដើមឡើយ។ ព្រះជាម្ចាស់បានបញ្ចប់ការបង្កើតហើយ ជាច្រើនឆ្នាំ និង ច្រើនឆ្នាំ រហូតដល់ទ្រង់បង្កើតស្ត្រីចេញពីឆ្អឹងជំនីចំហៀងរបស់មនុស្សប្រុស។ អ័ដាំបានដាក់ឈ្មោះសត្វទាំងអស់ ប៉ុន្តែគាត់ ខ្លួនគាត់មិនមែនជាអ្វីឡើយ។ ដូច្នេះ ទ្រង់បានបង្កើតអ្នកជំនួយដល់គាត់ យកឆ្អឹងជំនីចេញពីខ្លួន ភ្ជិតស្នាមរង្វះ និង បង្កើតអ្នកជំនួយមួយដល់គាត់។ ហើយ បុរស ក្នុងវិញ្ញាណគាត់ ជាប្រុសផងជា ស្រីផង។

114 ហើយស្ត្រីគ្រាន់តែជាផ្នែកមួយនៃបុរស។ ហើយពេលបុរសយកគាត់ជាប្រពន្ធ ហើយប្រសិនបើនាងជាប្រពន្ធត្រឹមត្រូវរបស់គាត់ ជាប្រពន្ធ-ព្រះប្រទានឲ្យ នាង ចំពោះគាត់គ្រាន់តែជាផ្នែកមួយប៉ុណ្ណោះ។

115 នោះជាហេតុផលដែលអ្នក ត្រូវធ្វើរឿងជាច្រើនក្នុងអាពាហ៍ពិពាហ៍ ព្រោះពេល អ្នកចេញទៅក្រៅ និង ឃើញក្មេងស្រីមានភ្នែកពណ៌ត្នោត ឬ ភ្នែកខៀវ ឬអ្វី ដូចនោះ និងមានរូបរាងស្អាត ហើយ អ្នកធ្លាក់ក្នុងសេចក្តីស្រឡាញ់នាង។ ដំបូង នាងកើតកូនដំបូង ពេលធ្មេញបាក់អស់ និង នាងជ្រួញ ហើយ ចាស់ ចង់ទាត់នាង ចោល។ ហើយមានអ្នកខ្លះនៃអ្នកជាស្ត្រីរកក្មេងប្រុស ដែលមានសក់រលោង និង សក់ម្តាយរបស់គាត់អាចមានខ្លាញ់ពាក់កណ្តាល ហើយ សក់រួញ។ ហើយវានឹង ទាសចេញខ្ញុំស្គាល់បានដោយបទពិសោធន៍។ ប៉ុន្តែតើមានអ្វីកើតឡើង? វាជាអ្វី? អ្នកធ្លាក់ទៅក្នុងនោះ។

116 អ្នកគួរតែអធិស្ឋាន ជាមុន ព្រោះស្ត្រីជាផ្នែកមួយរបស់អ្នក។ ហើយបើអ្នកបាន ឱបស្ត្រីនៅនឹងដើមទ្រូងរបស់អ្នកនិងយកនាងជាប្រពន្ធរបស់អ្នកហើយ អ្នក...នាង នឹងធ្វើឲ្យមានស្នាមលើរូបអ្នក។ យើងនឹងនិយាយបែបនេះ ដូច្នេះអ្នកនឹងយល់។

ហើយស្ត្រីផ្សេងទៀតទាស់នឹងទ្រូងនោះ ពិតជាមិនត្រូវនឹងស្មាមនោះ ឡើយ។ ហើយព្រះនឹងប្រកាន់អ្នកអំពីទំនួលខុសត្រូវនោះ។ ហើយគ្រាន់ តែចាំ។

117 អ្នកដែលយកប្រពន្ធអ្នកដទៃ...ខ្ញុំឮសព្វថ្ងៃពីក្មេងស្រីម្នាក់នៅក្រុងនេះ ជាក្មេងស្រីគួរឲ្យអាណិត។ ខ្ញុំស្គាល់នាង។ មានអ្នកលេងល្បែងម្នាក់ស្រទាញនាងទិញសម្លៀកបំពាក់ស្អាត និង អ្វីផ្សេងទៀត និង ព្យាយាមលេងជាមួយនាងបែបនោះ។ កណ្តុរ វាធ្វើរឿងបែបនោះ មិនអាចសូម្បីរាប់ថាជាមនុស្សផង។

118 អ្នកដឹងទេ ឆ្កែវាមិនថោកទាប បែបនោះឡើយ ហើយអ្នកនៅតែហៅ មេឆ្កែថា "ស្រីចើក។" វាមានសីលធម៌ជាងស្ត្រីពាក់កណ្តាលជេសាន់វីលផង។ ហើយអ្នកហៅមេជ្រូកថា "មេជ្រូកញី" ហើយវាមិនដូច្នេះទេ...វាមានសីលធម៌ជាងស្ត្រីពាក់កណ្តាលទូទាំងសហរដ្ឋអាមេរិកផង ភាគច្រើននៃពួកគេ។ នោះជាការពិត។ ឥឡូវខ្ញុំដឹងថាវាគ្មានន័យ។ ខ្ញុំប្រាប់អ្នកខ្ញុំនឹងខាត់សំលៀងក្នុងផ្ទះ ហើយ ខ្ញុំចង់ឲ្យអ្នកស្គាល់វា។ ហើយនោះជាការពិត។ ពួកគេទាំងអស់ស្ត្រីសព្វថ្ងៃ មិនដឹងថាសីលធម៌ជាអ្វីផង។ និយាយ "កុំធ្វើឲ្យមនសិកាខ្ញុំឈឺចាប់។" ល្អអ្នកមិនកត់សម្គាល់អ្វីទេ។ សម្គាល់។ បាទ លោក។ ពេលអ្នកដឹងថាអ្វីត្រូវ និង ខុស។

119 ឥឡូវ ចំណាំ។ បុរសនេះ ពេលត្រូវបានបង្កើតមក ព្រះបានបំបែកវិញ្ញាណរបស់គាត់។ ហើយទ្រង់យកចំណែកខ្លះនៃមនុស្ស ចំហៀងគាត់ ហើយបង្កើតជាស្ត្រីចេញមក។ ហើយ ទ្រង់ក៏យកភាពជាស្ត្រី ភាពវិញ្ញាណប្រណិតរបស់បុរស និង បង្កើតស្ត្រីចេញមក។ហើយទ្រង់ក៏ធ្វើឲ្យមនុស្សប្រុសមានភាពជាបុរសភាពរឹងប៉ឹង។

120 ហើយពេលអ្នកឃើញ—ឃើញ—ឃើញមនុស្សប្រុសតូច...អ្នកស្គាល់ពី តុបតែងក្រចក ឬហៅអ្វីក៏ដោយ ក្រចករបស់គាត់ និង អ្នកដឹង បួននៅម្ខាង និង ប្រាំនៅម្ខាងទៀតនិង—និងធ្វើសក់ឲ្យរលោងទម្លាក់ចុះមាត់ចំហពីមុខ គឺដូចបែប នោះ ជាក្មេងប្រុសស្រស់ស្អាតម្នាក់។ អ្នកគ្រាន់តែចាំថាបងប្អូនស្រីមានអ្វីខុស ចំពោះ សត្វនោះ។ មានអ្វីខុសហើយ។ ទប់ភ្នែកកុំមើលគាត់ឡើយ។

121 ហើយពេលអ្នកឃើញស្ត្រីមានបារីនៅ ក្នុងមាត់ពាក់ខោអៀមនិងនិយាយ "ខ្ញុំប្រាប់អ្នក មនុស្សនោះ វាជាអ្វី!" បងប្អូនប្រុស អ្នកមើលស្ត្រីចាស់នោះទៅ។ មានអ្វីមួយខុសឆ្គងជាមួយគាត់ហើយ។

122 ស្រ្តី ត្រូវតែមានភាពជាស្រ្តី ហើយ នាងត្រូវស្លៀកបែបជាស្រ្តី។ ពេល ព្រះជាម្ចាស់បង្កើតបុរស ព្រះជាម្ចាស់បង្កើតគាត់ក្នុងភាពមួយ ហើយ ទ្រង់បង្កើត ស្រ្តីមានភាពផ្សេងមួយទៀត។ ហើយពេលព្រះតុបតែងបុរស ទ្រង់តុបតែងរបៀប មួយ និង ស្រ្តីរបៀបមួយទៀត។ ហើយ ព្រះគម្ពីរនិយាយ "វាជាការស្អប់ខ្ពើមដល់ ព្រះ ចំពោះស្រ្តីណាស្លៀកសម្លៀកបំពាក់សមនឹងបុរស"។

123 ហើយអ្នកជាស្រីៗស្លៀកខោខ្លីចាស់តូចមួយបែបនេះ និង អ្វីៗទៀត ហើយ ស្លៀកវាចេញមក របស់តូចចាស់...អ្នកហៅវាថាយ៉ាងម៉េច ខោជើងខ្លី? ពួកវា ធ្វើអ្វី...? អូ តើពួកវាជាអ្វី...? ទេ ទេ វាមិនខ្លីទេ នោះជាអាមួយផ្សេងទេ មានជើងវែង ក្នុងនោះ។ [ក្រុមជំនុំនិយាយ "Pedal Pusher"—Ed.] Pedal Pusher និង គ្រប់ ទាំងអស់ ខោអៀម។

ទៅក្នុង និយាយ "នេះសម្រាប់ស្រ្តី។"

124 ខ្ញុំនិយាយ "ទេអ្នកខុសហើយ។ ស្រ្តីមិនស្លៀកវាទេ។ ស្រ្តីអាច ប៉ុន្តែសុភាពស្រ្តី មិនទេ" ត្រូវទេ។

125 ព្រះគម្ពីរនិយាយថា"វាជាការស្អប់ខ្ពើមដល់ព្រះជាម្ចាស់សម្រាប់ស្រ្តីណា ស្លៀកពាក់...និង សម្រាប់បុរសដែលស្លៀកសម្លៀកបំពាក់របស់ស្រ្តី។"

126 ហើយ ប្រុសៗកាន់តែក្លាយជាកំសាករាល់ថ្ងៃហើយស្រីៗកាន់តែក្លាយជាភាព បុរសវិញ។ មានរឿងអី? យើងនឹងរកឃើញតែប៉ុន្មាននាទីទៀត តាមរយៈព្រះគម្ពីរ។ ស្រ្តីនឹងមិនមែនជាស្រ្តីទៀតឡើយ។ ខ្ញុំមិនសំដៅអ្នកជាស្រ្តីគ្រីស្ទបរិស័ទទេ។ ខ្ញុំ និយាយពីដំណើរទូទៅ។ ពួកគេចង់សម្ដែងដូចជាបុរស ចង់កាត់សក់ដូចបុរស លើកដៃឡើងក្នុងបារ បែប*នោះ* និងច្រៀង *ព្រះប្រទានពរអាមេរិក* ជាមួយបារីលាន ចេញនៅចុងបបូមាត់។

127 ទៅតាមផ្លូវ ទៅក្រៅដូចនោះ នៅតាមផ្លូវធំ។ យើងរាប់...ខ្ញុំចង់ប្រាប់អ្នករឿង ខ្លះ។ ហើយ អ្នកជាស្រ្តីបើកបរ សូមស្ដាប់។ ប៊ីលលី ប៉ុល និងខ្ញុំ ចូលរួមយុទ្ធនាការ ចុងក្រោយជុំវិញប្រជាជាតិ ប្រាំមួយខែ ខ្ញុំរាប់ អ្នកមិនរអែងប៉ុន្មានអ្នកនៅតាមផ្លូវ។ ក្នុងចំណោមគ្រោះថ្នាក់អកុសល៣០០ដង នៅតាមផ្លូវ ទាយមើលប៉ុន្មាននាក់ជា អ្នកបើកបរស្រ្តី? វាខ្វះតែ...១៩នាក់ជាបុរស។ ហើយពីររយប៉ែតសិប ឬ ខ្ញុំជឿថាពីរ

រយប៉ែតសិបមួយ អ្នកជាអ្នកបើកបរជាស្ត្រីភេទ។ អ្នកបើកបរជាស្រី! ឥឡូវ ខ្ញុំមិននិយាយថាមិនមានស្ត្រីបើកបរបានល្អទេ។ ប៉ុន្តែនាងបានធ្វើបញ្ហាស់ហើយ។

128 ហើយ អ្នកព្យាយាមតាមពីក្រោយនាង? សូមឲ្យនាងជាអ្នកមើលទៅស្រស់ស្អាត ឈរនៅទីនោះ លើកសក់ឡើងពេលប៉ូលីសមកដល់។ "ហេតុអ្វី" គាត់និយាយ "ពិតណាស់អ្នកខុសហើយ!" ហ៊ុម! យើងមិនមែនមិនមានច្បាប់ឯណា។

129 ពួកគេបង្ហាញថា នៅថ្ងៃណាមួយ ក្នុងរឿងក្តីពន្ធដារដែលខ្ញុំកំពុងតែចង់និយាយ។ យើងមិនមែនមិនមានច្បាប់ឯណា។ បើមាន...

130 មិនមានអ្វីឆ្ងល់ទេ ដែលព្រះអម្ចាស់អស្ចារ្យម្នាក់ ក្នុងប្រទេសអង់គ្លេសនិយាយ "លទ្ធិប្រជាធិបតេយ្យគឺទាំងអស់គ្នាត្រូវបើកទៅ ហើយគ្មានយុត្តាឡើយ។" នោះជាការពិត ឈរថ្លែងសុន្ទរកថា ជាអ្នកឈរឈ្មោះបោះឆ្នោត។ លទ្ធិប្រជាធិបតេយ្យពុកផុយណាស់ ហើយ វាពិតជាផ្តាច់ការ និង អ្វីៗទាំងអស់នោះដែរ។ អ្វីទាំងមូលពុកផុយ។ វាមិនមានអ្វីសម្រាប់ឲ្យព្រះជាម្ចាស់អាចធ្វើបានឡើយ វាបំផ្លាញរឿងទាំងមូល ដូចទ្រង់មានបន្ទូលថាទ្រង់នឹងធ្វើ និង ចាប់ផ្តើមជាថ្មី។ ឥឡូវ សម្លឹងមើលអ្នកកាន់តែកៀកការយាងត្រលប់មកវិញប៉ុណ្ណា។

131 ឥឡូវ ពេលស្ត្រីនេះ...ពេលទ្រង់បង្កើតឲ្យគាត់នូវអ្នកជំនួយម្នាក់ និង នាងជាអ្នកជំនួយដល់គាត់។ និង ដូច្នេះ...

132 ឥឡូវ នៅទីនេះ ខ្ញុំមិនទាន់មានអ្នកអធិប្បាយណាដែលយល់ស្របជាមួយរឿងនេះឡើយ។ ហើយពួកគេព្យាយាមធ្វើវាតាមរបៀបមួយទៀត ប៉ុន្តែវានៅតែមិនអាចសមហេតុផលសម្រាប់ខ្ញុំ។ ពួកគេព្យាយាមនិយាយថាអ័ដាំ និង អេវ៉ាបរិភោគផ្លែប៉ោម។ បងប្អូនបើ...ខ្ញុំមិននិយាយរឿងនេះសម្រាប់ជាការកំប្លែងទេ តែខ្ញុំចង់និយាយវា។ ព្រោះបើសិនការបរិភោគផ្លែប៉ោមអាចឲ្យស្ត្រីដឹងថាខ្លួននៅអាក្រាត យើងគួរតែបរិភោគផ្លែនោះម្តងទៀត។ នោះអ្នកដឹងថាអ្វីត្រូវ។

133 អ្នកដឹងទេ ការបរិភោគផ្លែប៉ោម នោះមិនមែនជាអ្វីដែលពួកគេធ្វើឡើយ ដែលធ្វើឲ្យគេដឹងថាគេនៅអាក្រាត។ ជាការពិត វាមិនដូច្នោះឡើយ។ វាត្រូវតែចូលមកក្នុងរឿងផ្លូវភេទ។ វាត្រូវតែដូច្នេះ ពួកគេដឹងថាខ្លួននៅអាក្រាតពេលដែលពួកគេបរិភោគ ផ្លែឈើដឹងខុសត្រូវនេះ។ តើស្ត្រីមិនមែនជាដើមឈើនៃផ្លែនោះទេ? តើអ្នកមិនមែនជាផ្លែឈើពីម្តាយរបស់អ្នកទេ? នោះជាផ្លែដែលត្រូវបានហាមឃាត់ ដែលត្រូវបានបេះយកនោះ។

134 ឥឡូវនេះជារឿងធំមួយ។ ឥឡូវជាភាពកៀកជិត បំផុតដែលវិទ្យាសាស្ត្រមិនធ្លាប់ដឹងពីភាពជាមនុស្សយ៉ាងណា...ពួកគេជីកយកឆ្អឹងចាស់ ពួកគេយកហ្វូស៊ីល ហើយយកក្បាលមក ហើយយកលលាដ៍ក្បាល និង ដៃ និងឆ្អឹង ហើយព្យាយាមធ្វើឲ្យដូចជាមនុស្ស។ ហើយពួកគេដឹងថានោះជា ភាពកៀកជិតមួយដែលពួកគេព្យាយាមស្វែងរកពីមនុស្ស ដែលកៀកស្រដៀងនោះ វាជាស្វាឪ។ គឺជាសត្វ ដែលមានភាពស្រដៀងគ្នានឹងមនុស្សបំផុត ប៉ុន្តែវានៅតែមិនមែនជាអ្វីពីភាពជាមនុស្សឡើយ ជាភាពខ្ពស់បំផុត។

135 ទម្រង់ទាបជាងគេនៃជីវិតគឺជាកង្កែបទម្រង់ខ្ពស់បំផុតគឺមនុស្ស។ ព្រះជាម្ចាស់ចាប់ផ្តើមពីភាពដែលទាបបំផុត និងបន្តទៅជាភាពខ្ពស់ឡើងរហូតដល់ទ្រង់ទាញយកមកជារូបនៃព្រះជាម្ចាស់។ ព្រះអង្គបង្កើតមនុស្សភាពរូបបែបនោះ។ នោះជាទម្រង់ខ្ពស់បំផុត។ ទម្រង់ទាបបំផុតគឺជាកូនក្អុកដែលប្រែទៅជាកង្កែប និង មានបន្តទៀត។

136 ឥឡូវ ការបាត់បងការតភ្ជាប់ ដែលពួកគេមិនអាចរកឃើញ។ សូមមើលខគម្ពីរឥឡូវ។ អ្នក អ្នកនឹងមិនយល់ស្របជាមួយរឿងនេះ អ្នកជាច្រើននៃអ្នករាល់គ្នា ប៉ុន្តែខ្ញុំចង់...ខ្ញុំចង់ឲ្យអ្នកចងចាំក្នុងគំនិត។ ហើយ កុំលំអៀងទាស់នឹងវា។ សូមស្តាប់។

137 ខ្ញុំដឹងថាភាគច្រើននៃអ្នករាល់គ្នាទើបតែបានស្តាប់ ដុកទ័រ ដេហាន ខ្ញុំប្រាកដ...ជាមនុស្សដែលមានគុណភាពរបស់គាត់ និង ជាបងប្អូនប្រុសបាបទីស្ត ដ៏ល្អ ហើយ ខ្ញុំពិតជារីករាយជាមួយនឹងគាត់។ គាត់មានភាពវៃឆ្លាតជាង និង ខួរក្បាល និង—និងភ្លេចច្រើនជាងមុនព្រោះគាត់ជាដុកទ័រនៃ—ទេវវិទ្យា ហើយ គាត់ជា ដុកទ័រផ្នែកវេជ្ជសាស្ត្រ និង ជាដុកទ័រផ្នែកវិទ្យាសាស្ត្រ។ គាត់ជាមនុស្សវៃឆ្លាត។ ប៉ុន្តែគាត់និយាយបែបនោះ...ពេលដែលពួកកូនរបស់ព្រះឃើញកូនមនុស្សស្អាតៗ គាត់ឈរលើជំហរលោកយូសែបហ្វីស និង និយាយថា "ពួកគេ—ពួក គេ បង្រួមខ្លួនជាសាច់ ឈាមមនុស្ស" និងយកគេជាប្រពន្ធ។ ហើយមានយក្សនៅទឹកដីណូដ។ "ហើយពួកគេបានយកពួកនាងធ្វើជាប្រពន្ធ និង រស់នៅជាមួយពួកគេ ពេលដែលពួកកូនព្រះ ជាទេវតាធ្លាក់ចុះ បានឃើញពួកកូនស្រីរបស់មនុស្ស និង ចំណង់ផ្លូវភេទជារឿងធំ ប៉ុន្តែពួកគេពេញដោយបាបដោយសាការធ្លាក់ចុះ ពួកគេ បញ្ចូលខ្លួនជាមួយសាច់ឈាមមនុស្ស។"

138 បើពួកគេធ្វើដូច្នោះ ពួកគេបានធ្វើឲ្យខូចការប្រោសឲ្យជា មកពីព្រះជាម្ចាស់ ហើយ ពួកគេបង្ខូចអ្វីផ្សេងទៀត។ បើសិនជាអារក្សបង្កើត គាត់មានភាពស្មើនឹងព្រះជាម្ចាស់។ អារក្សមិនអាចបង្កើតអ្វីបានទេ។ ខ្ញុំចង់ឲ្យអ្នកបង្ហាញខ្ញុំកន្លែងមួយដែលអារក្សអាចបង្កើត។ វាមិនមែនជាអ្នកបង្កើតឡើយវាគ្រាន់តែជាអ្នកចចេសប៉ុណ្ណោះ។

139 ល្អ ដូច្នេះ អ្វីកើតឡើង? ពិនិត្យមើល។ នេះជាខប្រសើរ។ នេះជាតំណភ្ជាប់ដែលបាត់។

140 ឥឡូវពួកគេមានស្វាឌី ប៉ុន្តែអ្នកមិនអាចបង្កើតពូជជាស្វាឌី ជាមួយស្ត្រីហើយបង្កើតកូនបានឡើយ។ អ្នកមិនអាចបង្កើតមនុស្សជាមួយសត្វឡើយ។ វាមិនត្រូវបានរលាយគ្នាឡើយ។ អ្នកមិនអាចបញ្ចូលឈាម ពីសត្វណាឡើយ។

141 ពេលខ្ញុំនៅអាហ្វ្រិក ពួកគេប្រព្រឹត្តប្រជាជនជាតិស្បែកខ្មៅ ដែលក្រីក្រនៅទីនោះតាមរបៀបនោះ មានអ្នកនិយាយមកកាន់ខ្ញុំ និយាយ "ពួកគេមិនមែនជាអ្វីឡើយ តែជាសត្វប៉ុណ្ណោះ។"

142 ខ្ញុំនិយាយ "ខ្ញុំសូមឲ្យអ្នកអត់ទោស។ ពួកគេគ្រាន់តែជាមនុស្សដូចជាអ្នកដែរអាចជាអ្វីជាងនោះបន្តិចផង។" ចូរឲ្យខ្ញុំប្រាប់អ្នក ពេលអ្នកមានចរិកលក្ខណៈបែបនោះ អ្នកបានត្រលប់ទៅជាសត្វវិញ។ ខ្ញុំនិយាយ "មនុស្សនោះ ទោះបីជាគាត់ខ្មៅដូចជាសន្លឹកអាត់ប៊ិកក៏ដោយ ឬ ទោះបីជាគេមានពណ៌លឿងដូចល្ពៅក៏ដោយ ឬទោះបីជាគេមានពណ៌ខៀវដូចជាដើមធ្លះក្តី ពួកគេអាចសង្គ្រោះជីវិតដោយការបញ្ចូលឈាមឲ្យអ្នក។ ប៉ុន្តែអ្នកមិនដែលដាក់ឈាមសត្វក្នុងខ្លួនអ្នកទេ។" ពិតណាស់ គាត់ជាមនុស្ស។

143 ដោយគ្រាន់តែស្បែកមួយពណ៌ខ្មៅ ហើយ អ្នកម្នាក់ទៀតពណ៌ត្នោត និង អ្នកផ្សេងទៀតពណ៌លឿង និង អ្នកផ្សេងពណ៌ស គ្មានអ្វីត្រូវធ្វើជាមួយវាឡើយ។ ព្រះគម្ពីរនិយាយ "ព្រះជាម្ចាស់នៃឈាមតែមួយបង្កើតមនុស្សទាំងអស់" ហើយនោះពិតជាត្រឹមត្រូវ។ កន្លែងដែលយើងរស់នៅ ឬពណ៌របស់យើង គ្មានអ្វីត្រូវធ្វើជាមួយវាឡើយ។ ព្រះជាម្ចាស់បង្កើតមនុស្ស—ម្នាក់ជាជាតិសាសន៍ទាំងអស់ ឈាមតែមួយ និងគ្រប់ប្រជាជាតិគឺដូចគ្នា។

144 ជនជាតិចិន មនុស្សស្បែកពណ៌មិនអាចនិយាយឥឡូវទេ មនុស្សស្បែកខ្មៅក៏មិនអាចនិយាយឥឡូវដែរ ថា "នោះជាបុរសជនជាតិចិន គាត់—គាត់ពណ៌លឿង ខ្ញុំគ្មានអ្វីត្រូវធ្វើជាមួយគាត់ទេ" គាត់ជាបងប្អូនប្រុសរបស់អ្នក។ ហើយអ្នកជាជនជាតិស្បែកសក៏មិនអាចនិយាយទៅកាន់អ្នកស្បែកលឿង និង ស្បែកខ្មៅ ទាំងពីរនាក់ "ខ្ញុំគ្មានអ្វីធ្វើជាមួយអ្នកឡើយ" គាត់ជាបងប្អូនប្រុសរបស់អ្នក។ ជាការពិត ។

145 សម្គាល់ឥឡូវ នេះជាអ្វីដែលកើតឡើង។ ខ្ញុំជឿនិងអាចគាំទ្រវាដោយព្រះគម្ពីរថានោះជាសត្វពស់ដែលបានធ្វើ។ សត្វពស់ជា គឺជាការបាត់ចន្លោះរបស់មនុស្សរវាងស្វាឪ និង មនុស្ស។ ព្រោះ សូមស្តាប់ សម្គាល់ឥឡូវ សត្វពស់នោះមិនមែនជាល្មូនទេ។ វាមានភាព "មានល្បិច" នៃសត្វចតុបាទទាំងអស់នៅក្នុងទីវាល។

146 ឥឡូវខ្ញុំទៅយកវចនានុក្រមមក ថ្ងៃនេះពីគ្រប់កន្លែង ដើម្បីមើលពាក្យនេះ ពាក្យថា ឧបាយកល មានន័យយ៉ាងណា។ វាមានន័យថា "ត្រូវតែឆ្លាត ត្រូវតែមានល្បិច" ហើយ ការបកប្រែល្អបំផុតនៃ—នៃ ភាសាហេព្រើ(ពី m-a-h-ah mahah) មានន័យថា "មានការចេះដឹងច្បាស់ពីគោលការជីវិត។"

147 ឥឡូវ ចូរពិនិត្យរឿងនេះមួយនាទី។ វាឆ្លាត ល្បិចកល តែវានៅតែត្រូវបានហៅថាជា "សត្វពស់។" ប៉ុន្តែចងចាំថា វាជាអ្វីដែលឆ្លាតបំផុតនៅពេលនោះ ហើយជាអ្វីដែលកាន់តែមានភាពស្រដៀងមនុស្ស ដែលនៅទីវាល កៀកនឹងមនុស្សបំផុត។ វាមិនមែនជាសត្វល្មូនឡើយ។ បណ្តាសាធ្វើឲ្យវាក្លាយជាសត្វល្មូន។ ហើយវា...ព្រះគម្ពីរនិយាយថាវាស្អាតជាងគេទាំងអស់។

148 ហើយទោះបីជាបណ្តាសា ក៏មិនបានយកភាពស្រស់ស្អាតរបស់វាទាំងអស់ចេញដែរ ពណ៌ស្រស់ស្អាតរបស់ពស់នៅតែស្អាត ហើយ ព្រះគុណរបស់វាប្រាជ្ញាល្អិតរបស់វានៅតែដដែល។ ទោះបីជាបណ្តាសា មិនបានដកចេញគុណសម្បត្តិនោះឡើយ។ ប៉ុន្តែ អ្នកចាំទេ ព្រះជាម្ចាស់មានបន្ទូលប្រាប់វាថាជើងរបស់វានឹងត្រូវដកចេញ ហើយ វាត្រូវធ្វើដំណើរដោយពោះ។ ហើយអ្នកមិនអាចរកឃើញឆ្អឹងសត្វពស់ដែលស្រដៀងនឹងមនុស្សឡើយ នោះហើយជាហេតុផលដែលអ្នកវិទ្យាសាស្ត្រវង្វេង។ ប៉ុន្តែវាគឺបែបនេះ។

149 ព្រះជាម្ចាស់បានលាក់សេចក្តីនេះពីភ្នែករបស់មនុស្សមានប្រាជ្ញា និង មនុស្សប្រុងប្រយ័ត្ន ហើយសន្យាថានឹងបើកសម្តែងដល់បុត្រារបស់ព្រះវិញ នៅថ្ងៃចុងក្រោយពេលដែលបុត្រមនុស្សនឹងបានសម្តែងចេញមក ពេល "បុត្រារបស់

ព្រះមាន អំណរតាំងពីមុននឹងមានគ្រឹះផែនដីផង។" ពេលដែលការបើកសម្ដែងពីព្រះសិរ របស់ព្រះជាម្ចាស់ និង អ្វីដែលនាំមកនៅថ្ងៃចុងក្រោយ ទ្រង់នឹងបើកសម្ដែងសេចក្ដីទាំងនេះតាមរយៈបុត្រារបស់ព្រះជាម្ចាស់។ អ្នកដឹងថា បទគម្ពីរបង្រៀនពីសេចក្ដីនោះ។ ហើយយើងនៅទីនេះ។ នោះជាហេតុផលដែលព្រះជាម្ចាស់បានបើកសេចក្ដីទាំងនេះចំពោះយើង។ ព្រះជាម្ចាស់កំពុងនាំបុត្រារបស់ទ្រង់ឲ្យបានសម្ដែងចេញមក។ ទ្រង់នៅលើអស់ទាំង ការកម្រិតនៃចំណេះរបស់មនុស្ស តាមផ្លូវទៅកាន់ការបើកសម្ដែងខាងវិញ្ញាណ និង នាំវាចូលមក។ តើយើងមិនធ្លាប់ទទួលបានការបង្រៀន នៅក្នុងព្រះគម្ពីរ "នេះជាសេចក្ដីសម្រាប់អស់អ្នកមានប្រាជ្ញា"? មិនមែនជាអ្វីដែលគាត់រៀននៅក្នុងការអធិប្បាយឡើយ ប៉ុន្តែជាអ្វីដែលគាត់រៀនពីការលត់ជង្គង់នៅមុខព្រះជាម្ចាស់ ហើយ ជាអ្វីដែលព្រះសព្វព្រះទ័យប្រទានដល់គាត់។ បុត្រារបស់ព្រះ ត្រូវបានបង្ហាញឲ្យឃើញ!

150 នេះជាសត្វពស់ ឥឡូវនេះជារូបរាងរបស់សត្វពស់ខ្ញុំ នឹងផ្ដល់ឲ្យអ្នកនូវការពណ៌នា របស់ខ្ញុំអំពីវា។

151 យើងបាន...យើងបានចេញមក ពីកង្កែប ជាកូនក្អុក និង បន្តមក ហើយ*តរៀងមក* រហូតក្លាយជាស្វា នឹងក្លាយជាស្វាឌី។ ហើយ តពីស្វាឌី ឥឡូវ យើងលោតចូលមកស្វាឌីក្លាយជាមនុស្ស ហើយ យើងឆ្ងល់ហេតុអ្វី។

152 "ល្អ" អ្នកវិទ្យាសាស្ត្រនិយាយ "ឥឡូវសូមចាំ! យើងអាចបង្កាត់ស្ត្រីជាមួយស្វាលាយជាមួយស្វាឌី ហើយ បញ្ច្រាស់មកវិញដែរ មនុស្សប្រុសម្នាក់បង្កាត់ជាមួយស្វាឌី" វាមិនដំណើរការឡើយ។ បង្កាត់វាជាមួយសត្វផ្សេងទៀតវាមិនដំណើរការឡើយ។ ឈាមមិនលាយចូលគ្នាឡើយ រាល់ឈាមរបស់អ្នក វាទាំងអស់សុទ្ធតែឈាមខុសគ្នាទាំងអស់។

153 មានឈាមខ្លះនៅចន្លោះនេះ ហើយពួកគេមិនមានឃើញ នៅក្នុងសត្វនោះឡើយ។ អូ ហាលេលូយ៉ា ខ្ញុំមានអារម្មណ៍ថាបែបសាសនាមែនទែន ឥឡូវ។ កត់សម្គាល់។ ហេតុអ្វី? ព្រះជាម្ចាស់លាក់វាពីពួកគេ។ មិនមានឆ្អឹងនៅក្នុងពស់ ដែលដូចឆ្អឹងមនុស្សឡើយ។ ទ្រង់បានដាក់វានៅឆ្ងាយពីនោះ ដែលវាមិនអាចត្រូវបានរកឃើញដោយមនុស្សឆ្លាតឡើយ។

154 ហើយ ខ្ញុំនឹងបង្ហាញអ្នកពីកន្លែងដែលមនុស្សឆ្លាតមកពីណា កន្លែងណា—កន្លែងដែលគាត់ចេញមក។ ឃើញគាត់ មិនអាចចេញមកពីនោះបានឡើយ។

155 វាត្រូវតែមកតាមរយៈ ការបើកសម្តែង "ទ្រង់ជាព្រះគ្រីស្ទ ជាបុត្រានៃ..." "នៅលើថ្មនេះ ខ្ញុំនឹងសង់ព្រះវិហាររបស់ខ្ញុំ ហើយទ្វានៃស្ថាននរកមិនអាចឈ្នះវាបានឡើយ" ការបើកសម្តែងខាងវិញ្ញាណ។ តើ—របៀបដែលអេបិលដឹងពីការថ្វាយកូនចៀម ដែលផ្ទុយពីកាអ៊ីនថ្វាយផលផ្លែពីចំការជាយ៉ាងណា? វាជាការបើកសម្តែងខាងវិញ្ញាណចំពោះគាត់។ អ្នកមិនអាចទទួលបាន តាមរយៈការអធិប្បាយបានឡើយ។ អ្នកមិនអាចទទួលបានតាមរយៈនិកាយដែរ។ អ្នកទទួលពីស្ថានសួគ៌។

156 ឥឡូវ មើលពីសត្វពស់ ដែលសត្វពស់ដំបូង។ ចូរគូររូបភាពពីវាឥឡូវ។ វាជាសហាមិត្តដ៏ធំមួយ។ វានៅចន្លោះរវាងស្វាឱ្យ និង មនុស្ស។ ហើយសត្វពស់ អារក្ខ លូស៊ីហ្វឺ ដឹងថានោះជាឈាមតែមួយ ដែលអាចលាយជាមួយឈាមមនុស្ស ជា ម្នាក់ដែលអាចធ្វើការជាមួយបាន។ គាត់មិនអាចធ្វើការជាមួយស្វាឱ្យឡើយ ឈាមនោះមិនអាចបញ្ចូលគ្នាបានឡើយ។ គាត់មិនអាចចូលជាមួយអ្វីដែលខុសគ្នាឡើយ។ គាត់មិនអាចដំណើរការជាមួយសត្វចៀមដែរ។ គាត់មិនធ្វើការជាមួយឈាមសេះទេ។ គាត់មិនអាចធ្វើការជាមួយឈាមសត្វបានឡើយ វាត្រូវដំណើរការជាមួយសត្វពស់(Serpent)។

157 ឥឡូវយកគាត់មក ហើយពិនិត្យតើគាត់មានភាពយ៉ាងណា។ គាត់ជាសហមិត្តដ៏ធំមួយ ជាយក្សមុនប្រវត្តិសាស្រ្ត។ នោះជាអ្វី ពួកគេអាចរកឃើញឆ្អឹងធំនោះ ហើយខ្ញុំនឹងបង្ហាញរឿងនេះក្នុងព្រះគម្ពីរ។ ឥឡូវពិនិត្យឲ្យជិត។ ត្រូវណាស់។ សហមិត្តដ៏ធំនេះ ចូរនិយាយគាត់—គាត់កំពស់ដប់ហ្វូត ស្មាធំ មើលទៅដូចមនុស្ស។ ហើយឈាមវាបន្ទាប់ពីចុះមក ប្រសព្វគ្នាសត្វមួយនឹងសត្វ ផ្សេង ទៀត។ អ្នកអាចរំលងសត្វនោះ។ ហើយវាមានលក្ខណៈជាឈាមខ្ពស់ ជាទម្រង់ ជីវិតខ្ពស់មួយ រហូតដល់ឈានចូលដែនរបស់មនុស្ស។ ប៉ុន្តែការតភ្ជាប់ចុងក្រោយ នៅទីនេះនៅចន្លោះនេះ ត្រូវបានកាត់ផ្តាច់។ តើប៉ុន្មាននាក់ដឹងថា អ្នកវិទ្យាសាស្រ្តមិនអាចរកឃើញការតភ្ជាប់ដែលបាត់? អ្នកទាំងអស់គ្នាសុទ្ធតែដឹង។ ហេតុអ្វី? នៅទីនេះគាត់ជាសត្វពស់។ នៅទីនេះវាជា សហាមិត្តធំមួយ។

ហើយអារក្ខចុះមក ឥឡូវវានិយាយ "ខ្ញុំអាចជម្រុញបាន។"

158 ឥឡូវពេលនេះអ្នកទៅមើលស្រ្តី និង សកម្មភាពរបស់ស្រ្តី អ្នកចាំទេ អ្នកត្រូវបានតែងតាំងដោយអារក្ខ(ហើយនោះវាមិនមែនជាប្រពន្ធអ្នកទេ)។

159 កត់ចំណាំ ឥឡូវ អារក្ខចុះមក និង ចូលទៅក្នុងសត្វពស់។ ហើយវាឃើញអេវ៉ានៅសួនអេដែន ស្រោត ហើយ វានិយាយពីផ្លែនៅកណ្តាលសួន។ *កណ្តាល* មានន័យថា "ពាក់កណ្តាល" ហើយបន្តទៀត អ្នកយល់ទេ នៅកណ្តាលជំនុំដែលមានភាពចម្រុះលាយគ្នា។ ហើយគាត់និយាយ "ឥឡូវ វាសប្បាយ វាស្រស់ ល្អដល់ភ្នែក" តើវាធ្វើអ្វី?វាចាប់ផ្តើមបង្កើតការស្រឡាញ់ដល់អេវ៉ា ហើយ វារស់ជា មួយនាងដូចជាប្តី។

160 ហើយនាងឃើញថាវាសប្បាយដូច្នេះនាងទៅប្រាប់ប្តីរបស់នាងប៉ុន្តែនាង បានមានផ្ទៃពោះដោយសាតាំងរួចហើយ។

161 ហើយនាងបង្កើតបានកូនមួយរបស់នាង ដែលមានឈ្មោះថាកាអ៊ីន ជាកូនរបស់សាតាំង។

"ឥឡូវ" អ្នកនិយាយ "ខុសហើយ។"

162 មិនអីទេ យើងនឹងរកឲ្យឃើញថាតើវាខុស ឬ ត្រូវ។ "ហើយយើងនឹងដាក់ភាពជាសត្រូវរវាងពូជអ្នក និង ពូជសាតាំង។" អ្វី? ពូជសាតាំង! នាងមានពូជ ហើយវាមានពូជ។ "ហើយវានឹងធ្វើឲ្យស្នាមក្បាលអ្នក ហើយ អ្នកនឹងធ្វើឲ្យមានស្នាមកែងជើងរបស់លោក។" ហើយ *ស្នាមជាំ* មានន័យ "ធ្វើការទទួលទណ្ឌកម្ម" ឥឡូវមាន "ពូជ" របស់អ្នកដែលជាសាតាំង។

ឥឡូវ កត់សម្គាល់ មានមនុស្សពីរនាក់ចេញមក។

163 ឥឡូវ មានសត្វពស់ ពេលវាឈរនៅទីនោះ នេះជាយក្សនៃសហមិត្តដែលឈរនៅទីនោះ។ វាមានកំហុសដោយការធ្វើកំផិតជាមួយប្រពន្ធអ័ដាំ។ តើបាបនៅឯណាសព្វថ្ងៃនេះ? តើអ្វីដែលធ្វើឲ្យមានរឿងបែបនោះនាសព្វថ្ងៃ?ឥឡូវខ្ញុំ—ខ្ញុំ... ពិតណាស់អ្នកអាចចាប់បានអ្វីដែលខ្ញុំកំពុងនិយាយ។ ហើយពីមុនវាយ៉ាង នោះ។

ហើយពេលវាបានកើតឡើង ព្រះជាម្ចាស់ចាប់ផ្តើមមានបន្ទូលហៅអ័ដាំ និង អេវ៉ា។

ហើយគាត់និយាយថា "ខ្ញុំនៅអាក្រាត។"

ហើយ ទ្រង់មានបន្ទូលថា "នរណាប្រាប់អ្នក ថានៅអាក្រាត?"

164 ដូច្នេះពួកគេចាប់ផ្តើម គំរូទាហាន ហុចកំហុសឲ្យគ្នា។ និយាយ "ល្អ ស្ត្រីដែលទ្រង់ប្រទានឲ្យទូលបង្គំ បានធ្វើវាហើយ។ នាងជាអ្នកបញ្ចុះបញ្ចូលទូលបង្គំ។"

165 ហើយនាងនិយាយថា "សត្វពស់បានឲ្យផ្លែប៉ោមមកទូលបង្គំ"? ត្រូវហើយ គ្រូអធិប្បាយ ចូរទៅមើលរឿងបន្ទាប់។

166 នាងនិយាយ "សត្វពស់បោកប្រាស់ទូលបង្គំ" តើអ្នកដឹងថាពាក្យ *បោកប្រាស់*មានន័យយ៉ាងណាទេ? មានន័យថា "បង្ខូច" នាងបែបនោះ។ អារក្ខមិនបានឲ្យ ផ្លែ ប៉ោមនាងទេ។ "សត្វពស់បានបោកប្រាស់នាង។"

បន្ទាប់ទៀតបណ្តាសារក៏មកដល់។

167 ទ្រង់មានបន្ទូល "ដោយព្រោះអ្នកស្តាប់តាមសត្វពស់ជៀសជាងស្តាប់ប្តី អ្នកបានយកជីវិតចេញពីផែនដីហើយ។ ហើយអ្នក—អ្នកនឹងចម្រើនទុក្ខព្រួយរបស់អ្នកឡើង ហើយគំនិតរបស់អ្នកនឹងត្រូវការតែប្តី" និងមានរឿងតទៀត។

168 "ដោយព្រោះអ្នកស្តាប់តាមប្រពន្ធរបស់អ្នក ជៀសជាងស្តាប់យើង (យើងយកឯងចេញពីដី ជាជីវិតខ្ពស់មួយ) ឯងនឹងត្រូវត្រលប់ទៅជាដីវិញ។"

169 "រីឯ សត្វពស់ដោយព្រោះឯងធ្វើដូច្នេះ នឹងត្រូវដកជើងចេញ។ ឯងនឹងត្រូវធ្វើដំណើរដោយពោះ ពេញមួយជីវិតរបស់ឯង។ ហើយឯងនឹងត្រូវគេស្អប់។ ក៏នឹងមានដីជាអាហារ។" អ្នកយល់ទេ។ នោះជាការភ្ជាប់ដែលបាត់បង់។

170 ឥឡូវនេះកាអ៊ីនកើតមក។ ពិនិត្យមើលធម្មជាតិ។ ការអ៊ីនបានមកដល់។ គាត់ជាអ្វី? គាត់ជាអ្នកជំនួញមានប្រាជ្ញាល្អិត។ គាត់ព្យួរដី។ ឆ្លាត វាងវៃ គំនិតសាសនាមានការងប់ងល់នឹងសាសនា មើលគាត់—មើលលក្ខណៈ របស់គាត់ឥឡូវ។ សូមបន្តជាមួយខ្ញុំពីរបីនាទីទៀត។

171 ទីនេះ គាត់ចូល។ គាត់ដឹងពីក្រមសីលធម៌។ គាត់ចង់ទៅព្រះវិហា។ គាត់សង់ក្រុមជំនុំមួយផ្ទាល់ខ្លួន ថ្វាយខ្លួនជាតង្វាយ។ យកអាសនាមក និង អ្វីទាំងអស់ដាក់ផ្កាលើនោះ។ ដាក់ចំការ...ផ្លែបានមកពីចំការ ផលផ្លែបានពីចំការ ថ្វាយដល់ព្រះជាម្ចាស់។ និយាយ "នៅទីនេះព្រះអម្ចាស់។ ទូលបង្គំដឹងថា ពួកទូលបង្គំបរិភោគផ្លែប៉ោម ដែលជាហេតុនាំឲ្យមានរឿងនោះ។" មានការទូទាត់ខ្លះរបស់គាត់ មានប្រភេទគំនិតដូចគ្នា។ បង្ហាញមកថាវាបានពីណា។ នាំយកផ្លែប៉ោមមកចេញពីចំការ ដាក់វានៅទីនោះ និយាយ "នេះជាការសងថ្លៃលោះ។"

ព្រះជាម្ចាស់មានបន្ទូលថា "វាមិនមែនជាផ្លែប៉ោមឡើយ។"

172 ប៉ុន្តែ ដោយការបើសម្តែងខាងវិញ្ញាណ អេបិលដឹងថាជាឈាម។ ដូច្នេះគាត់យកចៀមមក វះបំពង់ក ហើយ វាក៏ងាប់។

173 ហើយព្រះមានបន្ទូល "ត្រូវហើយ។ នោះជាអ្វីដែលត្រូវធ្វើ។ វាជាឈាម។" អ្នកដឹងហើយថាជាឈាមអ្វីដែលខ្ញុំកំពុងតែនិយាយ។ ត្រូវណាស់។ "គឺជាឈាមជាអ្នកធ្វើវា។"

174 ឥឡូវ ពិនិត្យ។ ដូច្នេះពេលកាអ៊ីនបានឃើញពីមុខងារដ៏វិសុទ្ធ ជាបងប្អូនត្រូវបានទទួលដោយព្រះជាម្ចាស់ ហើយសញ្ញា និង ការអស្ចារ្យកើតមានឡើង គាត់ក៏ច្រណែន។ គាត់និយាយ "យើងទុករឿងនេះចុះសិន។" សម្លឹងមើលបងប្អូនរបស់គាត់មើលកូនចៅ សព្វថ្ងៃនេះ។ "ឥឡូវខ្ញុំឆ្លាតជាងគាត់" ដូច្នេះគាត់ក៏ខឹង។ តើ *កំហឹង* មកពីណា? អ្នកអាច និយាយថា នោះជាកំហឹង...? គាត់សម្លាប់បងប្អូនរបស់ខ្លួន។ គាត់ជាឃាតករ។

175 តើអ្នកអាចហៅព្រះជាម្ចាស់ថាជា ឧក្រិដ្ឋជន? ហើយអ័ដាំជាកូនរបស់ព្រះ។ ព្រះគម្ពីរនិយាយបែបនោះ "អ័ដាំជាកូនរបស់ព្រះ" មានភាពសុទ្ធនៅទីនោះ។ អ័ដាំជាកូនរបស់ព្រះ។ តើការច្រណែន និង ការឈ្នានីស និង អ្វីគ្រប់យ៉ាង មិនអាចចេញមកពីខ្សែស្រឡាយបរិសុទ្ធបានទេ។

176 វាត្រូវតែចេញមកពីកន្លែងផ្សេងទៀត។ [ខ្សែរអាត់សម្លេងទទេ—Ed] ហើយ វាមកតាមរយៈសាតាំង ជាឃាតករ ដែលចាប់ផ្តើម។ ព្រះគម្ពីរនិយាយ "វាជាមេកុហកនិងជាឃាតករជាអ្នកចាប់ផ្តើម។" នោះគឺវាយ៉ាងដូច្នោះ។ ហើយវាសម្លាប់បងប្អូនរបស់ខ្លួន។

177 ហើយនោះជារបៀបនៃការសុគតរបស់ព្រះគ្រីស្ទ។ ដូច្នេះ ចេញពីនោះមក គាត់បង្កើតបានសេត ដែលជំនួសកន្លែងរបស់គាត់។ ស្លាប់ កប់ និងការរស់ឡើងវិញនៃព្រះគ្រីស្ទ។

178 ហើយសម្លឹងមើល ដូច្នេះ ឥឡូវយក្សរបស់អ្នកបានមក។ ដូច្នេះកាអ៊ីនទៅទឹក ដីណូដ។ បើសិនជាឪពុករបស់គាត់ជាយក្សធំដែលមានទំនាក់ទំនង ដូច្នេះតើកាអ៊ីនមានរូបរាងបែបណា? ដូចឪពុករបស់គាត់។ ហើយគាត់ទៅកាន់ទឹកដីណូដ និង យកបងប្អូនស្រីរបស់គាត់ម្នាក់ជាប្រពន្ធ។

179 ជាវិធីតែមួយគាត់អាចធ្វើបាន។ មិនមានស្ត្រីណាអាចមកទៀតឡើយ គឺមានតែតាមរយៈអេវ៉ាប៉ុណ្ណោះ។ ពួកគេប្រកាសថាខ្លួនមានកូនប្រុសស្រីចិតសិបនាក់។ បើ—បើមិនមានស្ត្រី...ព្រះគម្ពីរមិនបានកត់ត្រា ពីស្រីដែលពួកគេបានកើតមកពេលណាទេ ប្រាប់តែបុរស។ ហើយពេល បើមិនមានស្ត្រីក្រៅពីអេវ៉ា ពេលគាត់ស្លាប់ សញ្ជាតិរបស់មនុស្សប្រាកដជាចប់ហើយ។ នាងត្រូវតែមានកូនស្រីៗ។ ហើយគាត់ក៏រៀបការជាមួយប្អូនស្រីរបស់ខ្លួន។

180 គាត់ទៅទឹកដីណូដ ហើយ យក—យកប្រពន្ធគាត់។ ហើយពេលរៀបការជាមួយនាងនៅទីនោះ នោះជាកន្លែងពួកគេកើតមានយក្សធំៗ ដែលជាការធ្លាក់ចុះរបស់កូនព្រះ តាមរយៈឪពុករបស់ពួកគេ ជាអារក្ស តាមរយៈកាអ៊ីន។ នោះជាចំនុចតភ្ជាប់ដែលបាត់។

181 ហើយមើលពីពូជរបស់សត្វពស់។ ចូរសម្លឹងមើល។ ចងចាំ ពូជរបស់ពស់ជាសាសនា។ មើលវាចាប់ផ្តើមប្រែប្រួលនាឥឡូវ រយៈពេលពីរបីនាទី។ វាបន្តទៅ ជាពូជនៃសត្វពស់។ មានអ្វីកើតឡើងចំពោះគេ? ឥឡូវសូមឲ្យខ្ញុំអានអ្វីមួយនៅ ទីនេះ ខ្ញុំសរសេរនៅរសៀលនេះ។

182 អ្វីដែលមកពីខ្សែស្រឡាយអេបិល? សូមស្តាប់រឿងនេះ។ ត្រូវណាស់។ តាមរយៈនោះមានអេបិល។ បន្ទាប់ពីអេបិលមានសេត។ បន្ទាប់ពីសេតមានណូអេ។ បន្ទាប់ពីណូអេមានសិម។ បន្ទាប់ពីសិមមានអាប្រាហាំ។ បន្ទាប់ពីអាប្រាហាំមានអ៊ីសាក។ បន្ទាប់ពីអ៊ីសាកមានយ៉ាកុប។ បន្ទាប់ពីយ៉ាកុបមានយូដា។ បន្ទាប់ពីយូដាមានដាវីឌ។ បន្ទាប់ពីដាវីឌមានព្រះគ្រីស្ទ មានភាពឥតខ្ចោះ។

183 សម្លឹងមើលទៅវិញពីរបៀបដែលព្រះវិញ្ញាណនៃព្រះរស់ក្នុងអេបិល។ មើលពីរបៀបដែលរស់ក្នុងសេត។ មើលពីរបៀបរស់នៅក្នុងយូដា។ មើលរបៀបដំណើរការក្នុងដេវីឌ។ មើលពីវិញ្ញាណតែមួយដែលត្រាស់ហៅ តាមរយៈពូជសាសន៍ តរៀងចុះមក។ មិនថាពួកគេធ្វើអ្វី ពួកគេត្រូវបានកំណត់មកទុកជាមុន។

184 មើលទៅយ៉ាកុប ជាអ្នកស្មោគគ្រោក...ខ្ញុំមិននិយាយថានេះតាមរយៈការប្រមាថ។ ប៉ុន្តែយ៉ាកុបជាមនុស្សអៀនប្រៀន នៅតែពីក្រោយជាយអាវរបស់ម្តាយគ្រប់ពេល រត់លេង ក្មេងប្រុសដូចស្រីតូចមួយ។ បានដាក់អ្វីមួយលើខ្លួនគាត់ចេញទៅបញ្ឆោតឪពុករបស់ខ្លួន ដើម្បីបានព្រះពរ ប៉ុន្តែវាត្រូវបានប្រគល់ឲ្យគាត់តាំងពីកំណើតគ្រឹះផែនដីផង។ ប្រាកដណាស់ វាបានកើតឡើង។

185 គាត់ចេញទៅ ហើយ កុហកឪពុកក្មេករបស់គាត់ និង យកដំបងអុចៗ ឈើស្នាមអុច មកដាក់ក្នុងទឹក ដើម្បីបង្កើលសត្វជើងបួនពេលវាផើម ដើម្បីឲ្យបានបង្កើតកូនមានស្នាមអុច ដូច្នេះគាត់អាចបញ្ឆោត និង ទទួលបានសត្វចតុបាតុនោះ។ ព្រះប្រទានពរដល់គាត់ក្នុងរបៀបនោះ។ នោះជាការពិត។

186 វរហើយដល់អ្នកដែលនិយាយអ្វីពីយ៉ាកុប។ អ្នកដឹងហើយថាអ្វី—អ្នកដឹងថាព្យាការីក្លែងក្លាយនិយាយ...ឬ គាត់ថ្លែងទំនាយបានត្រឹមត្រូវ។ បាឡាម និយាយ "នរណាដែលប្រទានពរគាត់ ក៏នឹងបានពរវិញដែរ ហើយអ្នកដែលផ្តាសសារគាត់នឹងត្រូវផ្តាសសារវិញ។"

187 "ខ្ញុំបានយក...យ៉ាកុប។ ខ្ញុំបានឃើញថាគាត់នៅ...ក្នុងទឹកដីខ្លាំងក្លា។ ជាឥន្ទ្រីកាយសំបុក្រ ខ្ញុំកក្កូរគាត់ និង យកគាត់ចេញ" ហាលេលូយ៉ា! "មិនមែនដោយរិទ្ធិដោយអំណាច ប៉ុន្តែដោយព្រះវិញ្ញាណ ព្រះបន្ទូលរបស់ព្រះជាម្ចាស់។"

188 សម្លឹងមើលពីអ្វីដែលតមកដល់ភាពឥតខ្ចោះ។ ព្រះវិញ្ញាណនោះបានធ្វើការមកដល់ព្រះគ្រីស្ទដែលល្អឥតខ្ចោះ តមកគ្រប់គ្នានៃបុព្វបុរស ចុះរៀងមក។ មិនថាពួកគេធ្វើអ្វី ពួកគេជាពូជនៃសេចក្តីសុចរិត។

189 ហើយ នៅទីនេះ ពេលអ័ប្រាហាំជាអ្នកសុចរិត...សិរីល្អ! អូ ខ្ញុំមានអារម្មណ៍ពីព្រះជាម្ចាស់ដ៏ពិត។ ពេលអ័ប្រាហាំជាអ្នកសុចរិតជួប ស្តេច មិលគីស្សាដេកដែលជាអង្គទ្រង់ព្រះជាម្ចាស់ផ្ទាល់!

190 នរណាជាមិលគីស្សាដេក? "ជាស្តេចសាឡិម ដែលជាស្តេចក្រុងយេរូសាឡិម ជាស្តេចនៃសន្តិភាព។ ទ្រង់គ្មានបិតា។ ទ្រង់គ្មានមាតា។ ទ្រង់មិនមានថ្ងៃចាប់ផ្តើម ក៏គ្មានថ្ងៃបញ្ចប់នៃព្រះជន្ម។" នៅតែជាអង្គដដែល ទ្រង់នៅមានព្រះជន្មគង់នៅ។ "ទ្រង់មិនបានប្រសូត្រមក ទ្រង់មិនដែលសុគត ទ្រង់មិនដែលមានមាតា ឬ បិតា។ ចាប់ផ្តើមនៃព្រះជន្ម ឬ ទ្រង់មិនមានថ្ងៃបញ្ចប់" ប្រាប់ខ្ញុំមកតើនោះជាអង្គណា។ ជាព្រះដ៏នៅអស់កល្ប ដែលយើងហៅថា...

191 អូ ខ្ញុំភ្លេចអ្វីដែលអ្នកហៅនោះឥឡូវ។ ទេវកថា គឺអ្វីដែលជាបែបនោះ។ ដូចជា...មិនមែនជា ទេវកថា ប៉ុន្តែជាអ្វីដែលបានសម្តែងមក។ ដូចជាទ្រង់បានយាងមកអ័ប្រាហាំនៅក្នុងតង់ ដូចជាទេវតា និង ថ្លែងទំនាយហើយ មានបន្ទូលប្រាប់សារ៉ាពីការនាងសើច នៅពីក្រោយលោក និង អ្វីផ្សេងទៀត។ ជាអ្វីមួយដូចគ្នាដែរ។

192 ហើយ នេះគឺជាទ្រង់ ។ គាត់ជួបស្ដេចមិលគីស្សាដេក។ និង ជីតា...ជីតាទួត អ័ប្រាហាំ ក្នុងពូជសុចរិត ថ្វាយតង្វាយ១០ភាគដល់ស្ដេចម៉ិលគីស្សាដេក ហើយ វាជា ការបែងចំណែកនៃចៅទួតរបស់គាត់តចុះមក ជាពូជសុចរិត។

193 ឥឡូវនេះមានពូជនៃ—សត្វពស់។ ឥឡូវសូមចាំ វានឹងមានភាពទាស់ទែងគ្នា សង្គ្រាមរវាងពួកគេ។

194 ពូជរបស់សត្វពស់តរៀងមក ហើយ វាបានបង្កើតជាអ្វី? ឥឡូវមើលពីប៉ុន្មានឆ្នាំ ដំបូង។ ឥឡូវមើលអ្វីដែលកើតឡើង។ យើងនឹងអាន ព្រោះខ្ញុំទើបតែបានពិនិត្យវា ហើយ។ ពូជរបស់សត្វពស់បង្កើតបានកាអ៊ីន។ កាអ៊ីនទៅទឹកដីណូដ បង្កើតបាន យក្ស ហើយពួកគេចូលទៅទឹកដីរបស់ណូអេ។

195 ពួកគេឆ្លាត មានការអប់រំ ជាមនុស្សឆ្លាត។ តើត្រូវទេ? ពួកគេជាអ្នកសាងសង់ អ្នកបង្កើត អ្នកវិទ្យាសាស្ត្រ មិនមែនមកតាមរយៈពូជសុចរិតឡើយ ប៉ុន្តែមកពីពូជ សាតាំង សត្វពស់។ ពួកគេជាមនុស្សជា—ជាអ្នកវិទ្យាសាស្ត្រ និងជាជាងសាង សង់ ជាមនុស្សអស្ចារ្យ ជាអ្នកបង្រៀនអប់រំ។ ខគម្ពីរនិយាយយ៉ាងនោះ។ ពួកគេ កែច្នៃស្ពាន់។ ពួកគេកែច្នៃដែក។ គេប្រើលោហៈ និង សង់ផ្ទះ និងអ្វីផ្សេងទៀត។ ខ គម្ពីរ និយាយដូច្នោះ។ ហើយពួកគេសើចចំអកពូជស្ត្រី ណូអេ ជាអ្នកសុចរិត។ នោះ ត្រូវទេ? [ក្រុមជំនុំនិយាយ "អាម៉ែន"—Ed]

196 ចូរតាមពួកគេបន្តិចទៀត។ ហើយ យើងឃើញគេនៅទូកធំ អ្វីគ្រប់យ៉ាងត្រូវ បំផ្លាញ។ មានអស់ទាំងការផ្គុំនៃបាប ហើយ ពួកគេធ្វើការគ្រប់គ្រង និង ជា អ្នកឆ្លាត និង វាងវៃ។ រហូតដល់ ព្រះជាម្ចាស់ទតមើល មិនមានអ្នកនៅច្រើន ទេ ដូច្នេះទ្រង់យកណូអេ និង គ្រួសារគាត់ទៅដាក់ក្នុងទូក ហើយ បង្អុរភ្លៀងចុះ និង បំផ្លាញគ្រប់ទាំងអស់។ ការយកអេណុកឡើង។ ត្រូវទេ? [ ក្រុមជំនុំនិយាយ "អាម៉ែន"—Ed។] មានអស់ទាំងពូជ ស្ទើរតែពូជទាំងអស់ ប៉ុន្តែទ្រង់មានបំណង ព្រះទ័យក្នុងការសម្រេច។

197 ឥឡូវ ណូអេ និង ពួកកូនប្រុសរបស់គាត់ ដែលចេញមក ហាំ សិម និង យ៉ាផែត ចេញពីខ្សែសុចរិត។

198 តើគ្រាប់ពូជមានភាពយ៉ាងណាពីមុន? គ្រាប់ពូជចេញមកពីទូក ដូចដែលវា បានចាប់ផ្ដើមពីដំបូងដែរ តាមរយៈស្ត្រី ជាប្រពន្ធរបស់ពួកគេ។ ពួកគេសប្បាយ

គ្រាប់ពូជសាតាំង តាមរយៈទូកធំ ដូចជាអេវ៉ាញាត់ណែនដោយពូជសាតាំង ផ្តល់កំណើតឲ្យកាអ៊ីន តាមរយៈស្ត្រី។

199 អ្នកបានដាក់ពួកស្ត្រីលើវេទិការបស់អ្នកជាអ្នកអធិប្បាយ ព្រះគម្ពីកាត់ទោសពីរឿងនោះ! ប៉ុលនិយាយ"បើនរណាម្នាក់ប្រាប់ខ្លួនឯងថាជា ហោរា ឬដោយវិញ្ញាណ ចូរឲ្យគាត់ដឹងថាអ្វីដែលខ្ញុំសរសេរគឺជាការកាត់ទោសមកពីព្រះជាម្ចាស់ តែបើគាត់ព្រងើយ ចូរឲ្យគាត់ក្លាយជាមនុស្សឥតប្រាជ្ញាទៀតចុះ។"

200 នោះហើយជាហេតុផល ដែលខ្ញុំដើរចេញពីក្រុមជំនុំបាបទីស្ត មកដល់ត្រង់នេះ។ បងប្អូនប្រុស ហ្វ៊ីមេននៅទីនេះ ពេលមុននេះ ខ្ញុំគិតថាគាត់នៅទីនោះនៅយប់នោះ។ លោកបណ្ឌិត ដេវីស និយាយថា"អ្នកឈរនៅទីនេះ ហើយតាំងស្ត្រីទាំងនេះជាអ្នកអធិប្បាយ"

ខ្ញុំនិយាយ "ខ្ញុំនឹងមិនធ្វើបែបនេះទេ។ ទេ ប្រាកដណាស់។"

គាត់និយាយថា "ល្អ ខ្ញុំនឹងដេញអ្នកទៅក្រៅ។"

201 ខ្ញុំនិយាយ "ដេញខ្ញុំទៅក្រៅនោះប្រសើរជាង" ខ្ញុំនិយាយ "នេះគឺជាព្រះបន្ទូលរបស់ព្រះជាម្ចាស់ ហើយវាបានកាត់ទោសអ្វីៗ។ ហើយខ្ញុំមិនអាចចាប់ទុកអ្វីដែលព្រះជាម្ចាស់កាត់ទោសឡើយ។" ទេ លោក។

202 ធ្លាប់មានអ្នកធ្វើដូច្នេះ គឺកំពុងបង្ហាញថាពួកគេជាគ្រូខុសឆ្គង។ ព្រះគម្ពីរនិយាយថាពួកគេនឹងក្លាយជាយ៉ាងនោះ។ "បញ្ឆោតអ្នកដែលត្រូវបានជ្រើសដែលអាចសម្រេចទៅរួច" អ្នកនៅទីនោះ។

203 កត់សម្គាល់របៀបនេះឥឡូវ។ ហើយ ចេញពីនោះ បន្ទាប់មក មានហាំ ហាំជាមួយប្រពន្ធគាត់និង ពួកគេ។ ទ្រង់បានដាក់បណ្តាសាលើគាត់។ ចេញពីហាំមានណារុត ជាអ្នកកសាងបាប៊ីឡូន។ ចេញពីបាប៊ីឡូនមានក្រុមជំនុំកាតូលិក ជាអ្នកចាប់ផ្តើម។ តមកមានអ័ហាប់។ ចេញពីអ័ហាប់ ចូលដល់អ៊ីស្ការីយុត ធ្វើឲ្យមានបន្តមក អ្នកប្រឆាំងព្រះគ្រីស្ទ។

204 ហើយ នៅថ្ងៃចុងក្រោយ មានវិញ្ញាណមេប្រឆាំងព្រះគ្រីស្ទ និង វិញ្ញាណព្រះគ្រីស្ទ។ វិញ្ញាណនៃអ្នកទាស់នឹងព្រះគ្រីស្ទ។ វិញ្ញាណអ្នកទាស់នឹងព្រះគ្រីស្ទនិយាយ "សម័យកាលការអស្ចារ្យកន្លងបាត់ហើយ។" វិញ្ញាណរបស់ព្រះគ្រីស្ទនិយាយថា "ទ្រង់នៅដូចម្សិលមិញ ថ្ងៃនេះ និង រហូតទៅ។" វិញ្ញាណមេប្រឆាំង

នឹងព្រះគ្រីស្ទនិយាយថា "វាមិនខុសគ្នាទេ បើអ្នកជ្រមុជទឹកដោយនាម 'ព្រះវរបិតា ព្រះរាជបុត្រា ព្រះវិញ្ញាណបរិសុទ្ធ' ការចាក់ទឹក ប្រោះទឹក អ្វីក៏ដោយ វាមានន័យដូចគ្នា" ព្រះគម្ពីរនិយាយថា ព្រះជាម្ចាស់មិនប្រែប្រួលឡើយ ហើយ ទ្រង់មិនអាចផ្លាស់ប្តូរដែរ។ តើអ្នកបម្រើនរណា? វាស្រេចតែអ្នក។

205 ឥឡូវអ្នកនិយាយ "តើពួកគេអាចរស់នៅជាមួយគ្នាបានទេ? អ្នកនិយាយ នៅក្នុងទូកធំបងប្អូនប្រុសប្រាណហាំ អ្នកមានទាំងហាំ និង សេតនៅក្នុងនោះ។" នោះត្រឹមត្រូវ ពិតជាត្រូវ។ ហាំជាអារក្ខ។ សេតមានភាពសាសនាខ្លាំង។ ត្រឹមត្រូវ។

206 ចូរមើលពិនិត្យតាមហាំ។ ត្រូវណាស់ ឥឡូវ មានហាំ និង សិត នៅលើទូកធំ ម្នាក់ជាអ្នកសុចរិត ម្នាក់ជាអ្នកទុចរិត។ មានក្អែក និង ព្រាបនៅលើទូកតែមួយ។ មានយូដាស និង ព្រះយេស៊ូវនៅក្នុងក្រុមជំនុំតែមួយ។ មានអ្នកប្រឆាំងនឹងព្រះគ្រីស្ទ និង ព្រះវិញ្ញាណបរិសុទ្ធនៅក្នុងក្រុមជំនុំតែមួយ។

207 ហើយ សព្វថ្ងៃ វិញ្ញាណដដែលនៅធ្វើការ។ "មានទម្រង់ជាព្រះជាម្ចាស់ និង សាសនា ប៉ុន្តែទោះមានទម្រង់ភាពជាព្រះ តែបដិសេធអំណាចចេស្តា បើបែបនោះមានន័យថាបែរចេញ។" ព្រះវិញ្ញាណបរិសុទ្ធប្រកាស "ព្រះយេស៊ូវគ្រីស្ទនៅដូចថ្ងៃម្សិលមិញ ថ្ងៃនេះ និង រៀងរហូតទៅ" តើផ្នែកមួយណាដែលអ្នកជ្រើស?

208 អ្នកប្រឆាំងនឹងព្រះគ្រីស្ទនិយាយ *នេះ*ជាសៀវភៅសាសនា។ "យើងនឹងថាតាមសាសនារបស់ពួកសាវក។" ខ្ញុំជម្រុញឲ្យគ្រូអធិប្បាយណាមួយក៏បាន ប្រាប់ខ្ញុំពីសាសនា របស់ពួកសាវក ដែលបានរកឃើញនៅក្នុងព្រះគម្ពីរៈ "ខ្ញុំជឿក្នុងព្រះជាម្ចាស់ ព្រះវរបិតាមានចេស្តា អង្គបង្កើតផ្ទៃមេឃ និង ផែនដី ព្រះយេស៊ូវគ្រីស្ទ ព្រះរាជបុត្រារបស់ទ្រង់។ ខ្ញុំជឿក្នុងក្រុមជំនុំបរិសុទ្ធរ៉ូមាំងកាតូលិកជាការប្រកបគ្នារបស់ពួកសាវក" អ្នករកឃើញបែបនោះនៅកន្លែងណាក្នុងព្រះគម្ពីរ? ហើយ អ្នកនៅតែបន្តវានៅក្នុង ក្រុមជំនុំ បាបទីស្ត និង មេតូឌីស្តធំរបស់អ្នក។ វាជាគោលលទ្ធិអារក្ស ហើយព្យាការីក្លែងក្លាយបង្រៀនវា។

209 ហើយ ខ្ញុំសង្ឃឹមថាខ្ញុំមិនធ្វើឲ្យអារម្មណ៍អ្នកឈឺចាប់ ប៉ុន្តែខ្ញុំកំពុងភ្ជាប់ទៅនឹងរោងឧបោសថនេះ។ អ្នកនៅទីនេះរោងឧបោសថប្រាណហាំ ចូរជៀសវាងពីរបស់ទាំងនោះ។ អ្វីដែលជឿលើការប្រកបជាសមាគមន៍ពួកបរិសុទ្ធក្នុងវិញ្ញាណ។ "មានពួកអ្នកជាកណ្តាលមួយ រវាងព្រះជាម្ចាស់ និងមនុស្ស ហើយនោះជាមនុស្សម្នាក់ជាព្រះយេស៊ូវគ្រីស្ទ។" កុំខ្វល់ថាមានម៉ារីច្រើនយ៉ាងណានោះ!

210 មើលពីគ្រាប់ពូជស្ត្រីនោះពេលនោះបានធ្វើអ្វី? មើលពីរបៀបគ្រាប់ពូជស្ត្រីស្លាយមកនៅទីនោះ?

211 មើលសព្វថ្ងៃនេះ នៅអាមេរិក។ អាមេរិកគឺជាគ្រាប់ពូជអារក្ខ។ វាជាអ្វី? នាងជាប្រជាជាតិ របស់ស្ត្រី។ អ្នកបានឮ "នេះជាពិភពរបស់ស្ត្រី។" ជាការត្រឹមត្រូវ។ វាជាប្រជាជាតិរបស់ស្ត្រី។ វាបានដាក់ជាគំរូ។

212 ខ្ញុំបានទៅទីនោះ មិនជាយូប៉ុន្មានទេទៅស្វីតហ្សឺឡែន។ ស្ត្រីម្នាក់និយាយថា...តូចមួយ ស្ត្រីព្រះវិញ្ញាណបរិសុទ្ធនិយាយថា "អ្នកដឹងទេ បើខ្ញុំទៅអាមេរិក គេថាស្ត្រីមានសេរីភាព។"

213 ខ្ញុំនិយាយ "ចូរឲ្យខ្ញុំនិយាយប្រាប់អ្នកថាវានឹងនាំទៅជាយ៉ាងណា។" ហើយខ្ញុំចាប់ផ្តើមប្រាប់នាង។

នាងនិយាយ "អូ មេត្តាករុណា ខ្ញុំមិនចង់បានអ្វីក្រៅពីនោះឡើយ។"

ខ្ញុំនិយាយ "នោះជាអ្វីដែលវានឹងនាំឆ្ពោះទៅ។"

អ្នកដឹងទេ ពួកគេមិនធ្វើអ្វីនៅទីនោះដូចគេធ្វើនៅទីនេះឡើយ។

214 នោះជាអ្វី? ចូរឲ្យខ្ញុំបង្ហាញអ្នកថាអាមេរិកជាស្ត្រី។ លើកាក់របស់យើង ជារូបភាពស្ត្រី។ គ្រប់យ៉ាងនៅទីនេះជាស្ត្រី។

215 ប្រាប់ខ្ញុំមក មិនមានហាងបិតស្រាលួចលាក់គ្រប់គ្រាន់នៅក្នុងប្រទេសមែនទេមាន...អ្នកដាក់កន្លែងបិតស្រាលួចលាក់សែសិបផ្ទុំគ្នានៅក្នុងក្រុងនេះ ហើយដាក់កន្លែងពេស្យាបីកន្លែង ជាស្ត្រីស្អាត រមួលតាមផ្លូវ ពួកគេបញ្ជូនព្រលឹងកាន់តែច្រើនទៅស្ថាននរក ជាអ្នកស្រើបតាមពួកគេ គឺច្រើនជាងកន្លែងបិតស្រាលួចលាក់អ្នកអាចដាក់ក្នុងក្រុងនេះ។ វាជាការពិត។

216 វាជានរណា? វាជាស្ត្រី។ នាងជានរណា? នាងជាព្រះនៃប្រទេសអាមេរិក។

217 យកតារាភាពយន្តចាស់ៗទាំងនេះមក ពួកគេនៅទីនោះ ហើយរៀបការបួនប្រាំដង រស់នៅជាមួយប្តីបីបួននាក់ ខុសគ្នាក្នុងពេលតែមួយ ហើយទស្សនាវដ្តីខ្លះ បានបញ្ចេញមក និង ប្រាប់ដល់គេ យករូបភាពដែលពួកគេស្រាតមក។ ហើយអ្នកជាក្មេងស្រីៗ យកជាគំរូ (ហេតុអ្វី?) ពីព្រោះម្តាយរបស់អ្នកនៅពីមុខអ្នក ប្រហែល យាយរបស់អ្នកនៅពីមុខផង។ អ្នកឃើញទេកន្លែងដែលពូជអារក្ខធ្វើការ? ពិត ណាស់ វាគឺដូច្នេះ។

218 ហើយតើវាបានធ្វើអ្វី? វាជាសេចក្តីទុចរិតដែលតចូលមកដប់បួនដំណ ក្រោមច្បាប់ តើភាពទុចរិតនឹងជាយ៉ាងណាបើវាតចូលមកសព្វថ្ងៃ ពេលដែលពូជរបស់អ្នកសុចរិតរកមធ្យោបាយដោះស្រាយ? ហើយព្រះជាម្ចាស់មានបន្ទូល នឹងមានពេលចូលមកដល់ បើទ្រង់មិនកាត់ការងារនោះឲ្យខ្លីទេ គ្មាននរណាម្នាក់តាំងនៅបានឡើយ។ យើងនៅសម័យចុងក្រោយហើយ។ ចូរតាមប្រដេញចាប់សេចក្តីសុចរិតនៅយប់នេះ ទៅតាមក្រុងនានា!

219 អូ អ្នករកបានសមាជិកក្រុមជំនុំដែលស្មោះត្រង់ចំពោះបាបទីស្ត ព្រីសប៊ីធីរៀន និងផ្សេងទៀត តាមតែអាចទៅរួច។ ប៉ុន្តែអ្នកគ្មានអ្វីធ្វើទៀតជាមួយព្រះជាម្ចាស់ជាងទន្សាយដែលពាក់ស្បែកជើងទឹកកកឡើយ។ មិនដឹងអ្វីសោះពីវា! អ្វីដែលដឹង តើអ្នកជាគ្រីស្ទាន?

"ខ្ញុំជាកាតូលិក"

តើអ្នកជាគ្រីស្ទាន?

"ខ្ញុំជាបាបទីស្ត។"

តើអ្នកជាគ្រីស្ទាន?

"ខ្ញុំជាព្រីសប៊ីធីរៀន"

តើអ្នកជាគ្រីស្ទាន?

"ខ្ញុំជាពេនទីកុស្ត។" នោះមិនមានអ្វីធ្វើជាមួយវាឡើយ។

220 អ្នកជាគ្រីស្ទានដោយព្រោះព្រះជាម្ចាស់នោះ ដោយព្រះគុណ អ្នកបានសង្គ្រោះ។ ហើយអ្នកដឹងពីវា។ ហើយមានអ្វីផ្លាស់ប្តូរជីវិតអ្នក ដែលអ្នករស់នៅខុសប្លែក។ ហើយអ្នកជាមនុស្សថ្មី និង ជាស្នាព្រះហស្តថ្មីក្នុងព្រះគ្រីស្ទ។ ជាការពិត។

221 ប៉ុន្តែអ្នកឃើញកន្លែងណាជាពូជរបស់សត្វពស់? អ្វីទៅកាលពីមុនជាពូជរបស់សត្វពស់? អ្នកកំផិត។ អ្នកជាអ្នកតាមពីក្រោយ? កំផិតជាមួយអេវ៉ា។ មានអ្វីកើតឡើងចំពោះរឿងនោះ? មានអ្វីនាំឲ្យកើតឡើង? យប់នេះមានអ្វីដែរ?

222 មើលទៅត្រើយម្ខាងទៀត កាលពីពីរបីឆ្នាំមុន ពេលដែលចម្រៀងដំបូងផលិតចេញមក។ អ្នកជាមនុស្សចាស់ៗ ពេលដែល...ពួកគេធ្លាប់ពិនិត្យចម្រៀង មុនគេអនុញ្ញាតិឲ្យច្រៀងលើវិទ្យុ។ ហើយចម្រៀងដំបូងបានផ្សាយចេញមក គឺបែបនេះ

"លូនទៅ អេម ក្មេងស្រី លូនទៅ បង្ហាញជង្គង់របស់អ្នក" និងអ្វីៗទាំងអស់ បែបនោះ។ "សើចដាក់ ប៉ា និង ម៉ាក់ ហើយ ធ្វើដាក់គេ 'ហា-ហា-ហា!'" នោះជា ចម្រៀងដំបូងដែលគេព្រមឲ្យបញ្ចេញទៅ។ តើអ្នកគិតថាអ្នកសរសេរចម្រៀងនៅ យប់នោះនៅឯណា? គាត់ស្លាប់បាត់ហើយ។

223 តើអ្នកយល់យ៉ាងណាចំពោះ ក្លារ៉ា បូ ជាអ្នកដំបូងគេ ហើយ និយាយថា *ខ្សែរ កោងគ្រោះថ្នាក់* ដែលបញ្ជូនព្រលឹងរាប់ពាន់ទៅស្ថាននរក? តើអ្នកគិតថានាងនៅឯណានៅយប់នេះ? នាងបានស្លាប់ជាយូឆ្នាំហើយ។ នាងនៅឯណា ជាមួយសាកសពរបស់នាង? ដេកនៅត្រើយម្ខាង រលួយជាមួយដី ដង្កូវបានស៊ីវាទៅ។ ហើយព្រលឹងរបស់នាងនៅត្រើយម្ខាងពីមុខព្រះដ៏សុចរិត។

224 នៅកន្លែងដែលបុរសបានយកស្ត្រីនោះ និង ធ្វើឲ្យគេក្លាយសម្លៀកបំពាក់កខ្វក់ដែលគេបាក់ ដើម្បីរុញគេចេញតាមផ្លូវមួយ និង អ្នកផ្សេងទៀត មិនសមនឹងគេ? និយាយ "តើពួកគេធ្វើដើម្បីអ្វី? ហេតុអ្វីបានអ្នកស្លៀកពាក់របស់ប្រភេទទាំងនោះ?" ព្រោះអ្នកចង់ឲ្យបុរសសម្លឹងមកអ្នក គ្មានវិធីផ្សេងទៀតដើម្បីពន្យល់ឡើយ។

225 តើអ្នកដឹងទេថា ពេលអ្នកធ្វើដូច្នោះ ហើយមនុស្សបាបចាស់ខ្លះសម្លឹងមើលអ្នក អ្នកដឹងថាមានរឿងនោះកើតឡើងទេ? នៅបាជំនុំជម្រះ...អ្នកនិយាយ "បងប្អូនប្រុសប្រាណហាំ ខ្ញុំពិតជាស្មោះនឹងប្តីដូចដែលខ្ញុំបានធ្វើ។" អ្នកនឹងត្រូវបានរាប់ថាមានកំហុសនៃការធ្វើកំផិតហើយ។ ព្រះយេស៊ូវមានបន្ទូល "អ្នកណាដែលសម្លឹងមើលស្ត្រីដោយសម្រើប នោះបានធ្វើការកំផិតជាមួយនាងក្នុងចិត្តហើយ" ពេលបុរសនោះត្រូវឆ្លើយពីការធ្វើកំផិត តើនរណាដែលជាអ្នកបង្ករវាឡើង? របៀបដែលអ្នកស្លៀកពាក់ខ្លួនអ្នក និង បង្ហាញពីអ្នកផ្ទាល់។

226 ឥឡូវខ្ញុំមិននិយាយថា អ្នកស្លៀកពាក់ដូចអ្នកផ្សេង ដែលចេញពីហិបបុរាណឡើយ។ ប៉ុន្តែសូមឲ្យអ្នកអាចមើលទៅដូចជាស្ត្រីផង។

227 ចេញពីនេះ ទៅ និង ដោះខោអាវចេញ អ្នកស្លៀកខ្លីសែនខ្លី ហើយចងបូតូចមួយជុំវិញបែប*នោះ* ហើយកូនសម្លាញ់របស់អ្នក ភ្នែកគាត់ដូចជាស្តុកបារី មានបារីនៅក្នុងមាត់ ដើរតាមផ្លូវ។ អ្នកមិនបានធ្វើបែបនោះដោយហេតុផលមិនល្អឡើយ។ អ្នកប្រហែលមិនដឹងពីការពិត ប៉ុន្តែអារក្ខកំពុង ប្រើអ្នកជាឧបករណ៍ដូចវាធ្វើជាមួយអេវ៉ាដែរ។

228 ហេតុអ្វីវាជាប្រជាជាតិស្រី្ត? ព្រោះវាបាននាំទៅរកនិកាយកាតូលិក។ សព្វថ្ងៃ ជា អ្វី? អ្នកមិនដែលឮពីគេផ្តោតពីព្រះយេស៊ូវឡើយ។ "ហេលម៉ារី! ម៉ារីមាតារបស់ព្រះ! អ្នកបរិសុទ្ធ សេស៊ីលា" អស់ទាំងអ្នកបរិសុទ្ធ អ្នកបរិសុទ្ធដែលស្លាប់។ នៅត្រង់នេះ មិនជាយូប៉ុន្មាន តមក...

229 ខ្ញុំធ្លាប់ទៅមិកស៊ិកកូ កាលពីឆ្នាំទៅ។ មានស្រ្តីក្រីក្រម្នាក់ ដាច់ដោច។ ជង្គង់របស់នាង យកថ្នាំចេញមកបែបនេះ យំ ហើយឱបដៃ។ ហើយឪពុកដើរមកជាមួយកាន់យកកូនតូចពីរនាក់ ពួកគេកំពុងតែយំ ម្តាយក៏រងទុក្ខបែបនោះដែរ ព្រោះស្រ្តីម្នាក់ដែលគេហៅថាជាអ្នកបរិសុទ្ធ បានស្លាប់។ ពួកគេបានដាក់នាងនៅភ្នំ។ អ្នកដែលស្រលាញ់នាងខ្លះបានសំលាប់នាង។ ហើយនាងត្រូវបានគេសំលាប់ បែបនោះជាកាពិត នាងជាអ្នកកាតូលិក។ ដូច្នេះនាងក៏ទៅធ្វើការកែប្រែចិត្ត ហើយនាងត្រូវបានទាញមកចម្ងាយពីរម៉ាលកាត់ថ្មក្រាលផ្លូវដើម្បីធ្វើការកែប្រែចិត្ត។

230 បងប្អូនបើសិនជាមានអ្វីដែលខ្ញុំត្រូវធ្វើព្រះយេស៊ូវគ្រីស្ទសុគតជាឥតប្រយោជន៍ ហើយ។ ដោយព្រះគុណ ខ្ញុំបានសង្រ្គោះ ហើយមិនដោយ—ដោយខ្លួនខ្ញុំឡើយ ប៉ុន្តែដោយព្រះទ័យរបស់ព្រះជាម្ចាស់និង ដោយសេចក្តីល្អនៃព្រះជាម្ចាស់។

231 អ្នកធ្វើសេចក្តីរាយការណ៍សួរខ្ញុំ និយាយថា "លោក ប្រាណហាំ..." ក្មេង—ក្មេងប្រុសតូច បានស្លាប់ ហើយបាននាំឲ្យរស់វិញ នឹងមានអ្វីពីរបីទៀតនៅទីនោះ។ មានអ្នកកាតូលិក បីម៉ឺននាក់...ទេ ខ្ញុំសូមអភ័យទោស។ វាគឺពីរម៉ឺននាក់។ បីម៉ឺនគឺនៅអាហ្រ្វិក។ អ្នកកាតូលិកពីរម៉ឺននាក់ទទួលព្រះគ្រីស្ទ ជាព្រះអង្គសង្រ្គោះផ្ទាល់ខ្លួន នៅពេលតែមួយ ពេលរឿងនោះកើតឡើង គឺនៅក្រុងមិកស៊ិកកូ។ ហើយ សង្ឃដទៃទៀត ពួកគេមិនអាចនិយាយអ្វីបានឡើយ ច្រើនពេក ចាប់ផ្តើមធ្វើកុប្បកម្ម។ មានច្រើនពេកនៅផ្នែកម្ខាង។ ដូច្នេះគាត់និយាយ "លោកប្រាណហាំ តើអ្នកជឿទេថាពួកអ្នកបរិសុទ្ធរបស់យើងអាចធ្វើដូច្នេះដូចអ្នកធ្វើ?"

232 ដោយដឹងពីគោលលទ្ធិរបស់ពួកគេ ខ្ញុំនិយាយ "ប្រាកដណាស់ បើពួកគេរស់នៅ" ឃើញទេ? ដូច្នេះអ្នកមិនអាចធ្វើជាអ្នកបរិសុទ្ធរបស់កាតូលិកពេលអ្នកស្លាប់ឡើយ អ្នកដឹងហើយ។

ដូច្នេះគាត់និយាយ "អូអ្នកមិនអាចក្លាយជាអ្នកបរិសុទ្ធទេរហូតដល់អ្នកស្លាប់។"

233 ខ្ញុំនិយាយ "អ្នកអានវានៅត្រង់ណា? ប៉ុលនិយាយ 'ចំពោះអ្នកបរិសុទ្ធនៅអេភេសូ' ហើយពួកគេ ជាអ្នកដែលត្រូវបានត្រាស់ហៅពីព្រះ 'ចំពោះអ្នកបរិសុទ្ធនៅអេភេសូ' គាត់កំពុងអានសំបុត្រគាត់ ហើយអ្នកបរិសុទ្ធកំពុងនៅកន្លែងមួយផ្សេងទៀត នៅកាឡាទី និង—និង 'អ្នកបរិសុទ្ធនៅរ៉ូម' និង ផ្សេងទៀត។ អ្នក*បរិសុទ្ធ*ជាអ្នកបាន ធ្វើឲ្យបានវិសុទ្ធ' នោះជាអ្វី?"

234 គាត់និយាយ "ដោយត្រឹមត្រូវ ឥឡូវយើងមិននឹងត្រូវនិយាយឈ្លោះពីព្រះគម្ពីរទៀយ។ ពីព្រោះយើងជាក្រុមជំនុំ និងអ្វីដែលក្រុមជំនុំនិយាយ។ យើងមិនខ្វល់ពីអ្វីដែលព្រះគម្ពីរនិយាយទៀយ។ វាជាអ្វីដែលក្រុមជំនុំនិយាយ។" និយាយ "អ្វីទៅ ជាគំនិតរបស់អ្នក ពីក្រុមជំនុំកាតូលិក?"

235 ខ្ញុំនិយាយ "ខ្ញុំមិនចង់ឲ្យអ្នកសួរខ្ញុំពីរឿងនោះទៀយ។ ដោយព្រោះអ្នកសួរខ្ញុំ ខ្ញុំនឹងប្រាប់អ្នកពីសេចក្ដីពិត"

និយាយ "ល្អ ខ្ញុំចង់ឲ្យអ្នកប្រាប់ខ្ញុំពីសេចក្ដីពិត។"

ខ្ញុំនិយាយ "ជាទម្រង់ខ្ពស់បំផុតនៃវិញ្ញាណដែលខ្ញុំដឹង។"

គាត់និយាយ "តើអ្នកទទួលបានវាដោយរបៀបណា?"

236 ខ្ញុំនិយាយ "អ្វីដែលជាការទូលអង្វរជាមួយសេចក្ដីស្លាប់ គឺជាអ្នកខាងឯវិញ្ញាណ" ខ្ញុំនិយាយ "បើសិនជាពួកអ្នកបរិសុទ្ធនិយាយមកវិញ ពួកគេនឹងនៅស្ថាននរកហើយ។ ព្រោះរឿងនោះវារំលងផ្លូវឈើឆ្កាង ព្រះ—ព្រះគម្ពីររបស់ខ្ញុំនិយាយថា គាត់មិនអាចមកវិញបានទៀយ" នោះជាការត្រឹមត្រូវ។ ហើយខ្ញុំនិយាយ "បើវាដូច្នោះបើគាត់ជាអ្នកបរិសុទ្ធ វាជាអារក្ខកំពុងនិយាយបែបដូចអ្នកបរិសុទ្ធដែរ ហើយ នោះមិនមែនជាអ្នកបរិសុទ្ធ ទាំងអស់។"

237 ហើយគាត់និយាយ "ល្អ ឥឡូវ ត្រឹមតែមួយនាទី" និយាយ "អ្នកទូលអង្វរជាមួយអ្នកស្លាប់ ដែរ"

ខ្ញុំនិយាយ "នៅឯណា?"

គាត់និយាយ "ព្រះយេស៊ូវដែលបានសុគត។"

238 ខ្ញុំនិយាយ "ប៉ុន្តែទ្រង់បានរស់ឡើងវិញហើយ។ ទ្រង់មិនសុគត់ទៀយ។ ប៉ុន្តែទ្រង់នៅរស់វិញ ដើម្បីធ្វើការទូលអង្វរ និង ធ្វើជាកណ្ដាលរវាងព្រះជាម្ចាស់ និងមនុស្សៗ។"

239 "ខ្ញុំគឺជាអង្គដែលបានសុគត ហើយ រស់ឡើងវិញ ហើយនឹងនៅមានព្រះជន្មរស់រហូតផង។ ខ្ញុំមានកូនសោនៃសេចក្ដីស្លាប់ និង ស្ថាននរក។" "អ្នកណានឹងមកចូរឲ្យគាត់មកនឹងផឹកទឹកជីវិតដោយឥតបង់ថ្លៃ" របស់ខ្ញុំ! ជាព្រះជាម្ចាស់។ នោះជាព្រះជាម្ចាស់របស់យើង។

240 ហើយពូជរបស់អ្នកសុចរិតជិតផុតហើយ។ និយាយទៅកាន់មនុស្សអំពីរឿងនេះ។ និយាយជាមួយមនុស្សពីការត្រលប់ទៅតាមរបៀបព្រះគម្ពីរ។ និយាយទៅកាន់មនុស្សពីការអស្ចារ្យ។ និយាយទៅកាន់មនុស្សពីអស់ទាំងនោះ។ ក្រុមជំនុំរបស់ពួកគេ "មិនជឿឡើយ" ដូច្នេះពួកគេជាកូនឥតខាន់ស្លាចំពោះព្រះជាម្ចាស់។ ព្រះគម្ពីរនិយាយថា បើយើងមិនស៊ូទ្រាំនឹងការបៀតបៀន និងទុក្ខលំបាក ការចំអក និង ការហៅថា "ហូលី រ៉ូលឡឺ" និងអ្វីទៀត ដូចនោះ បើអ្នកមិនអាចទ្រាំបាន អ្នកជាកូនឥតខាន់ស្លា ហើយ មិនមែនជាកូនរបស់ព្រះឡើយ។ ព្រះគម្ពីរនិយាយបែបនោះ។

241 ហៅខ្ញុំ "ហូលី រ៉ូលឡឺ" ចុះបើអ្នកចង់ហៅ។ ហៅខ្ញុំថាអ្វីក៏បានតាមតែអ្នកចង់។ ហើយដរាបណាចិត្តរបស់ខ្ញុំត្រឹមត្រូវចំពោះព្រះជាម្ចាស់ ហើយបទពិសោធន៍របស់ខ្ញុំភ្ជាប់ជាមួយព្រះគម្ពីរ ខ្ញុំកំពុងធ្វើចលនាត្រូវនៅក្នុងទិសដៅដូចគ្នានេះ។ ហ្នឹងហើយ។ នោះជាអ្វីដែលយើងជឿ។ នោះជាក្រុមជំនុំរបស់ព្រះដ៏មានព្រះជន្មរស់ គឺមិនមែនមកដោយទេវវិទ្យានោះឡើយ។ វាមិនបានមកដោយ ការបង្កើតរបស់មនុស្ស ទស្សនៈចំណេះដឹងឡើយ។ វាបានមកដោយប្រាកដពីការបើកសម្ដែងសេចក្ដីពិតដែលព្រះយេស៊ូវជាបុត្រារបស់ព្រះជាម្ចាស់។

242 បើខ្ញុំមានតែទស្សនៈចំណេះដឹង ដោយព្រោះតែជាក្រុមជំនុំបាបទីស្ត ឬក្រុមជំនុំមេតូឌីស្តបង្រៀនខ្ញុំថាអ្វីជា *បែប-នេះ-បែបនេះ*ពេលខ្ញុំឮពីព្រះគម្ពីរនេះ...បើខ្ញុំមានការជ្រមុជក្នុងព្រះនាម "ព្រះបិតា ព្រះរាជបុត្រា និង ព្រះវិញ្ញាណបរិសុទ្ធ" និងអានព្រះគម្ពីរ និង អ្នកអធិប្បាយប្រាប់ខ្ញុំថាមានព្រះយេស៊ូវគ្រីស្ទ និង អានវា ហើយឃើញថាវាជាសេចក្ដីពិត ខ្ញុំនឹងវាយទឹកតាមតែអាចធ្វើទៅបាន។ ហ្នឹងហើយ។

243 បើមាននរណាម្នាក់ប្រាប់ខ្ញុំថា—ថាព្រះយេស៊ូវជាអ្នកប្រោសឲ្យជាដ៏អស្ចារ្យ ហើយ ក្រុមជំនុំរបស់ខ្ញុំប្រាប់ខ្ញុំ "សម័យកាលការអស្ចារ្យបានកន្លងបាត់ហើយ" ហើយ ខ្ញុំត្រូវការការប្រោសឲ្យជា ខ្ញុំនឹងរត់ឲ្យលឿនតាមតែអាចធ្វើទៅបាន ទៅអាសនានោះ ដើម្បីទទួលការប្រោសឲ្យជា។ ខ្ញុំពិតជាធ្វើ។

244 បើខ្ញុំជាគ្រូអធិប្បាយ និង មាន—មានស្ត្រីជាអ្នកអធិប្បាយនៅវេទិកា ហើយ ខ្ញុំអានក្នុងព្រះគម្ពីរ និង ឃើញថាស្ត្រីមិនត្រូវបានអនុញ្ញាតិឲ្យអធិប្បាយឡើយ ខ្ញុំនឹងយកនាងចេញពីទីនោះ ហើយយកទៅលាក់ពីក្រោយខ្ញុំវិញ។

245 ហើយចងចាំ អង្គុយនៅកន្លែងដែលបងប្អូនស្រី វ្រីក នៅយប់មួយ មានស្ត្រីម្នាក់នឹងទាញខ្ញុំចេញតាមទ្វាដោយព្រោះធ្វើបែបនោះ។ ហ្នឹងហើយ។ ខ្ញុំនិយាយ "អ្នកមិនត្រូវមកក្រុមជំនុំខ្ញុំដោយរបៀបចាស់ឡើយ..." ពេលគេធ្លាប់ស្លៀកពាក់អ្វី ឬកាត់សម្លៀកបំពាក់ដូចនេះ និងមានអ្វីមើលទៅគួរឲ្យអស់សំណើច ហើយរាងកាយពាក់កណ្តាលបញ្ចេញមកក្រៅ។ ខ្ញុំនិយាយ "ពួកគេធ្លាប់មកក្រុមជំនុំខ្ញុំ ខ្ញុំពិតជាចាប់គេចេញ។" ហើយមានក្មេងតូចកាលពីមុននៅទីនេះ នាងបានស្លាប់មិនជាយូប៉ុន្មានទេ ហើយនាងហៅខ្ញុំ ពេលជិតស្លាប់។ នាងជាក្មេងស្រីកាតូលិក នាងដើរចូលមក ហើយ អង្គុយបែបនោះ។ ខ្ញុំក្រលេកមើលទៅ ហើយតាមលួចឃ្លាំមើលនាង អង្គុយនៅទីនោះ ហើយគេកំពុងតែច្រៀង។ ខ្ញុំដោះអាវធំចេញ ដើរទៅក្រោយនៅទីនោះ ដាក់វាជុំវិញស្មារបស់នាង។ ខ្ញុំនិយាយ "អ្នកនាង បើអ្នកនាងនឹងស្តាប់ខ្ញុំអធិប្បាយ សូមអ្នកពាក់អាវធំខ្ញុំចុះកាលដែលអ្នកកំពុងនៅក្នុងព្រះវិហាររបស់ព្រះ" ឃើញទេ? ប្រាកដណាស់។

246 នាងបានដើរចេញហើយ បញ្ចេញសម្លេងតិចតួច។ នាងចេញពីអាគា។ នាងនិយាយ "បើគាត់មានសាសនាខ្ញុំមិនព្រមឲ្យសត្វគោរបស់ខ្ញុំជឿសាសនានោះទេ។"

ខ្ញុំនិយាយ "កុំបារម្ភ នាងមិនមានឡើយ។"

247 បន្ទាប់មកយើងនៅក្នុងតង់ ពួកគេហៅខ្ញុំពេលនាងកំពុងតែជិតស្លាប់។ នាងមានជម្ងឺគាំងបេះដូង ហើយនាងពេលនោះកំពុងតែជិតស្លាប់។ ប្តីរបស់នាងបានមក។ គាត់ "អាច មកឲ្យលឿនបានទេ!" ហើយពេលនោះខ្ញុំកំពុងតែនៅក្នុងការប្រជុំ។ ក្មេងប្រុស ធំ ខ្ពស់ ឈរនៅមាត់ទ្វា រង់ចាំខ្ញុំ។ ហើយខ្ញុំរត់តាមទៅ...

248 ខ្ញុំចូលទៅក្នុងឡាន ហើយ ចេញទៅទីនោះ។ ពេលខ្ញុំចេញទៅ ខ្ញុំជួបគិលានុបដ្ឋាកចាស់ម្នាក់នៅទីនោះ ដែលរស់នៅក្នុង ហៅវ៉េដ ផាក។ នាងនិយាយ "លោកគ្រូមិនចាំបាច់មកទេ" នោះប្រហែលជាម្ភៃឆ្នាំមុនប្រហែលជាគ្រាន់បើបន្តិច។ និយាយ "នាងស្លាប់ហើយ។" និយាយ "នាងបានស្លាប់ប្រហែលជាបីនាទីមុន"

និយាយ "នាងស្រែកយ៉ាងខ្លាំងតាមតែអាចធ្វើទៅបាន ស្រែករកលោក" និយាយ "ខ្ញុំមានសារមួយសម្រាប់អ្នក។"

និយាយ "អ្វី?"

249 និយាយ "ប្រាប់ គ្រូអធិប្បាយនោះ ថាខ្ញុំចង់និយាយថា 'សូមអត់ទោសឲ្យខ្ញុំ ផង'។"

250 ខ្ញុំទៅមើលនាង។ ជាក្មេងស្រីស្អាតម្នាក់ ហើយនាងរងទុកលំបាក។ នាងមានអាចម៍រុយលើច្រមុះ ជាក្មេងស្រីស្អាត។ ហើយអាចម៍រុយដូចជាលានចេញមក។ ហើយភ្នែករបស់នាងរុញចេញពីរង្វង់ និងពាក់កណ្ដាលត្រលប់ ពោះវៀននិងតម្រងនោមបានដូរទីតាំង និង ចំហាយក្ដៅភាយពេញគ្រែ បែបនោះ។

251 ហើយប្ដីរបស់នាងសម្លឹងមើលមកខ្ញុំ និយាយ "បងប្អូនប្រុសប្រាណហាំ និយាយ អធិស្ឋាន ព្រោះនាងចង់ឃើញអ្នក។"

ខ្ញុំនិយាយ "អធិស្ឋានសម្រាប់នាងឥឡូវ អាចមិនមែនជាទង្វើល្អអ្វីឡើយ។"

252 "ដើមឈើផ្អែកទៅណា វានឹងដួលទៅខាងនោះ" ឃើញ? "សូមកុំទទួលការបញ្ឆោតឡើយ ព្រះជាម្ចាស់មិនមែនចំអកឡើយ។ អ្វីដែលមនុស្សបានព្រួស នឹងច្រូត បានរបស់នោះ។"

253 តើអ្នកឃើញវានៅឯណា? ឥឡូវមានអ្វីកើតឡើង? មើលពីស្ត្រីម្នាក់ដែលធ្វើចុះ។ សម្លឹងមើលស្ត្រីដែលរស់នៅត្រើយម្ខាងទៀត ស្ត្រីអ្នកចម្រៀង កូនស្រីរបស់នាងជាអ្វី? ជាក្មេងស្រី។ ចុះកូនស្រីរបស់ស្រីក្មេងគឺជាអ្វី? យុវវ័យ រ៉ក ខេនរ៉ូល។ តើកូនស្រីរបស់នាងនឹងក្លាយជាអ្វី? ហឹម! វាជាអ្វី?

មើលពូជនៃសេចក្ដីសុចរិតវិញ?

254 មើលទៅអ្នកជាបាបទីស្ដ។ ត្រលប់ទៅពេលមុនបន្តិច។ ត្រលប់ទៅរកចនស្មីធ ជាអ្នកបង្កើតអ្នកមក អ្នកជាបាបទីស្ដ។ ពេលដែល គាត់អធិស្ឋានសេចក្ដីទុចរិតរបស់មនុស្ស រហូតដល់ គាត់ស្រែកយំ និង អធិស្ឋានដល់មនុស្សរហូតដល់ភ្នែករបស់គាត់ហើមជិត ហើយប្រពន្ធគាត់ត្រូវបម្រើអាហារលើតុ អាហារពេលព្រឹករបស់គាត់។

255 ហើយអ្នកជាមេតូឌីស្ដនៅជុំវិញនេះ ជាមួយអល័ង្គការក្នុងច្រមុះរបស់អ្នក និង លើត្រចៀករបស់អ្នក ហើយ មើលទៅដូចជាកន្លែងអង្គុយសម្រាប់អារក្ខ

និង ចេញទៅស្លៀកខ្លី និង អ្វីបែបនោះ! ពេល លោកចនស្មីធចាស់ ចាស់ទុំម្នាក់ក្នុងចំណោម ពីរបីនាក់នៃក្រុមជំនុំមេតូឌីស្ត មុនគាត់ស្លាប់អាយុ85ឆ្នាំ គាត់អធិប្បាយខ្លីៗរយៈ ពេលបួនឆ្នាំ...បួនម៉ោង។ គេត្រូវលើកគាត់ដាក់លើវេទិកា។ ហើយ នោះជាពាក្យ ចុងក្រោយ របស់គាត់។ គាត់និយាយ "ខ្ញុំភ្ញាក់ផ្អើលចំពោះសកម្មភាពរបស់ក្រុម ជំនុំមេតូឌីស្ត" និយាយ "ទោះបីជាកូនស្រីរបស់ក្រុមជំនុំមេតូឌីស្តក៏ពាក់ចិញ្ចៀន មាសក្នុងម្រាមដៃរ។" អ្វីដែលគាត់ និយាយឥឡូវជាមួយខោអាវខ្លីៗកំពុងឡើង ច្រៀង?

256 អ្នកធ្វើបានល្អហើយ។ តើមានអ្វីកើតឡើង? អ្នកសម្តែងចេញដូចជាម្តាយដែរ។ នោះជាការពិត។

257 នោះជាហេតុផលដែលយើងមិនចង់ឲ្យមាននិកាយណាមួយនៅក្បែរនេះ ព្យួរនៅទីនេះ "យើងជាមេតូឌីស្ត។ យើងជាបាបទីស្ត" យើងជារបស់ព្រះគ្រីស្ទ។ រក្សាវាបែបនោះចុះ ចូរមានសេរីភាព។

258 ឥឡូវមើលពូជរបស់សត្វពស់? តើស្ត្រីចូលចិត្តបោះស្នឹងនោះ? តើនោះអាចធ្វើ យ៉ាងណា? អ្វី? ពួកគេរក្សា តចុះមក។ ពួកគេរុញបាបទីស្តចេញ រុញមេតូឌីស្តចេញ រុញព្រីសប៊ីធីរៀនចេញ។ តើពួកគេចង់បានអ្វី? ពួកគេទាំងអស់ត្រលប់ទៅវិញ ដូចជាម្តាយរបស់ពួកគេ ជាស្ត្រីពេស្យាចាស់ពីដើម។ នោះជាអ្វីដែលពួកគេធ្វើពេស្យាចារដូចគ្នា។ "ល្អ វាមិនធ្វើឲ្យមានភាពខុសគ្នាឡើយ។ ពួកគេជ្រមុជ។ ពួកគេប្រោះ។ ពួកគេបានមក លន់តួបាប។ ពួកគេត្រូវបានហាមឃាត់ប្រាំមួយខែ ពួកគេមិនផឹកអ្វីច្រើនកំឡុងពេលនោះ ជាដើម។ ពួកគេបង្កើនសមាជិកបានល្អ។ ពួកគេចំណាយបានល្អ..." អូ ខ្ញុំអើយ! នោះគ្មានអ្វីត្រូវធ្វើជាមួយផលជាមួយខាងវិញ្ញាណ។

259 ផលផ្លែខាងវិញ្ញាណគឺជា "សេចក្តីជំនឿ" ជឿដល់ព្រះយេស៊ូវគ្រីស្ទ ដែល នៅដូចថ្ងៃម្សិលមិញ ថ្ងៃនេះ និង រៀងរហូត "សេចក្តីស្រឡាញ់" សម្រាប់បងប្អូនប្រុស "អំណរ សេចក្តីសុខសាន្ត អត់ធ្មត់ សេចក្តីល្អ សុភាព ស៊ូទ្រាំ សំឡូត ទប់ចិត្ត" នោះជាអ្វីៗ ផលផ្លែខាងវិញ្ញាណ។

260 ហើយយើងយកមនុស្សមក "ល្អ គាត់—គាត់រស់នៅជីវិតល្អ ក្នុងភាពជាអ្នកជិតខាង។" អេសាវក៏ដូច្នេះដែរ។

261 អេសាវមិនដែលធ្វើបាបនរណាឡើយ ហើយ អេសាវជាអារក្ខ ប៉ុន្តែយ៉ាកុបកើតចេញពីពោះតែមួយ ជារបស់ព្រះវិញ។ ជាពូជនៃសាតាំង និង ជាពូជនៃស្ត្រី ពូជរបស់ព្រះជាម្ចាស់ដែលបានតមក។

262 ឥឡូវអ្នកឃើញ វាបានតមករបៀបនេះ ចំពោះអ្វីដែលវាបានបន្សល់រហូតដល់សព្វថ្ងៃ? ខ្ញុំនឹងនិយាយដោយខ្លាំងៗពិតជាក់ ជំរុញរឿងនេះមក បន្ទាប់មកយើងនឹងចាប់ផ្តើមការបំពេញចេស្តាជាថ្មី បន្ទាប់ពីនេះ នៅការប្រជុំបន្ទាប់។ វាត្រូវតែច្បាស់លាស់។ ហើយសូម ខ្ញុំមិននិយាយដោយសេចក្តីប្រមាថទេ។ ខ្ញុំមិននិយាយវាដោយមានន័យយ៉ាងនោះទេ។ វានឹងចូលមកដល់កន្លែង ជាក្រុមសាសនាធំមួយនៃភាពមិនស្របច្បាប់ កូនឥតខាន់ស្លា។ នេះជាការគូសចំណាំចុងក្រោយរបស់ខ្ញុំ។ នេះជាអ្វីដែលនឹងមកជាពិត។ អ្នកដឹងថានោះជាសេចក្តីពិត។ វានឹងមកដល់កន្លែងរហូតដល់វាជាការភ្ជាប់គ្នានៃក្រុមជំនុំ និង សមាជិកក្រុមជំនុំ "មានទម្រង់ភាពជាព្រះ តែបដិសេធចេស្តានោះ" រហូតវាបានក្លាយជាក្រុមសាសនា ជាកូនឥតខាន់ស្លា។ នោះជាអ្វីពិតហើយ។

263 អ្វីជាការបន្សល់មកទៀត? មានគ្រាប់រ៉ុកកែតព្យួរនៅត្រើយម្ខាងទៀត មានពីរទៅបី គ្រាប់បែកកូប័ល និង អ្វីៗផ្សេងទៀត។ ពួកគេចាំតែពេលវេលានោះមកដល់។ ហើយវានឹងមានការបំផ្លាញដោយភ្លើង ដូចទីនោះ ដោយទឹក។

264 ហើយ សម្លាញ់អើយ អ្វីដែលអ្នកធ្វើ បើអ្នកជាគ្រីស្ទាននិង មានព្រះជាម្ចាស់នៅក្នុងចិត្ត ហើយអ្នកដឹងថាអ្នកបានឆ្លងពីសេចក្តីស្លាប់មកឯជីវិត អ្នកនឹងក្លាយជាមនុស្ស ដែលរីករាយបំផុតនៅក្នុងលោក។

265 ពេលដែលព្រះវិញ្ញាណបរិសុទ្ធនៅក្នុងអ្នក...ពេលព្រះគម្ពីរនិយាយ "ព្រះយេស៊ូវគ្រីស្ទនៅដូចថ្ងៃម្សិលមិញ ថ្ងៃនេះ និងរហូតតទៅ។" និកាយផ្សេងៗ និយាយថា "ប៉ុន្តែយើងជឿថាការអស្ចារ្យបានកន្លងបាត់ហើយ។" ព្រះវិញ្ញាណបរិសុទ្ធមានបន្ទូល "អាមែន ព្រះយេស៊ូវគ្រីស្ទគឺ នៅដូចថ្ងៃម្សិលមិញនិងរហូតតទៅ។ វានឹងដូច្នេះ។"

266 បើព្រះគម្ពីរនិយាយថា "ប្រែចិត្ត និង ជ្រមុជទឹកឲ្យគ្រប់គ្នានៃអ្នកក្នុងព្រះនាមព្រះយេស៊ូវគ្រីស្ទ សម្រាប់កាលោះបាប អ្នកនឹងទទួលព្រះវិញ្ញាណបរិសុទ្ធ។ ព្រោះសេចក្តីសន្យាចំពោះអ្នក និង កូនៗរបស់អ្នក ចំពោះសាសន៍ដទៃ និង តរៀងទៅតាមតែ ច្រើនតាមតែព្រះអម្ចាស់ជាព្រះ..."(ច្រើនតាមតែ ព្រះអម្ចាស់ជាព្រះនៃ

យើងនឹងត្រាស់ហៅ ឃើញទេ? មិនមែន ច្រើនតាមតែមេតូឌីស្តហៅ បាបទីស្ត ហៅនោះទេ ប៉ុន្តែតាមតែព្រះអម្ចាស់ជាព្រះរបស់យើងត្រាស់ហៅ នឹងទទួលបាន ព្រះវិញ្ញាណបរិសុទ្ធ និង ជ្រមុជក្នុងព្រះនាមព្រះយេស៊ូវគ្រីស្ទ នេះជាអ្វីដែលព្រះគម្ពីរ និយាយ)ពេលដែលការនោះវាយដល់អ្នក អ្នកនិយាយ "អាម៉ែន!"

267 ក្រុមជំនុំនិយាយថា "អូ វាគ្មានអ្វីខុសគ្នាទេ។"

268 ប៉ុន្តែព្រះវិញ្ញាណបរិសុទ្ធនេះនៅក្នុងអ្នកនិយាយថា "អាម៉ែន" ចំពោះព្រះបន្ទូល ទ្រង់។

269 "មនុស្សមិនមែនរស់ដោយសារតែនំប៉័ង ប៉ុន្តែគ្រប់ទាំងព្រះបន្ទូលចេញពី ព្រះ ឱស្ឋរបស់ព្រះជាម្ចាស់ដែរ។" អ្នកគឺបែបនោះ។

270 ខ្ញុំចង់ឲ្យអ្នកបង្ហាញខ្ញុំ ពីខគម្ពីរត្រង់ថា ផ្លែប៉ោមចាប់ផ្តើមអ្វីដែលបន្តឥឡូវ។ ខ្ញុំ ចង់ឲ្យអ្នកបង្ហាញខ្ញុំថា ពួកគេបរិភោគផ្លែប៉ោម។ ខ្ញុំបានបង្ហាញអ្នកពីកន្លែងដែល កាអ៊ីនបានគិតដូចគ្នានោះ ហើយពូជរបស់គាត់នៅតែបន្តគិតដូចគ្នា។

271 ប៉ុន្តែការបើកសម្តែងរបស់ព្រះខាងវិញ្ញាណ តាមរយៈព្រះគម្ពីរ ថានោះជា ការទាក់ទងផ្លូវភេទរវាងមនុស្សប្រុសស្រី មិនស្របច្បាប់។ នោះជាអ្វីដែលយក្ស កើត មានមក។ នោះជាអ្វីដែលបាបចូលមក។ នោះជាកន្លែង ដែលសេចក្តីពុកផុយ ចេញមក។ ហើយនោះជាកន្លែងដែលវាបានតមក។

272 ឥឡូវ កត់សម្គាល់ក្នុងការនេះ—នេះ មើល—សត្វពស់មានភាពវ៉ៃ ឆ្លាតពីរ ដង។ ពូជរបស់វាឆ្លាតពីរដង។ ហើយខ្ញុំចូលចិត្តឡើងទៅវេទិកា និង ចាប់កាន់ មីក្រូហ្វូនក្នុងដៃ [បងប្រុសប្រាណហាំប្តូរកន្លែងមីក្រូហ្វូន—Ed] ហើយដោយជើង របស់ខ្ញុំនៅលើវេទិកា ហើយ និយាយបែបនេះ។ ហើយសព្វថ្ងៃចំណេះចេះដឹងអ្នក នៅឯណា? គ្រូគង្វាលរបស់អ្នកដែលតមក និង មានចំណេះដឹងច្រើន ហើយ គាត់ ឈរឡើង គាត់ជាគ្រូគង្វាលក្រុមជំនុំធំនៅក្នុងប្រទេស ហើយមានអ្វីៗបែប នោះ។ តើកន្លែងណា ដែលពូជរបស់សត្វពស់ឈរ? ក្នុងកន្លែង ដែលឆ្លាតពីរដងបែប នោះ ឆ្លាតជាគ្រូប្រាជ្ញាល្អិត។ នោះជាកន្លែងដែលគាត់នៅ។ នោះជាកន្លែងគាត់ តាំងនៅ។

273 "មិនមែនឫទ្ធិ និង អំណាច ប៉ុន្តែដោយព្រះវិញ្ញាណ នេះជាព្រះបន្ទូលរបស់ ព្រះអម្ចាស់។" ឃើញ? តើអ្នកនៅឯណា...

274 បន្ទាប់មកអ្នកយកប្អូនប្រុសតូចម្នាក់ឈរនៅជ្រុងមួយ ភ្នែកគាត់យំ ហើយប្រហែលឈរ នៅទីនោះកំពុងលេងហ្គីតានិយាយ "ប្អូនប្រុសមកស្វែងរកព្រះអម្ចាស់!"

275 គ្រូគង្វាលដើរកាត់នោះ និយាយ "ហះ! មិនមែនក្រុមជំនុំរបស់ខ្ញុំទេ...ហេតុអ្វីខ្ញុំមិនសហការទេ មិនគួរឲ្យខ្ញុំ...មិនគួរឲ្យ លីដឌី និង ចននី ហើយពួកគេឃើញខ្ញុំនៅកន្លែងបែបនោះឡើយ។" បន្តទៀតចុះ ពូជអារក្ខអើយ ទោះយ៉ាងណាអ្នកតម្រង់រកគោលដៅអស់កល្បរបស់អ្នកហើយ។ ត្រូវទេ។ ខ្ញុំអាចនិយាយពាក្យផ្សេងទៀតទីនោះ និង និយាយ "កូនឥតខាន់ស្លា" ហើយនោះជាអ្វីដែលវានៅទីនោះ។ ព្រោះអ្នកឃើញ អ្នក...

276 "គ្មាននរណាម្នាក់អាចមកឯខ្ញុំ លើកលែងតែព្រះបិតានាំគេប៉ុណ្ណោះ និងគ្រប់ទាំងអស់អ្នកដែលមកឯខ្ញុំ ខ្ញុំនឹងប្រោសឲ្យបានរស់ឡើងវិញ នៅថ្ងៃចុងក្រោយ។ នឹងគ្មានអ្វីដែលត្រូវបាត់បង់ឡើយ។ ខ្ញុំយកទាំងអស់។ ខ្ញុំនឹងរក្សាវា។ គ្មានមនុស្សណាអាចធ្វើបានឡើយក្រៅពីការនេះ។"

277 ទាំងអស់នៅក្នុងទ្រង់។ អ្នកអាចនិយាយ "ខ្ញុំបានធ្វើការមួយ" វាជាព្រះគុណនៃព្រះដែលបានធ្វើសេចក្តីទាំងអស់។ ដូច្នេះ គ្មានអ្វីដែលខ្ញុំបានធ្វើឡើយ។ ខ្ញុំគ្មានអ្វីត្រូវធ្វើឡើយ អ្នកក៏មិនធ្វើដែរ មិនធ្វើដូចគ្នា។ អ្នកមិនអាចមានសគុណណាមួយ។ ព្រះជាម្ចាស់ធ្វើវាគ្រប់ទាំងអស់។ អ្នកមិនបានកម្រើកម្រាមណាមួយពីផ្នែករបស់វាដែរ។ អ្នកមិនអាចនិយាយ "ល្អ ខ្ញុំមកពីគ្រួសាល្អ។ ខ្ញុំធ្វើការ*នេះ*" គ្មានអ្វីត្រូវ ធ្វើជាមួយវាឡើយ។ព្រះជាម្ចាស់ជាម្នាក់ដែលធ្វើវាសេចក្តីមេត្តារបស់ព្រះជាម្ចាស់។

278 ខ្ញុំសូមទោសឥឡូវ វានឹងមិនចប់នៅម៉ោងដប់មួយឡើយ ប៉ុន្តែខ្ញុំនឹងបិទ ទោះជាយ៉ាងណាក៏ដោយ។ ឃើញ?

279 តើប៉ុន្មាននាក់ ដែលយល់ថាព្រះគម្ពីរនិយាយសេចក្តីទាំងអស់នេះ ថាជាសេចក្តីពិត អ្នកជាមនុស្សរបស់រោងឧបោសថប្រាណហាំ ជាពិសេស? [ក្រុមជំនុំនិយាយ "អាម៉ែន"—Ed]។ ឥឡូវវាប្រហែលជាមួយភាគដប់ប្រាំមួយ នៃអ្វីដែលយើងបានបង្រៀននិងជឿ។ ប៉ុន្តែសូមចងចាំ ដល់អ្នកដែលនៅជិតព្រឹត្តិការណ៍ ខ្ញុំអាចនឹងនិយាយរឿងនេះ អ្នកជាមនុស្សដែលមិន បានមកទីនេះដូចសមាជិកនោះទេ។ របៀបដែលយើងជឿរឿងនេះ *នេះ* ជាអ្វីក្នុងព្រះគម្ពីរ និង ព្រះគម្ពីរជាសេចក្តីពិតរបស់ព្រះជាម្ចាស់។

280 ហើយយើងជឿថា ក្នុងសញ្ញាចាស់ ឥឡូវ ពួកគេមានរបៀបដែលអ្វីជាសេចក្តីពិត និង អ្វីមិនមែនជាសេចក្តីពិត។

281 ឥឡូវយើងទាំងអស់គ្នាដឹងថា ពួកគេមានបញ្ញតិសរសេរទុក។ តើប៉ុន្មាននាក់ដែលដឹង? ច្បាប់—បញ្ញាតិនៅក្នុងហិប និងអ្វីទៀត ត្រូវ និងច្បាប់នៅក្នុងបញ្ញតិ។ និយាយ "អ្នកមិនត្រូវប្រព្រឹត្តការកំផិត។ អ្នកណាធ្វើកំផិតនឹងត្រូវគប់នឹងដុំថ្ម" ឃើញ? នោះជា—ជាបញ្ញតិ និង ច្បាប់នៅក្នុងបញ្ញតិ។ ឥឡូវហិបដាក់នៅបែប*នេះ* ហើយបញ្ញតិដាក់នៅក្នុងនោះ ហើយច្បាប់បញ្ញតិនៅក្នុងកាតាបម្ខាងនៃហិប។ បើមនុស្សមកត្រង់ចំនុចនេះ ធ្វើកំផិត មកដល់ត្រង់នេះច្បាប់និយាយថា "ចោលគាត់នឹងដុំថ្ម។" ពួកគេនាំគាត់ចេញទៅហើយចោលនឹងដុំថ្ម។ នោះជាអ្វីដែលជាច្បាប់នៅក្នុងបញ្ញតិ។

282 ឥឡូវពួកគេមានពីររបៀបក្នុងការដឹង។ វាតែងតែមានបី ដើម្បីបញ្ជាក់។ ពួកគេមានរបៀបផ្សេងទៀតក្នុងការស្គាល់ វាចេញមកពីហោរ៉ា ឬ អ្នកយល់សប្តិ។ តើប៉ុន្មាននាក់ដែលដឹង? "បើមាននរណាម្នាក់ក្នុងចំណោមអ្នក ជាអ្នកខាងវិញ្ញាណ ឬ ជាព្យាការីយើងជាព្រះអម្ចាស់នឹងប្រាប់ដល់គាត់ផ្ទាល់ ក្នុងសុបិនរបស់គាត់ ហើយមានបន្ទូលទៅកាន់គាត់ដោយការបើកសម្តែង។" ពិតណាស់។ ឥឡូវនេះ គាត់គឺជាហោរ៉ាហើយ។

283 ឥឡូវ បើមានមនុស្សចូលមកនិយាយ "អូហាលេលូយ៉ាខ្ញុំយល់! ខ្ញុំថ្លែងទំនាយឥឡូវក្នុងព្រះនាមព្រះអម្ចាស់។ ខ្ញុំទទួលបានការបើកសម្តែង" ពួកគេមិនព្រមឲ្យប្រព្រឹត្តទៅបែបនោះឡើយ ដូចអ្នករាល់គ្នាធ្វើដែរ។ ពួកគេពិនិត្យរឿងនោះដោយព្រះជាម្ចាស់ ជាមុន។

284 ឥឡូវបន្ទះស្លាកទ្រូងរបស់អើរ៉ុនមានអ្វីដែលគេហៅថា យូរីម និងធូមីម។ តើប៉ុន្មាននាក់ធ្លាប់ឮពាក្យនោះ? វាជាអ្វី? គឺជាថ្ម១២ ម្ខាងមានប្រាំមួយ ជាបុព្វបុរសទាំងដប់ពី ជាត្បូង យូដា និងអ្វីទៀត ហើយបន្តមក ជាត្បូងដប់ពីរ។ ហើយក្រោយមកពួកគេយកព្យាការីនេះ ឬ អ្នកយល់សប្តិមក ហើយគេពាក់ប្រដាប់បាំងទ្រូងនេះ និង ដាក់ឲ្យគាត់ឈរនៅទីនោះ។ ហើយ ពួកគេនិយាយថា "ឥឡូវចូរថ្លែងទំនាយ និង ប្រាប់ពីទំនាយរបស់អ្នក។"

"ព្រះអម្ចាស់មានបន្ទូលមកខ្ញុំ ហើយ និយាយ ជាប្រាកដ—សេចក្តីប្រាកដ។"

285 មិនថាវាហាក់ដូចជាពិតយ៉ាងណាក៏ដោយ វាស្តាប់ទៅដូចជាវាជាសេចក្តីពិតឥតខ្ចោះ ប៉ុន្តែបើពន្លឺពួកវាមិនបានមកជួបជុំ និង មិនមានឥន្ទនូពណ៌កាត់តាមនោះ យូរីម ធូមីម ពន្លឺរបស់ពួកវាប្រមូលផ្តុំទាំងអស់គ្នា ជាដំណើរការលើសពីធម្មជាតិមានការបញ្ជាក់មក។ មើលព្រះជាម្ចាស់តែងបញ្ជាក់ព្រះបន្ទូលទ្រង់។ ឃើញទេ? ហើយបើថាពន្លឺលើសពីធម្មជាតិមិនមានភ្លឺត្រង់នោះ ដូច្នេះខ្ញុំមិនគិតថាវាដូចជាពិតប៉ុណ្ណាទេ វាខុសហើយ។

286 បើអ្នកយល់សប្តិនិយាយ "ខ្ញុំយល់សប្តិរឿងមួយ ហើយសុបិននេះនិយាយថា 'អ៊ីស្រាអែលត្រូវផ្លាស់ទី និង ទៅកន្លែងណាមួយច្បាស់ ព្រោះពួកស៊ីរីនឹងមកតាម*ផ្នែកនេះ* និង ឡោមពទ្ធ័វា។'" ពួកគេនឹងយកសុបិនរបស់អ្នកយល់សុបិនមកគាត់ប្រាប់សប្តិនោះ។ បើពន្លឺមិនបានភ្លឺទេ គាត់ថាខុសហើយ មិនថារបៀបណាទេ...តែបើពួកស៊ីរីបានអង្គុយរៀបខ្លួនរួចហើយ នៅទីលានសង្គ្រាមក៏ដោយគាត់និយាយខុស។ អត់ទេ។ ពួកគេ ពិតណាស់វាត្រូវតែបង្ហាញដោយ យូរីម ធូមីម។

287 ឥឡូវគ្រប់គ្នាដឹងថាសង្ឃបុរាណកន្លងបាត់ ចប់បាត់ហើយ ហើយ យូរីម ធូមីមទៅជាមួយពួកគេដែរ។ យើងដឹងដូច្នេះ មែនទេ? [ក្រុមជំនុំនិយាយ "អាម៉ែន"—Ed]។

288 ហើយសង្ឃថ្មីក៏បានមក។ ជាអ្វី? សព្វថ្ងៃយើងមានយូរីម ធូមីមទេ? បាទមាន។ ព្រះបន្ទូលរបស់ព្រះជាម្ចាស់! ហ្នឹងហើយ។ *នេះ*គឺវា។ បើមនុស្សណាម្នាក់មានការបើកសម្តែងណាមួយ ឬនិយាយអ្វី ឬគោលលទ្ធិណាដែលមិនស្របតាម និង...និង ថតចម្លងព្រះគម្ពីរ តាមរយៈអត្ថបទគម្ពីរទាំងមូល គាត់ខុសហើយ។ ខ្ញុំមិនខ្វល់ថាគាត់មាននិកាយអ្វី គាត់ល្អយ៉ាងណា គាត់ឆ្លាតប៉ុណ្ណា គាត់រៀនបានច្រើនប៉ុណ្ណា គាត់ខុសហើយ។

289 ហើយបើមានមនុស្សណាម្នាក់ប្រាប់អ្នកពីការនេះ ដែលយើងកំពុងតែបង្រៀនទីនេះក្នុងក្រុមជំនុំឥឡូវ និង ប្រាប់អ្នក ថា "បើអ្នកប្រស់ទឹក វាមិនអីទេ" គាត់ប្រាប់អ្នកដោយកុហកហើយ។ នោះមិនមានពន្លឺនៅយូរីម ធូមីមឡើយ។ ពេលគាត់ប្រាប់អ្នកបែបនោះ "ការចាក់ទឹកត្រូវហើយ" គាត់ប្រាប់អ្នកដោយកុហកហើយ។ គាត់ប្រាប់អ្នកថា "ការជ្រមុជទឹកក្នុងព្រះនាម 'ព្រះវរបិតា ព្រះរាជបុត្រា ព្រះវិញ្ញាណបរិសុទ្ធ' ជាការត្រឹមត្រូវ" គាត់ក៏ប្រាប់អ្នកដោយកុហកដែរ។ បើគាត់ប្រាប់អ្នកថា "សម័យកាលការអស្ចារ្យកន្លងបាត់ហើយ" គាត់ប្រាប់អ្នកដោយកុហក់ហើយ។

បើគាត់ប្រាប់អ្នកថា "វាមិនមានបញ្ហាទេ ក្នុងការឲ្យស្ត្រីអធិប្បាយ" គាត់ប្រាប់អ្នកដោយកុហកដែរ។ បើគាត់ប្រាប់អ្នកថា "វាមិនអីទេដែលអ្នកចេញទៅហើយបិទស្លាកនិកាយ" គាត់ប្រាប់អ្នកដោយកុហកហើយ។ វានឹងមិនមានពន្លឺចេញមកនៅយូរីមធូធីមឡើយ។ ហើយអ្វីរាប់ឡូដែលចេញមក នៅក្នុងរឿងចាស់ "**ម្ដាយនៃ ពេស្យាចារ**" ហើយមកដល់ទីនេះ ហើយ នោះជាហេតុផលដែលអ្នកត្រូវនៅឲ្យឆ្ងាយពីនិកាយ។

290 យើងស្រឡាញ់បងប្អូនប្រុសស្រីដែលមកពីនោះ។ ប៉ុន្តែអ្នកត្រូវទៅ និយាយថា "ខ្ញុំជាមេតូឌីស្ត" និង ធ្វើឲ្យអ្នកក្លាយជាគ្រីស្ទាន ចំពោះខ្ញុំ។ អ្នកជាគ្រីស្ទានព្រោះអ្នកកើតចេញពីវិញ្ញាណនៃព្រះ។ អ្នកមិនចាំបាច់ក្លាយជាបាបទីស្ត ឬ មេតូឌីស្តឡើយ។ អ្នកមិនចាំបាច់ក្លាយជាអ្វីមួយនោះឡើយ។ អ្នកគ្រាន់តែកើតចេញពី ព្រះវិញ្ញាណរបស់ព្រះជាម្ចាស់ប៉ុណ្ណោះ។ តើអ្នកជឿទេ?[ក្រុមជំនុំនិយាយ "អាម៉ែន"—Ed]។

291 អាស្រ័យលើមូលដ្ឋាននេះ បើមាននរណាម្នាក់នៅទីនេះ ចង់សហការនិងចូលរួមក្នុងការប្រកបនៃការថ្វាយបង្គំនេះ និងចង់ធ្វើ—ការ ជ្រមុជទឹកជ្រមុជទឹកដោយ ព្រះនាមព្រះយេស៊ូវគ្រីស្ទ នៅទីនេះមានអាងទឹក។ គេនឹងជ្រមុជទឹកតែមួយនាទីប៉ុណ្ណោះ។

292 បើមានមនុស្សជាច្រើន ច្រើននាក់នៅទីនេះ នរណាដែលចង់មក ក្នុងរបៀបណាផ្សេង? យើងនៅទីនេះ។ ជាការត្រឹមត្រូវ។

293 ឥឡូវ យើង—យើងមិនមានភាពជាសមាជិកអ្វីទេ អ្នកគ្រាន់តែមកទីនេះក្នុងក្រុមជំនុំនេះ។ យើងជឿថាព្រះគ្រីស្ទគង់នៅក្នុងក្រុមជំនុំមេតូឌីស្ត និង បាបទីស្ត និង ព្រីសប៊ីធីរៀន។ ទ្រង់ទទួលយកសមាជិកម្នាក់ៗនៃពួកគេ។ ហើយអ្វីដែលខ្វះខាតបច្ចុប្បន្ន គឺការថ្លែងទំនាយខុសដែលនាំឲ្យរឿងនោះចេញមក ការបង្រៀនរបស់ក្រុមជំនុំនោះ ដែលពិតជាផ្ទុយនឹងព្រះគម្ពីរ។

294 ឥឡូវ បើមាននរណាម្នាក់បង្ហាញច្បាស់មកខ្ញុំ ខ្ញុំនឹងទទួលយកដោយខ្លួនឯង...ខ្ញុំជឿជាក់ថាមានព្រះវិញ្ញាណរបស់ព្រះគ្រប់ល្មមក្នុងខ្លួនខ្ញុំ ដើម្បីស្វែងរក និង ចូលមក ហើយជឿថាវាត្រឹមត្រូវ។ បើខ្ញុំគ្រាន់តែដើបដើរចេញ និងចាប់ដៃជាមួយអ្នកអធិប្បាយ និង ដាក់ឈ្មោះរបស់ខ្ញុំលើសៀវភៅ ប៉ុន្តែនៅមានសម្អប់និងព្យាបាទ ក្នុងចិត្ត និង នៅមានការច្រណែន និង វិវាទនិងនៅតែមិនជឿថាព្រះយេស៊ូវជាអង្គ ដែលប្រោសឲ្យជាដ៏អស្ចារ្យ និងអ្វីផ្សេងទៀតបែបនោះ ខ្ញុំ

នឹងចេញទៅពង្រឹងជាមួយ ព្រះជាម្ចាស់ យ៉ាងលឿន។ ខ្ញុំជឿជាក់ថាប្រាកដជាធ្វើ។ ខ្ញុំ—ខ្ញុំនឹងស្មោះត្រង់ចំពោះ រឿងនោះ។ ខ្ញុំនឹងចេញទៅដើម្បីរកឲ្យបាន ភាពត្រឹមត្រូវជាមួយព្រះជាម្ចាស់។ បើសិនជាខ្ញុំគ្រាន់តែនៅជាប់ធម្មតាដោយព្រោះខ្ញុំជាបាបទីស្ត ឬ មេតូឌីស្ត ខ្ញុំនឹង ចុះទៅ ហើយទទួលសាសនាគ្រីស្ទក្នុងចិត្ត។ ខ្ញុំនឹងធ្វើវា។ ហ្នឹងហើយ។

295 ឥឡូវចងចាំពីការចាក់ព្រះចេស្តា ដែលនឹងចាប់ផ្តើម បំណងព្រះទ័យរបស់ព្រះជាម្ចាស់ ការនេះនឹងមកនៅយប់ថ្ងៃពុធ។ វាអាស្រ័យលើគោលការណ៍នេះ ។

296 ចូរស្តាប់សម្លាញ់ មានព្រះដ៏ពិត និង ព្រះជាម្ចាស់ដ៏មានព្រះជន្មរស់។ នោះជាការពិត។ ព្រះយេស៊ូវគ្រីស្ទជាបុត្រារបស់ព្រះជាម្ចាស់។ ព្រះវិញ្ញាណបរិសុទ្ធនៅក្នុងក្រុមជំនុំសព្វថ្ងៃ។

297 ឥឡូវ បើខ្ញុំមាននរណាម្នាក់ប្រាប់ខ្ញុំថា ខ្ញុំមានសិទ្ធិក្នុងការសង្ស័យ។ ប៉ុន្តែ សូមស្តាប់។ នៅថ្ងៃមួយនៃត្រើយម្ខាង នៅភាពជាក្មេងប្រុសតូចម្នាក់ ខ្ញុំកំពុងឈរក្រោមដើមឈើ ខ្ញុំឃើញទ្រង់។ ខ្ញុំឮពីទ្រង់។ ទ្រង់មានបន្ទូលប្រាប់ខ្ញុំ ថា "នៅ ឲ្យឆ្ងាយពីគេស្ត្រីដែលស្មោកគ្រោក។ នៅឲ្យឆ្ងាយពីបារី។ នៅឲ្យឆ្ងាយពីការជេរប្រមាថ ផឹកស្រា និង ការអស់ទាំងនេះ។ ខ្ញុំមានការងាសម្រាប់អ្នក ពេលអ្នកមាន វ័យចាស់ទៅ" ខ្ញុំដឹងថាទ្រង់មានវត្តមានពិត ជាព្រះមានព្រះជន្មរស់ ដែលដោះស្រាយគ្រប់យ៉ាងជាមួយព្រះបន្ទូលទ្រង់។

298 ពេលខ្ញុំកាន់តែមានវ័យចាស់បន្តិច របៀបដែលទ្រង់ជួបជាមួយខ្ញុំ របៀបដែលទ្រង់មានបន្ទូលមកកាន់ខ្ញុំ! របៀបដែលខ្ញុំបានឃើញទ្រង់ នៅត្រើយនាយ ដូចជាគុម្ពោតព្រៃដែលឆេះ ហើយភ្លើងនោះធ្វើចលនាជុំវិញត្រើយនាយ! របៀបដែលខ្ញុំឃើញទ្រង់មានបន្ទូល និង ប្រាប់ពីអ្វីដែលកើតមាន និង គ្រប់ពេល បានកើតមានយ៉ាងល្អឥតខ្ចោះ តាមតែអាចប្រព្រឹត្តទៅបាន បានល្អឥតខ្ចោះបែបនោះ។

299 អង្គតែមួយដែលមានបន្ទូលអ្វីដែលល្អឥតខ្ចោះនោះ គឺជាអង្គនៅដដែលដែលជម្រុញខ្ញុំឲ្យបង្រៀនព្រះគម្ពីរតាមរបៀបដែលខ្ញុំបង្រៀន។ វាជាការត្រឹមត្រូវ។ ដូច្នេះ វាមកពីព្រះជាម្ចាស់។ សម្រាប់ខ្ញុំ វាជាព្រះជាម្ចាស់មានចេស្តា និង ទ្រង់នៅដូចថ្ងៃម្សិលមិញ ថ្ងៃនេះ និង រៀងរហូតទៅ។

300 ព្រះយេស៊ូវមានបន្ទូល "ខ្ញុំបានមកពីព្រះបិតា និង ខ្ញុំទៅព្រះបិតាវិញ។" ពេលទ្រង់យាងមក...

301 ខណៈទ្រង់ជាព្រះនៅវាលរហោស្ថាន ទ្រង់ជាពន្លឺភ្លើងដែលឆេះ។ តើប៉ុន្មាននាក់ដែលដឹងថាដូច្នោះ? [ក្រុមជំនុំនិយាយ "អាម៉ែន"—Ed] ទ្រង់ជាពន្លឺដែលឆេះជាសសរភ្លើង។

302 ហើយទ្រង់យាងមកលើផែនដីនេះ និងមានបន្ទូលថា "ខ្ញុំមកពីព្រះបិតា ហើយខ្ញុំទៅ...ខ្ញុំមកពីព្រះជាម្ចាស់ ហើយ ខ្ញុំត្រលប់ទៅព្រះជាម្ចាស់វិញ។"

303 ពេលទ្រង់សុគត ត្រូវបានកប់ រស់ឡើងវិញ ហើយ ប៉ុលធ្វើដំណើរតាមផ្លូវរបស់គាត់ទៅដាម៉ាស់បានជួបទ្រង់ម្តងទៀត តើទ្រង់ជាអ្វី? [មានអ្នកនិយាយ "ជាសសរភ្លើង"—Ed] នៅតែជាសសរភ្លើង។ ត្រូវហើយ។

304 តើទ្រង់ធ្វើអ្វីពេលទ្រង់នៅទីនេះ លើផែនដី? តើទ្រង់ធ្វើអ្វីពេលទ្រង់ជួបជាមួយប៉ុល? តើទ្រង់បានបញ្ជូនគាត់ដោយរបៀបណា? ទ្រង់បានបញ្ជូនគាត់ទៅព្យាការីម្នាក់ដើម្បីប្រាប់គាត់ពីការជ្រមុជទឹក ប្រាប់គាត់ពីអ្វីត្រូវធ្វើ ដាក់ដៃលើគាត់ដើម្បីប្រោសគាត់ឲ្យជា ប្រាប់គាត់ ពីគាត់ដែលបានឃើញនិមិត្ត។

305 ព្រះយេស៊ូវនៅទីនេះថ្ងៃនេះ ធ្វើការដដែល ហើយនៅតែជាសសរភ្លើងដដែលបង្រៀនសេចក្តីដដែល ហើយបញ្ជាក់ដោយព្រះបន្ទូល ហើយ ដោយទីសម្គាល់និងការអស្ចារ្យ។ ខ្ញុំរីករាយចំពោះគ្រីស្ទាន ខ្ញុំមិនដឹងថាធ្វើអ្វី។ ខ្ញុំរីករាយដែលក្លាយជាគ្រីស្ទាន ខ្ញុំមិនដឹងថាធ្វើអ្វីឡើយ។ ខ្ញុំរីករាយណាស់ដែលអ្នកក្លាយជាគ្រីស្ទាន។

306 ហើយអ្នក រោងឧបោសថនេះ ខ្ញុំប្រាប់អ្នកនឹងផ្លាស់ប្តូរឈ្មោះនេះ។ វាមិនត្រឹមត្រូវជារោងឧបោសថប្រាណហាំឡើយ។ វាគ្រាន់តែជាមនុស្សប៉ុណ្ណោះឃើញ។ យើងនឹងផ្លាស់ប្តូឈ្មោះរបស់វា បង្កើតវាជាឈ្មោះផ្សេងៗ។ យើងនឹងនិយាយពីនោះបន្ទាប់ពីនេះ។ ខ្ញុំចង់តែឲ្យវាក្លាយជា—ព្រះវិហាររបស់ព្រះដែលមានព្រះជន្មរស់។ ខ្ញុំមិនចង់ឲ្យវាក្លាយជាមេតូឌីស្ត បាបទីស្ត ព្រីសប៊ីធីរៀន ពេនទីកុស្តឡើយ។ ខ្ញុំ...

307 មនុស្សទាំងនោះ ខ្ញុំស្រឡាញ់អស់ពីចិត្ត។ ខ្ញុំមិនដឹងថាមួយណាជាមួយ ណាទេ។ ខ្ញុំមិនអាចប្រាប់អ្នកបានទេ។ ខ្ញុំគ្រាន់តែអធិប្បាយព្រះបន្ទូលនោះ។ ខ្ញុំបោះសំណាញ់ហើយទាញវាចេញមក។ មានកង្កែប និង មានពីងពាងទឹក និង ពស់ និង មានត្រីខ្លះដែរ។ វាអាស្រ័យលើព្រះជាម្ចាស់ជាអ្នកសម្រេច។ ទូលបង្គំគ្រាន់តែ

ទាញសំណាញ់ គ្រាន់តែអធិប្បាយព្រះបន្ទូល និង ទាញវាចូលមក និង និយាយ "ពួកគេនៅទីនេះ ព្រះអម្ចាស់ នៅជុំវិញអាសនានោះ។ ទ្រង់ស្គាល់អ្វីជារបស់ទ្រង់ ទ្រង់បានស្គាល់ពួកគេ តាំងពីដើមមក។ ទូលបង្គំ មិនដឹងមួយណាជាមួយណាឡើយ។ សូមទ្រង់ធ្វើចុះ ដូច្នេះវាស្រេចតែទ្រង់ ព្រះអម្ចាស់។ នោះជាអ្វីដែលល្អបំផុត ដែលទូលបង្គំអាចធ្វើបាន។ ទូលបង្គំទៅទីនេះ និងទៅកន្លែងផ្សេងទៀតនិងចាប់ក្រុមផ្សេងទៀត។ នោះជាអ្វីដែលទូលបង្គំអាចធ្វើបាន។" ត្រូវណាស់។

អូ ខ្ញុំមានអារម្មណ៍ដូចជាធ្វើដំណើរទៅ
ខ្ញុំមានអារម្មណ៍ដូចជាធ្វើដំណើរទៅ
ផ្ទះស្ថានសួគ៌របស់ខ្ញុំភ្លឺ និង ស្រស់ស្អាត
ហើយខ្ញុំមានអារម្មណ៍ថាដូចជាធ្វើដំណើរទៅ។

308 ឥឡូវសូមចងចាំ មាននរណាម្នាក់ដែលចង់ណាត់ជួប សូមហៅទៅកាន់លោក មឹសសៀ: BUtler 2-1519[ លេខទូរស័ព្ទបានប្ដូហើយ—Ed] យើងនឹងរីករាយដែលបានជួបអ្នក។ បើម្នាក់ដែលអ្នកស្រឡាញ់ចូលមក ត្រូវតែប្រញាប់ក្នុងពេលចាក់បំពេញព្រះចេស្ដា...ឥឡូវខ្ញុំនឹង ចាប់ពីយប់នេះទៅ បន្តខ្លួនខ្ញុំ និង នឹងត្រូវចេញទៅរយៈពេលពីរថ្ងៃ ដោយខ្លួនឯង។

309 ខ្ញុំគ្រាន់តែចូលទៅក្នុងនោះ និង រៀនដូចនេះ "ព្រះអម្ចាស់ ទ្រង់គង់នៅក្បែរទូលបង្គំ។ ទូលបង្គំដឹងថាទ្រង់គង់ទីនេះ។ ហើយព្រះបន្ទូលទ្រង់មានបន្ទូលថាទ្រង់នឹងទាញពួកគេមកក្បែរ។" ខ្ញុំបន្តអធិស្ឋានចាំយាម រហូតដល់ខ្ញុំបានឃើញសសរភ្លើងចាប់ផ្ដើមធ្វើចលនា។ ខ្ញុំបានស្គាល់រួចមកហើយ។ រួចខ្ញុំដើរទៅកាន់វេទិកាសម្រាប់កម្មវិធីប្រោសឲ្យជា ដើម្បីអធិស្ឋាន និង ធ្វើអ្វីខ្ញុំអាចជួយអ្នកជម្ងឺ និង អ្នករងទុក្ខ។

310 យើងទទួលរាល់សេចក្ដីសប្បុរសឥឡូវ។ ហើយពេលអ្នកមកជឿ ហើយ យើងរំពឹងថាមានការជួបជុំដ៏អស្ចារ្យ។ ខ្ញុំចង់និយាយបែបនោះ...

311 បងប្អូនប្រុស ចេហ្រីស នៅទីនេះយប់នេះ? យើងចង់បង្ហាញភាពរីករាយជាមួយការងាររបស់បងប្អូនប្រុស ចេហ្រីស។ ខ្ញុំទាយថាគាត់បានត្រលប់ទៅកោះវិញហើយ និង បន្តអ្វីទៀត។

312 រីករាយដែលបាន ជួបបងប្អូនប្រុសស្រី វ៉ើហ្គ និងពួកអ្នកជាច្រើនទៀតនៅទីនេះ។

313 ហើយខ្ញុំបានឃើញលោកមេធាវីប៊ីតសាន់នៅទីនេះ មួយស្របក់មុន មកមួយស្របក់កន្លងទៅ។ ខ្ញុំចង់សរសើរគាត់ពីសារ—របស់គាត់ដែលមានកាលពីថ្ងៃមុន។ គ្មាននរណានិយាយថានោះជានរណា។ នោះគឺជាភាពអាម៉ាស់។ គាត់មានសារល្អលើការថ្លែងទំនាយ ជាអ្វីដូចដែលខ្ញុំបានអធិប្បាយនៅយប់នេះ។

314 ហើយដូច្នេះមានអ្នកដឹកនាំមួយទៀតនៅទីនេះកាលពីព្រឹកមិញ ឬកាលពីយប់មិញ បងប្អូនស្មីធ មកពីក្រុមជំនុំមេតូឌីស្ត...ឬពីក្រុមជំនុំព្រះវិហារព្រះជាម្ចាស់ នៅទីនោះ។ ខ្ញុំមិនដឹងថាតើគាត់នៅទីនេះឬអត់។ បើអ្នកធ្លាប់ឈរនៅវេទិកាមើលតាមរបៀបនេះ វាពិបាកប្រាប់បន្តិច វាពិបាកយល់ អ្នកឃើញទេ ហើយអ្នកមិនអាចប្រាប់បាន។បើអ្នកនៅទីនេះបងប្អូនប្រុសស្មីធយើងរីករាយជាមួយលោក។

315 ហើយ វាមិនដូច្នេះ អង្គុយនៅទីនេះ បងប្អូនប្រុសមកពី ចចចា នៅខាងស្តាំគាត់គឺបងប្អូនប្រុស កូលីន? [បងប្អូនប្រុសណេវីលនិយាយ "បាទ"—Ed] រីករាយដែលបានឃើញអ្នកនៅទីនេះ នៅយប់នេះម្តងទៀត បងប្អូនប្រុស។

316 ហើយ អ្នកទាំងអស់គ្នា ទាំងអស់គ្នា ម្នាក់ៗដឹងហើយថាខ្លួនជានរណា។

317 ខ្ញុំជឿថានេះជាបងប្អូនប្រុសស្រីនៅទីនេះ ជាអ្នកអធិស្ឋានសម្រាប់ក្មេងស្រីនៅពេលនោះ នៅទីនេះ ដុកទ័រ ដែលអង្គុយនៅទីនោះនៅកន្លែងនេះចំហៀងម្ខាង។ ព្រះអម្ចាស់ប្រទានពរដល់អ្នក លោកដុកទ័រ។

318 ឥឡូវ សូមកុំមានអារម្មណ៍អាម៉ាស់ចំពោះខ្ញុំ អ្នកដែលជាអ្នកដឹកនាំ និង បងប្អូនប្រុស ពីព្រោះរបៀបដែលខ្ញុំធ្វើនេះដោយខំប្រឹងតាមតែអាចធ្វើទៅបាន។ នេះជារោងឧិបោសថរបស់យើង។ វាជាអ្វីដែលខ្ញុំឈរជំហរ និង យើងចង់ដាក់វាតាមព្រះបន្ទូលនោះ និង ញាប់ញ័រចំពោះសេចក្តីនោះ។ ដូច្នេះ បើអ្នកនៅក្រៅបន្ទាត់យើង នឹងមកវិញហើយនិយាយ "អ្នកដឹងប្រសើរជាង។ វានៅខ្សែអាត់ថត ទុក។" ឃើញ? អ្នកនៅទីនោះ។ "នេះវានៅលើខ្សែអាត់។"

319 យើងមានឱកាសជាងអ្វីដែលគួរតែប្រព្រឹត្តទៅបែបនោះ លីអូ។ ប៉ុន្តែ ប៉ុន្តែយើង...អ្នកទទួលបានច្រើន។ យើងនិយាយពីភាពត្រឹមត្រូវពីនោះ ហើយ យើងនឹងទទួលទាំងអស់ ពីវានៅបន្តិចទៀត។ ដូចជាមនុស្សបរិភោគផ្លែឱឡឹក បាន និយាយ

"វាឆ្ងាញ់ណាស់ ប៉ុន្តែវាមានអ្វីដែលល្អជាងនោះទៅទៀត" ដូច្នេះយើងមាន វាច្រើន ប៉ុន្តែ មិនទាន់មកដល់។

320 សូមព្រះប្រទានពរដល់អ្នក ជាសេចក្តីពិតដែលត្រឹមត្រូវនាឥឡូវ។ ខណៈដែលយើង...នឹងមានកម្មវិធីថ្វាយបង្គំឥឡូវ។ នោះជាការត្រឹមត្រូវ បងប្អូនប្រុសណេវីល? [បងប្អូនប្រុសណេវីលនិយាយ "បាទ ខ្ញុំជឿថាដូច្នោះ"—Ed]។ តើមាននរណានៅទីនេះត្រូវជ្រមុជទឹកឥឡូវទេ? យើងមិនខ្វល់ថាអ្នកជានរណា យើង—យើងនៅទីនេះត្រូវជ្រមុជទឹក។ លើកដៃ អ្នកណាដែលត្រូវជ្រមុជទឹក។ អ្នកដែល ខ្ញុំជឿវាគឺ...ទីនេះមានស្រ្តីម្នាក់។ ហើយមាននរណាទៀត? ឥឡូវយើងមានសម្លៀកបំពាក់នៅទីនេះជារបស់បុរសនិងស្រ្តី។

321 ឥឡូវ យើងមិននិយាយ "ចាកចេញពីក្រុមជំនុំអ្នក។ ចេញពីក្រុមជំនុំមេតូឌីស្ត" យើងមិននិយាយ។ អ្នកត្រលប់ទៅវិញតាមក្រុមជំនុំរបស់អ្នកចុះ។ ប៉ុន្តែបើអ្នកមិនបានជ្រមុជទឹកតាមរយៈបទគម្ពីរ ក្នុងព្រះនាមព្រះអម្ចាស់យេស៊ូវ...មិនដោយព្រះនាម "ព្រះយេស៊ូវ" តែមួយឥឡូវ។ ក្នុងព្រះនាម "ព្រះអម្ចាស់យេស៊ូវ គ្រីស្ទ" តាមរយៈខគម្ពីរ។ អ្នកជ្រមុជទឹកខុសហើយ។

322 ខ្ញុំមិនចង់មានបញ្ហាពេលខ្ញុំមកដងទន្លេ។ ខ្ញុំចង់ឲ្យគ្រប់យ៉ាងច្បាស់លាស់តាមតែខ្ញុំដឹងពីរបៀបនោះ ពេលខ្ញុំកាន់សំបុត្រនោះ មើល ព្រោះខ្ញុំចង់ទទួលបានការចេញដំណើរនៅពេលនោះ។ ខ្ញុំសូមលើកទឹកចិត្តអ្នកឲ្យធ្វើដូចគ្នា។

323 ត្រលប់ទៅក្រុមជំនុំរបស់អ្នកវិញ។ នោះត្រូវហើយ រវាងអ្នកនិងព្រះជាម្ចាស់។ នោះជាអ្វីដែលខ្ញុំអាចប្រាប់អ្នក។

324 ប៉ុន្តែគ្មាននរណា ក្នុងគម្ពីរដែលត្រូវបានជ្រមុជទឹក ដោយរបៀបណាមួយផ្សេងក្រៅពីព្រះនាម "ព្រះអម្ចាស់យេស៊ូវគ្រីស្ទ។" ហើយអស់អ្នកដែលជ្រមុជទឹកដែលបង្គាប់ដោយសាវកប៉ុល ជាអ្នកនិយាយថា "បើមានទេវតាណា អធិប្បាយអ្វីផ្សេងទៀត ចូរឲ្យត្រូវបណ្តាសារចុះ" ការបង្គាប់របស់គេចូលមក និង ត្រូវជ្រមុជទឹកជាថ្មី ម្តងទៀត ក្នុងព្រះនាម "ព្រះអម្ចាស់យេស៊ូវគ្រីស្ទ" នោះជាការត្រឹមត្រូវ។ ហើយគាត់ក៏ធ្វើបែបនោះ។ ហើយអ្វីគាត់ធ្វើ គាត់ផ្តល់កិច្ចការដល់យើងត្រូវធ្វើ ដែលនោះជាអ្វីយើងត្រូវធ្វើ បំណងព្រះហឫទ័យព្រះជាម្ចាស់។

យើងជឿលើការលាងជើង។ យើងជឿលើការប្រេកបគ្នា។

325 យើងជឿលើការយាងមកជាលើកទីពីររបស់ព្រះគ្រីស្ទដែលមើលឃើញ ជារាងកាយនៃព្រះអម្ចាស់ មិនមែនជាវិញ្ញាណ ប៉ុន្តែជារាងកាយនៃ ព្រះអម្ចាស់យេស៊ូវដែលយាងមកម្តងទៀតដោយសិរីរុងរឿង។

326 យើងជឿលើការរស់ឡើងវិញពីការសុគត ដើម្បីទទួលរាងកាយ មិនចេះចាស់ជ្រីវជ្រួញពេលយើងទៅក្នុងផ្នូរ ប៉ុន្តែជារាងកាយថ្មីមួយ ពេញដោយសុភមង្គលនៃយុវវ័យ ដើម្បីរស់បានរហូត។

327 យើងជឿលើភាពមិនចេះស្លាប់នៃព្រលឹង ជាការពិត។ យើងជឿថាមានទម្រង់តែមួយនៃជីវិតអស់កល្ប ហើយនោះជា ជីវិតដែលអ្នកទទួលបានពីព្រះគ្រីស្ទ យេស៊ូវ។ នោះជាការពិត។

328 ដូច្នេះ យើងមិនជឿលើការដាក់ទោសជារៀងរហូត។ យើងជឿលើភ្លើងនរក ការឆេះដោយស្ពាន់ធ័រ ប៉ុន្តែយើងមិនជឿថាវាឆេះជារៀងរហូត បើវាដូច្នោះអ្នកទទួលជីវិតអស់កល្ប។ មានជីវិតអស់កល្បតែមួយ ដែលមកពីព្រះជាម្ចាស់។ នោះជាការពិត។ អ្នកនឹងត្រូវបានដុតបញ្ឆេះ ប្រហែលជាមួយលានឆ្នាំ ដប់លានឆ្នាំ ខ្ញុំមិនដឹង ប៉ុន្តែអ្នកមិនអាចមានជីវិតអស់កល្បឡើយ។ អ្នកមិនអាចត្រូវដុតរៀងរហូតឡើយ...អ្នកអាចឆេះរៀងរហូត ប៉ុន្តែមិនមែនអស់កល្ប។ ឃើញទេនេះជាភាពខុសគ្នារវាងអស់កល្ប និង រៀងរហូត។ *រៀងរហូត* គឺរហូត និង រៀងរហូត ចំណុចប្រសព្វ មានន័យថា "ចន្លោះពេលវេលា" ប៉ុន្តែអស់កល្ប អ្នកមិនអាចមានការដាក់ទោសអស់កល្បឡើយ។

329 អ្នកមានជីវិតអស់កល្ប ព្រោះមានទម្រង់តែមួយនៃ ជីវិតអស់កល្ប រស់ និងត្រូវបានប្រទានពរដោយព្រះជាម្ចាស់រៀងរហូត។

330 "ប៉ុន្តែព្រលឹងដែលបានធ្វើបាប ព្រលឹងនោះនឹង..." អ្វី? [ក្រុមជំនុំនិយាយ "...ស្លាប់"—Ed] នោះត្រឹមត្រូវ។ ដូច្នេះវាមិនមានជីវិតអស់កល្បឡើយ។ ជាការ ពិត។ វាមាន—ការដាក់ទោសរបស់វា ប៉ុន្តែមិនមែនជីវិតអស់កល្បឡើយ។

331 ដូច្នេះអ្នកឃើញ មានរឿងជាច្រើនត្រូវបង្រៀន យើងនឹងធ្វើពេលក្រោយ។ សូមព្រះអម្ចាស់ប្រទានពរអ្នក។

332 ឥឡូវចូរយើងច្រៀងចម្រៀងចាស់ពិរោះនេះ ខណៈដែលបងប្អូនស្រីរបស់យើងនឹងច្រៀង។ ខ្ញុំជឿថាស្ត្រីនៅទីនេះនឹងអាច...

333 រ៉ូសែលឡានោះជាម្ដាយរបស់អ្នក? [បងប្អូនស្រីរ៉ូសែលឡានិយាយ "ចាស"—Ed]។ ហេតុអ្វី សូមព្រះប្រទានពរដល់ចិត្តអ្នក។រីករាយបានជួបអ្នក បងប្អូនស្រី ដែលកំពុងធ្វើរឿងនោះ។ នោះពិតជាត្រឹមត្រូវ។

334 រ៉ូសែលឡាហ្វ្រីហ្វិនជាមិត្តសុភាពដែលយើងមាន។ នាងជាស្រីក្មេងម្នាក់ ដែលជាអ្នកផឹកស្រា សម្រាប់អ្នកជាមនុស្សនៅទីនេះ ប្រហែលជាមនុស្សចម្លែក។ រ៉ូសែលឡាមិនបារម្ភពីអ្វីដែលខ្ញុំនិយាយបែបនោះ។ ពេលនាងចូលមកវេទិកានៅ—កន្លែង...ទីនេះ អិនឌាអាយណា។ អ្នកធ្លាប់ឃើញមនុស្សទុច្ចរិត នាងជាម្នាក់ក្នុងចំណោមនោះ នាងជាអ្នកប្រមឹកលៀនភ្នែក។ កន្លែងដែល ដុកទ័រធំៗបួននាក់នៃ ឈីកាហ្គូ និយាយថា...ជាអ្នកញៀនស្រាអាណាមិក ហើយ អ្វីៗទៀត បោះបង់នាងចោលហើយ។ ប៉ុន្តែនៅយប់មួយពេលនាងចូលមកក្នុងការប្រជុំ ព្រះវិញ្ញាណបរិសុទ្ធដោះស្រាយបញ្ហាជីវិតរបស់នាង និង មានបន្ទូលប្រាប់នៅទីនេះ។ នោះជាការ ដោះស្រាយ។

335 ឥឡូវមើលទៅនាង អាយុប្រហែលសាមសិបឆ្នាំ អាចយកឈ្នះអ្នកអាយុដប់ប្រាំបីឆ្នាំបាន គួរឲ្យស្រឡាញ់ ជាស្រីក្មេងស្រស់ស្អាត។ មិនដែលភ្លក់ស្រាវីស្គីតាំងពីពេលនោះមក គ្មានចំណង់ទៀតឡើយ។ រស់នៅសម្រាប់ព្រះគ្រីស្ទ ដើរទៅតាមផ្លូវ គ្រប់កន្លែង ធ្វើទីបន្ទាល់ពីសិរីរុងរឿងរបស់ព្ទះជាម្ចាស់ ដល់មនុស្សបាប និងអ្នកប្រមឹកតាមកន្លែងរអិល និង កន្លែងផ្សេងទៀត ទូទាំង ឈីកាហ្គូ ធ្វើសម្រាប់ព្រះអម្ចាស់។

336 នាងត្រូវបានជ្រមុជទឹកក្នុងព្រះនាមព្រះអម្ចាស់យេស៊ូវ ហើយម្ដាយរបស់នាងមកយប់នេះដើម្បីធ្វើដូចគ្នា បើសិនព្រះជាម្ចាស់អាចព្យាបាលនាង បើព្រះយេស៊ូវអាចព្យាបាលនាង..."អ្វីក៏ដោយដែលធ្វើក្នុងព្រះបន្ទូល ឬការប្រព្រឹត្ត ចូរធ្វើដោយព្រះនាម..." [ក្រុមជំនុំនិយាយ "ព្រះយេស៊ូវគ្រីស្ទ"—Ed] នោះជាអ្វីដែលព្រះគម្ពីរបាននិយាយ។ ជាការត្រឹមត្រូវណាស់។

337 ត្រូវហើយ ឥឡូវយើងនឹងមានកម្មវិធីជ្រមុជទឹក។ យើងនឹងបិទភ្លើងប្រហែលពីរបីនាទី ដើម្បីប្រុងប្រៀបសម្រាប់កម្មវិធី ដើម្បីជ្រមុជទឹក ហើយ—ហើយយើងនឹងរំពឹងថានឹងមានពេលវេលាល្អក្នុងព្រះអម្ចាស់។

338 តើអ្នកនឹងធ្វើការជ្រមុជទឹកនៅយប់នេះ? ត្រូវណាស់ អ្នកល្អហើយ—អ្នកល្អហើយដែលបានត្រៀមរួចរាល់។ ហើយ ខ្ញុំនឹងចាប់ផ្ដើម ខ្ញុំនឹងដឹកនាំចម្រៀង និង

អ្វីទៀតកាល យើងកំពុងតែតម្រង់ទៅ។ ពេលគេកំពុង…[បងប្អូនប្រុសណេវិល និយាយ "មាននាឡិកានៅទីនោះទេ ដុក?"—Ed]។ សម្លៀកបំពាក់ជ្រមុជទឹក ដុក លឿនឡើង។ ត្រូវហើយ។

339 ចូរច្រៀងចម្រៀងចាស់មួយនេះ…[បងប្អូនប្រុសប្រាណហាំដឹកនាំក្រុមជំនុំច្រៀង កាលបងប្អូនប្រុសណេវិល ជ្រមុជទឹកឲ្យបងប្អូនស្រី—Ed]។

340 [ខ្សែអាត់ទទេ—Ed] ហើយ រហូតដល់យើងធ្វើការនេះ ពេលយើងចេញទៅ តើយើងត្រូវធ្វើអ្វី?

ចូរយកព្រះនាមព្រះយេស៊ូវ
ឱអ្នកមានចិត្តព្រួយលំបាក
ស្តេចលើស្តេច យើងអភិសេកទ្រង់
ពេលការធ្វើដំណើររបស់យើងបានពេញលេញ។

ពិតណាស់ សូមក្រោកឈរឡើង

ចូរយកព្រះនាមព្រះយេស៊ូវ
កូននៃសេចក្តីទុក្ខព្រួយ និង ទុក្ខសោក
អំណរ និង ការកំសាន្តចិត្តនឹងបានប្រទានដល់អ្នក…

341 ខ្ញុំនឹងប្រាប់អ្នកពីអ្វីនឹងធ្វើ។ សូមងាកទៅស្តាំហើយចាប់ដៃជាមួយនរណាម្នាក់នៅទីនេះ និង និយាយ "តើអ្នកសុខសប្បាយទេ បងប្អូន? ខ្ញុំរីករាយណាស់ដែលបាននៅក្នុងកម្មវិធីជាមួយអ្នក។"

នាមពិសេស នាមប្រសើរ!
…គឺជានាមនៃព្រះដ៏រស់
នាមពិសេស នាមប្រសើ អូ…

# គ្រាប់ពូជសត្វពស់ KHM58-0928E

(The Serpent′s Seed)

សារដែលធ្វើឡើងដោយបងប្រុស William Marrion Branham នេះ ត្រូវបានចែកចាយនៅល្ងាចថ្ងៃអាទិត្យ ថ្ងៃទី 28 កញ្ញា1958 នៅរោងឧបោសថBranham, Jeffersonville, Indiana, U.S.A។ រាល់ការខិតខំត្រូវបានធ្វើឡើងដោយការផ្ទៀងផ្ទាត់យ៉ាងត្រឹមត្រូវ ជាសារសម្លេងចេញពីខ្សែរអាត់ថត ចម្លង និង បោះពុម្ពដោយរក្សាសិទ្ធពីភាសារអង់គ្លេស។ ការបក ប្រែជាភាសារខ្មែរនេះ គឺត្រូវបោះពុម្ព និង ចែកចាយដោយ សម្លេងព្រះជាម្ចាស់ដែលបានថតទុក ។

KHMER

©2018 VGR, ALL RIGHTS RESERVED

VOICE OF GOD RECORDINGS
P.O. BOX 950, JEFFERSONVILLE, INDIANA 47131 U.S.A.
www.branham.org

## ការរក្សាសិទ្ធ

សៀវភៅនេះត្រូវបានរក្សាសិទ្ធ។ សៀវភៅនេះអាចថតចម្លង បានជាការប្រើប្រាស់ផ្ទាល់ខ្លួន ដោយសេរី ឥតគិតថ្លៃ ដើម្បីផ្សព្វផ្សាយដំណឹងល្អអំពីព្រះយេស៊ូគ្រិស្ត។ សៀវភៅនេះ មិនអាចលក់ ផលិតជាទ្រង់ទ្រាយធំ យកទៅដាក់ក្នុងវេបសាយ លក់តាមប្រព័ន្ធអេលេចត្រូនីក ឬ បកប្រែ ដោយគ្មានការអនុញ្ញាតិពី វ៉យ អូហ្វ ហ្គត់ រីខខតឌីង (VOICE OF GOD RECORDINGS®.)ឡើយ។

សម្រាប់ទំនាក់ទំនងបន្ថែម និង ឬសម្រាប់តម្រូវការទាក់ទងនឹងឯកសារសូមទំនាក់ទំនង៖

វ៉យស៍ អូហ្វ ហ្គត់ រីខខតឌីង (VOICE OF GOD RECORDINGS)

P.O. BOX 950, JEFFERSONVILLE, INDIANA 47131 U.S.A.

WWW.BRANHAM.ORG